គណៈកម្មាធិការជាតិបណ្តុះបណ្តាល

ទ.ជ.ម.ក
NEA
ទីភ្នាក់ងារជាតិមុខរបរ និងការងារ

អង្គការពលកម្មអន្តរជាតិ

# សៀវភៅណែនាំ

## ស្តីអំពី

# ការប្រឹក្សាយោបល់ការងារ

English version inside

www.nea.gov.kh

# មាតិកា ទំព័រ

**មាតិកា** ....................................................................................................... i

**អារម្ភកថា** ....................................................................................................... v

**មេរៀនទី១:** **សេចក្តីផ្តើមនៃវគ្គបណ្តុះបណ្តាលស្តីអំពីសេវាការងារ**

លំហាត់ទី១.១: សេចក្តីផ្តើម........................................................................ ១-២

លំហាត់ទី១.២: ការកំណត់គោលបំណងនៃការសិក្សាដោយខ្លួនឯង ............ ១-៥

បទបង្ហាញទី១.១: សេចក្តីសង្ខេបអំពីដំណើរការប្រឹក្សាយោបល់ការងារ..................................................................................... ១-៧

លំហាត់ទី១.៣: ចែករំលែកព័ត៌មានអំពីមជ្ឈមណ្ឌលការងាររបស់ខ្លួន........... ១-១០

ឯកសារទី១.១ (Handout 1.1): សេវាការងារនៅក្នុងប្រទេសកម្ពុជា-បញ្ហាប្រឈម និងកាលានុវត្តភាព ................................................ ១-១១

**មេរៀនទី២:** **ដំណើរការទទួលបានសេវារបស់អ្នកស្វែងរកការងារធ្វើ និងការធ្វើបទសម្ភាសន៍កំណត់អំពីតម្រូវការសេវា** (SND)

បទបង្ហាញទី២.១: សេចក្តីសង្ខេបអំពីការទទួលអតិថិជន និងការធ្វើបទសម្ភាសន៍ SND ........................................................................ ២-២

លំហាត់ទី២.១: ព័ត៌មានរបស់អតិថិជន ................................................... ២-៣

បទបង្ហាញទី ២.២: ដំណើរការនៃការទទួលបានព័ត៌មាន............................ ២-៤

លំហាត់ទី២.២: សំនួរដែលអាចចោទសួរដោយអ្នកស្វែងរកការងារធ្វើក្នុងពេលមកកាន់មជ្ឈមណ្ឌលការងារ.............................................................. ២-៥

បទបង្ហាញទី២.៣: ដំណើរការនៃការកំណត់អំពីតម្រូវការសេវា(SND)-ជម្រើសចំនួន ៣ យ៉ាង ក្នុងការតាមដាន (Follow-up) ............................. ២-៦

លំហាត់ទី២.៣: ការយល់ឃើញចំពោះខ្លួនឯង និងរបស់អតិថិជននៅក្នុងការធ្វើបទសម្ភាសន៍ SND.............................................................. ២-៧

បទបង្ហាញទី២.៤: ដំណាក់កាលទាំង៦នៅក្នុងការធ្វើបទសម្ភាសន៍ SND..... ២-៩

លំហាត់ទី ២.៤: ការអនុវត្តការធ្វើបទសម្ភាសន៍ SND ................................. ២-១២

ឧបសម្ព័ន្ធទី ២.១: ទម្រង់អ្នកស្វែងរកការងារធ្វើ ......................................... ២-១៣

ឧបសម្ព័ន្ធទី ២.២: ទម្រង់ SND សម្រាប់អ្នកស្វែងរកការងារធ្វើ .................... ២-១៤

ឧបសម្ព័ន្ធទី ២.៣: ចំណេះដឹង និងជំនាញសម្រាប់ធ្វើបទសម្ភាសន៍ SND.... ២-១៥

ឧបសម្ព័ន្ធទី ២.៤: ទម្រង់សម្តែងជាអតិថិជនក្នុងការធ្វើបទសម្ភាសន៍ SND... ២-១៦

ឧបសម្ព័ន្ធទី ២.៥: ទម្រង់ទទួលព័ត៌មានត្រឡប់ (Feedback form)............. ២-១៧

ឧបសម្ព័ន្ធទី ២.៦: តារាងអ្នកសង្កេតការណ៍ ............................................... ២-១៨

**មេរៀនទី៣: ការបង្កើតទម្រង់គំរូនៃលទ្ធភាពទទួលបានការងារធ្វើ និងភាពគ្រប់គ្រាន់សម្រាប់អ្នកប្រើប្រាស់សេវា**

បទបង្ហាញទី ៣.១: កត្តាដែលជះឥទ្ធិពលដល់លទ្ធភាពទទួលបានការងារធ្វើ ..... ៣-៣

បទបង្ហាញទី ៣.២: ការបង្កើតទម្រង់គំរូដើម្បីធ្វើឱ្យលទ្ធភាពទទួលបានការងារធ្វើមានភាពល្អប្រសើរ ..... ៣-៥

បទបង្ហាញទី ៣.៣: ដំណាក់កាលអន្តកាលទៅកាន់ពិភពការងារ និងចំណុចទាំង ៥ យ៉ាងដែលមាននៅក្នុងលទ្ធភាពទទួលបានការងារធ្វើ ..... ៣-៧

លំហាត់ទី ៣.១: កំណត់ពីបញ្ហាគន្លឹះដែលពាក់ព័ន្ធទៅនឹងទម្រង់គំរូនៃលទ្ធភាពទទួលបានការងារធ្វើ និងភាពគ្រប់គ្រាន់របស់អតិថិជននៅក្នុងទីផ្សារការងារនៅប្រទេសកម្ពុជា ..... ៣-៩

ឧបសម្ព័ន្ធទី ៣.១:សំនួរជ្រើសរើស ត្រូវ/ខុស ស្ដីអំពីស្ថានភាពជាក់ស្ដែងនៅក្នុងទីផ្សារការងារនៅប្រទេសកម្ពុជា ..... ៣-១០

ឧបសម្ព័ន្ធទី ៣.២: ប្រធានបទសម្រាប់ក្រុមពិភាក្សាតូចៗមាននៅក្នុងលំហាត់ទី៣.១ ពាក់ព័ន្ធទៅនឹងការអភិវឌ្ឍលទ្ធភាពទទួលបានការងារធ្វើ ..... ៣-១៣

**មេរៀនទី៤: ដំណើរការដោះស្រាយបញ្ហាក្នុងការប្រឹក្សាយោបល់ការងារ**

បទបង្ហាញទី ៤.១:ដំណាក់កាលទី១-ការកំណត់ពីការលំបាកក្នុងការងារ ..... ៤-៤

លំហាត់ទី៤.១: ការកំណត់ពីការលំបាកក្នុងការងារ ..... ៤-៧

បទបង្ហាញទី ៤.២: ដំណាក់កាលទី២-ការបញ្ជាក់ពីការលំបាកក្នុងការងារ ..... ៤-៨

លំហាត់ទី ៤.២: ជំហានក្នុងការកំណត់ដំណាក់កាលទី១ និងទី២ នៃដំណើរការដោះស្រាយបញ្ហា ..... ៤-១០

បទបង្ហាញទី ៤.៣: ដំណាក់កាលទី៣-ការបង្កើត និងការចងក្រងផែនការសកម្មភាព ..... ៤-១១

លំហាត់ទី ៤.៣: ការបង្កើតផែនការសកម្មភាព ..... ៤-១៣

បទបង្ហាញទី ៤.៤: ដំណាក់កាលទី៤ - ការអនុវត្ត និងការតាមដាន (Follow-up) ..... ៤-១៤

បទបង្ហាញទី ៤.៥: ការពិនិត្យអំពីលទ្ធផលដែលសម្រេចបាននៃគោលដៅប្រឹក្សាយោបល់ ..... ៤-១៧

បទបង្ហាញទី ៤.៦: ការកំណត់អំពីភាពគ្រប់គ្រាន់របស់អតិថិជនក្នុងការងារទទួលបានការងារធ្វើ ..... ៤-១៩

លំហាត់ទី ៤.៥: តើអតិថិជនបានសម្រេចគោលដៅនៃការប្រឹក្សាយោបល់ដែរឬទេ? ..... ៤-២០

ឯកសារទី ៤.១: តារាងសង្កេតការទី១ ..... ៤-២១

ឯកសារទី ៤.២: កម្រងរឿងរបស់អតិថិជន ....................................................៤-២២
ឯកសារទី ៤.៣: តារាងសង្កេតការទី២ ....................................................៤-២៥
ឯកសារទី ៤.៤: ផែនការសកម្មភាពការងារ ....................................................៤-២៦
ឯកសារទី ៤.៥: កម្រងរឿងរបស់អតិថិជន ....................................................៤-២៩
ឯកសារទី ៤.៦: ការតាមដានទៅលើបទអន្តរាគមន៍ ( Follow-up ) ....................................................៤-៣០
ឯកសារទី ៤.៧: តារាងសង្កេតការទី៣ ....................................................៤-៣១
ឯកសារទី ៤.៨: ការបង្កើតភាពជាដៃគូយុទ្ធសាស្ត្រជាមួយអង្គការ
មិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល ....................................................៤-៣២

**មេរៀនទី៥: ការរៀបចំ និងការធ្វើផែនការចុះជួបនិយោជក**

គោលគំនិតជាមូលដ្ឋាន ....................................................៥-២
បទបង្ហាញទី៥.១ : និយមន័យ Marketing ....................................................៥-៨
លំហាត់ទី ៥.១: លក្ខខណ្ឌនៃការជ្រើសរើសនិយោជកអាទិភាព ....................................................៥-៩
បទបង្ហាញទី ៥.២: ការរៀបចំទំនាក់ទំនងនិយោជក ....................................................៥-១០
លំហាត់ទី ៥.២: ការយល់ដឹងពីនិយោជកអាទិភាពនៅក្នុងតំបន់
របស់លោកអ្នក ....................................................៥-១១
បទបង្ហាញទី ៥.៣: គំនិតផ្តួចផ្តើម Marketing ....................................................៥-១២
លំហាត់ទី ៥.៣: ការយល់ដឹងពីនិយោជក និងការបង្កើតនូវគោលដៅនៃការ
ទំនាក់ទំនង ....................................................៥-១៣
បទបង្ហាញទី ៥.៤: ការជ្រើសរើសមធ្យោបាយក្នុងការផ្សព្វផ្សាយ ....................................................៥-១៤
បទបង្ហាញទី ៥.៥: ការរៀបចំធ្វើបទបង្ហាញទៅកាន់និយោជក ....................................................៥-១៨
លំហាត់ទី ៥.៤: ការធ្វើបទបង្ហាញដល់និយោជកតែម្នាក់ ....................................................៥-២៤
លំហាត់ទី ៥.៥: ការធ្វើបទបង្ហាញទៅកាន់ក្រុមនិយោជក ....................................................៥-២៥
បទបង្ហាញទី ៥.៦: ការរំលឹកឡើងវិញនូវដំណាក់កាលទាំង ៩ នៅក្នុងការ
រៀបចំផែនការសកម្មភាពសម្រាប់ទំនាក់ទំនងនិយោជក ....................................................៥-២៦
ឧបសម្ព័ន្ធទី ៥.១: តារាងផែនការ Marketing ....................................................៥-២៧
ឧបសម្ព័ន្ធទី ៥.២ : គុណសម្បត្តិ និងគុណវិបត្តិនៃការទំនាក់ទំនង
និយោជកតាមទូរស័ព្ទ និងការចុះជួបនិយោជក ....................................................៥-២៩

**មេរៀនទី៦: ផែនការសកម្មភាព និងការវាយតម្លៃវគ្គបណ្តុះបណ្តាល**

បទបង្ហាញទី ៦.១: ការរំលឹកឡើងវិញអំពីទម្រង់គំរូនៃការផ្តល់សេវាការងារ ...៦-២
លំហាត់ទី ៦.១: រំលឹកឡើងវិញ និងការពិភាក្សាទៅលើទម្រង់គំរូនៃការផ្តល់
ប្រឹក្សាយោបល់ការងារ ....................................................៦-៣
លំហាត់ទី ៦.២: ផែនការសកម្មភាព ....................................................៦-៤
លំហាត់ទី ៦.៣: ការវាយតម្លៃវគ្គបណ្តុះបណ្តាល និងការបញ្ចប់ ....................................................៦-៥

# អារម្ភកថា

ទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) នៃគណៈកម្មាធិការជាតិបណ្ដុះបណ្ដាល មានសេចក្ដីសោមនស្សរីករាយក្នុងការដាក់ឱ្យប្រើប្រាស់នូវ "***សៀវភៅណែនាំស្ដីអំពីការប្រឹក្សាយោបល់ការងារ***" ដែលបានធ្វើការប្រែសម្រួលពីសៀវភៅ "Manual of Employment Counselling" របស់អង្គការ ILO ។ សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងដោយ ទ.ជ.ម.ក ក្រោមកិច្ចសហការ និងជំនួយបច្ចេកទេសពីសំណាក់អង្គការពលកម្មអន្តរជាតិ (ILO)។ សៀវភៅណែនាំនេះរៀបចំឡើងដើម្បីជួយពង្រឹងសមត្ថភាពមន្ត្រីមជ្ឈមណ្ឌលការងារ ក្នុងការផ្ដល់ប្រឹក្សាយោបល់ការងារដល់អ្នកស្វែងរកការងារធ្វើ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ទំនួលខុសត្រូវខ្ពស់ ព្រមទាំងជួយដល់សិស្ស-និស្សិតដែលជួបប្រទះការលំបាកក្នុងការចូលទៅក្នុងទីផ្សារការងារ។

ការរៀបចំផែនការអាជីព និងការប្រឹក្សាយោបល់វិជ្ជាជីវៈបានគ្រប់គ្រាន់ គឺជាតម្រូវការជាចាំបាច់ដើម្បីទទួលបានការងារធ្វើដែលល្អ និងមានគុណភាព។ ការផ្ដល់នូវមគ្គុទេសន៍ការងារ និងព័ត៌មានទីផ្សារការងារដែលត្រឹមត្រូវ ផ្ដល់ឱ្យបុគ្គលនីមួយៗនូវជម្រើសដែលបានណែនាំ ដែលនឹងនាំពួកគេមានការងារធ្វើដែលជាការងារគួរជាទីពេញចិត្ត។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកស្វែងរកការងារធ្វើនៅក្នុងប្រទេសកម្ពុជាភាគច្រើន ជាពិសេសសិស្ស-និស្សិតដែលទើបនឹងបញ្ចប់ការសិក្សាពីសាលានិងសាសកលវិទ្យាល័យនានា តែងជួបការលំបាកក្នុងការទទួលបានការងារធ្វើបានឆាប់រហ័ស។ កត្តាមួយក្នុងចំណោមកត្តាសំខាន់ៗដែលនាំឱ្យកើតមាននូវបញ្ហានេះ គឺការខ្វះខាតនូវការផ្ដល់សេវាការងារ និងការប្រឹក្សាយោបល់ការងារ។ ទ.ជ.ម.ក បាននឹងកំពុងប្រើប្រាស់សៀវភៅណែនាំនេះ ដូច្នេះបុគ្គលិកមជ្ឈមណ្ឌលការងារនឹងអាចណែនាំអ្នកស្វែងរកការងារធ្វើ ដោយទទួលបានបទពិសោធន៍ពីផលលំបាកនៃទីផ្សារការងារធ្ងន់ធ្ងរ ដើម្បីកំណត់ពីតម្រូវការទាក់ទងនឹងការមានការងារធ្វើរបស់ពួកគេ។ អង្គការ ILO បានផ្ដល់ការគាំទ្រដល់បុគ្គលិកមជ្ឈមណ្ឌលការងារក្នុងការទទួលបានការបណ្ដុះបណ្ដាល ព្រមទាំងបានជួយដល់ ទ.ជ.ម.ក ក្នុងការបោះពុម្ពសៀវភៅណែនាំនេះ និងឯកសារជំនួយផ្សេងៗទៀត ដូចជាសម្ភារៈជំនួយអាជីព និងប័ណ្ណណែនាំជាដើម។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បាននិងកំពុងផ្ដោតការយកចិត្តទុកដាក់ជាខ្លាំងក្នុងការបង្កើតការងារ និងការផ្ដល់នូវឱកាសការងារ ដូចដែលបានរំលេចឡើងក្នុង "**យុទ្ធសាស្ត្រចតុកោណ**" ដើម្បី ***កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព*** នៅកម្ពុជា **ដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣**។ គោលនយោបាយនេះបានកំណត់យ៉ាងច្បាស់ថា ការទទួលបានការងារធ្វើរបស់ប្រជាពលរដ្ឋជាកត្តាមួយដ៏សំខាន់ក្នុងការបង្កើនកម្រិតជីវភាព ការកាត់បន្ថយភាពក្រីក្រ ព្រមទាំងបង្កើនប្រសិទ្ធិភាពសេដ្ឋកិច្ចជាតិទាំងមូល។

ដើម្បីជាឧបករណ៍មួយក្នុងការចូលរួមចំណែកអនុវត្តគោលនយោបាយខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត ទ.ជ.ម.ក តាមអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ស្ថិតនៅក្រោមគណៈកម្មាធិការជាតិបណ្ដុះបណ្ដាល ដោយមាន**ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រីជាប្រធាន។ ទ.ជ.ម.ក មានតួនាទី និងភារកិច្ចផ្ដល់សេវាការងារ និងព័ត៌មានទីផ្សារការងារប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ជូនដល់អ្នកស្វែងរកការងារធ្វើ និយោជក អ្នកផ្ដល់ការអប់រំបណ្ដុះបណ្ដាល អ្នករៀបចំគោលនយោបាយនិងផែនការ និងសាធារណជនទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បន្ថែម

លើនេះ ក្នុងឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ ទ.ជ.ម.ក ជាអង្គភាពស្ថិតិដែលជាផ្នែកមួយនៃប្រព័ន្ធស្ថិតិជាតិ និងមានតួនាទីនិងភារកិច្ចក្នុងការប្រមូល វិភាគ ចងក្រង និងផ្សព្វផ្សាយនូវព័ត៌មានទីផ្សារការងារជាសាធារណៈនៅមួយកន្លែងងាយស្រួលតាមប្រព័ន្ធអេឡិចត្រូនិច និងក្នុងទម្រង់ក្រដាស។

ការបង្កើត ទ.ជ.ម.ក និងមជ្ឈមណ្ឌលការងារ ក្នុងឆ្នាំ២០០៩ និង២០១០ ក៏ស្របពេលផងដែរ ទន្ទឹមនឹងគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលក្នុងការជួយសម្រាលការកើនឡើងនៃការបញ្ឈប់ពីការងារ និងភាពគ្មានការងារធ្វើរបស់ប្រជាពលរដ្ឋដោយសារឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចពិភពលោក និងជួយផ្តល់ការគាំទ្រដល់និយោជកក្នុងការជ្រើសរើសកម្លាំងពលកម្មក្នុង និងបន្ទាប់ពីដំណាក់កាលងើបឡើងវិញនៃសេដ្ឋកិច្ចជាតិក្រោយពីជួបវិបត្តិ។

តាងនាម ទ.ជ.ម.ក ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះលោកស្រី Carmela I. Torres អ្នកជំនាញជាន់ខ្ពស់ផ្នែកជំនាញ និងលទ្ធភាពការងារនៃការិយាល័យអនុតំបន់សម្រាប់អាស៊ីបូព៌ា លោក **នួន ឫទ្ធី** អ្នកពិគ្រោះយោបល់ជាតិ ព្រមទាំងបុគ្គលិករបស់អង្គការ ILO ទាំងអស់ ដែលបានគាំទ្រដល់ដំណើរការប្រែសម្រួល និងបោះពុម្ពសៀវភៅណែនាំនេះ។ ឆ្លៀតក្នុងឱកាសនេះផងដែរ ខ្ញុំសូមថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងបុគ្គលិករបស់ ទ.ជ.ម.ក ដោយធ្វើការយ៉ាងសស្រាក់សស្រាំក្នុងការបញ្ចប់ និងបោះពុម្ពផ្សព្វផ្សាយសៀវភៅណែនាំនេះ។

ជាទីបញ្ចប់ ខ្ញុំមានជំនឿយ៉ាងមុតមាំថា សៀវភៅណែនាំនេះនឹងជាឧបករណ៍សម្រាប់ជួយណែនាំដល់មន្ត្រីរបស់ ទ.ជ.ម.ក និងមជ្ឈមណ្ឌលការងារ ក្នុងបង្កើនសេវាប្រឹក្សាយោបល់ការងារ និងការផ្តល់សេវាឱ្យកាន់តែល្អប្រសើរឡើង។

**នាយកការិយាល័យអង្គការពលកម្មអន្តរជាតិប្រចាំប្រទេសថៃ កម្ពុជា និងឡាវ**



Jiyuan Wang

**ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ**



**ហុង ជឿន**

ទីភ្នាក់ងារជាតិមុខរបរ និងការងារ
រាជធានីភ្នំពេញ ខែសីហា ឆ្នាំ២០១១

# មេរៀនទី ១

# សេចក្តីផ្តើមនៃវគ្គបណ្តុះបណ្តាលស្តីអំពីសេវាការងារ



**គោលបំណងនៃការសិក្សា:** នៅពេលបញ្ចប់មេរៀនទី ១ នេះ សិក្ខាកាមទាំងអស់នឹង:

- យល់ដឹងអំពីគោលបំណងនៃវគ្គបណ្តុះបណ្តាល
- យល់ដឹងអំពីរបៀបវារៈ និងមាតិកានៃវគ្គបណ្តុះបណ្តាល
- យល់ដឹងអំពីវិធីសាស្រ្តក្នុងការចាត់ចែងសិក្ខាកាម
- យល់ដឹងអំពីតម្រូវការនៃការផ្តល់ប្រឹក្សាយោបល់ការងារ ទោះបីជាពេលវេលា ឬនៅទីកន្លែងណាដែលមិនសូវសំបូរការងារពិតប្រាកដក៏ដោយ
- យល់ដឹងអំពីសេចក្តីរំពឹងទុករបស់សិក្ខាកាមដែលត្រូវបានកំណត់ ឬចាត់ចែងដោយអ្នករៀបចំវគ្គបណ្តុះបណ្តាល
- អាចកំណត់បាននូវគោលបំណងសិក្សារបស់សិក្ខាកាមគ្រប់រូប
- ចែករំលែកព័ត៌មានអំពីការផ្តល់ប្រឹក្សាយោបល់ការងារនៅតាមមជ្ឈមណ្ឌលការងាររបស់ខ្លួន

**រយៈពេល:** ១.៥ ម៉ោង

**សេចក្តីសង្ខេប:** នៅក្នុងមេរៀននេះ

- លំហាត់ទី ១.១: សេចក្តីផ្តើម
- លំហាត់ទី ១.២: ការកំណត់គោលបំណងនៃការសិក្សាដោយខ្លួនឯង
- បទបង្ហាញទី១.១: សេចក្តីសង្ខេបអំពីដំណើរការប្រឹក្សាយោបល់ការងារ
- លំហាត់ទី១.៣: ចែករំលែកព័ត៌មានអំពីមជ្ឈមណ្ឌលការងារ របស់ខ្លួន
- ឯកសារទី១.១ (Handout 1.1): សេវាការងារនៅប្រទេសកម្ពុជា: បញ្ហាប្រឈម និងកាលានុវត្តភាព

# លំហាត់ទី ១.១: សេចក្តីផ្តើម

រយៈពេល: ៤០នាទី

គោលបំណង:

- ✓ សិក្ខាកាម និងអ្នកសម្របសម្រួលទាំងអស់ធ្វើការណែនាំខ្លួនទៅវិញទៅមក ព្រមជាមួយនឹងការចែករំលែកនូវព័ត៌មាន និងបទពិសោធន៍ពីមជ្ឈមណ្ឌលលការងាររបស់ខ្លួន។

សេចក្តីណែនាំ:

- ✓ ចំពោះលោកអ្នកដែលមានវត្តមាននៅក្នុងវគ្គបណ្តុះបណ្តាលទាំងអស់ ត្រូវធ្វើការណែនាំខ្លួនអំពីឈ្មោះ មុខតំណែង តួនាទី (ប្រសិនបើជាអ្នកសម្របសម្រួល និងអ្នកបកប្រែភាសា) និងអ្នកតំណាងមជ្ឈមណ្ឌលការងារ (ប្រសិនបើជាសិក្ខាកាម)។
- ✓ ធ្វើការបែងចែកជាក្រុមពិភាក្សា ដោយអាស្រ័យទៅតាមចំនួនមជ្ឈមណ្ឌលការងារ របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- ✓ ការសរសេរព័ត៌មាន (រយៈពេល ២០នាទី) នៅលើក្រដាសដែលបានចែកជូន រួមមាន៖
  - ឈ្មោះ ឬទីតាំងរបស់មជ្ឈមណ្ឌលការងារ
  - តំបន់ដែលមជ្ឈមណ្ឌលការងារកំពុងដំណើរការ
  - ចំនួនប្រជាពលរដ្ឋនៅក្នុងតំបន់ដែលមជ្ឈមណ្ឌលការងារស្ថិតនៅ
  - សង្ខេប:
    - រៀបរាប់អំពីប្រភេទនិយោជកនៅក្នុងតំបន់មជ្ឈមណ្ឌលការងាររបស់លោកអ្នក
    - រៀបរាប់អំពីនិយោជកសំខាន់ៗ (ចំនួននិយោជក) នៅក្នុងតំបន់របស់លោកអ្នក
  - ព័ត៌មានដែលពាក់ព័ន្ធទៅនឹងមជ្ឈមណ្ឌលការងារ និងតំបន់របស់លោកអ្នក
- ✓ នៅក្នុងក្រុមពិភាក្សាធំ សិក្ខាកាមនៅតាមមជ្ឈមណ្ឌលការងារនីមួយៗត្រូវធ្វើបទបង្ហាញ និងពិភាក្សាអំពីព័ត៌មានទាំងនេះ (រយៈពេល ២០នាទី)។

# កម្មវិធីបណ្តុះបណ្តាល

| | | |
|---|---|---|
| ថ្ងៃទី១ | ពេលព្រឹក | មេរៀនទី១: សេចក្តីផ្តើមអំពីការវាយតម្លៃទៅលើសមាសភាពសំខាន់ៗនៃការប្រឹក្សាយោបល់ការងារ |
| | ពេលរសៀល | មេរៀនទី២: ការទទួលបានចំណេះដឹង និងការធ្វើបទសម្ភាសន៍ដើម្បីកំណត់អំពីតម្រូវការសេវា |
| ថ្ងៃទី២ | ពេលព្រឹក | មេរៀនទី៣ - ផ្នែកទី១: ការបង្កើតទម្រង់គំរូនៃលទ្ធភាពទទួលបានការងារធ្វើដែលគ្រប់គ្រាន់សម្រាប់អ្នកប្រើប្រាស់សេវារួមមាន ៥ ចំណុចសំខាន់គឺៈ ការគ្រប់គ្រងខ្លួនឯង ការសម្រេចចិត្តចាប់យកអាជីព ការពង្រឹងជំនាញ ការស្វែងរកការងារធ្វើ និងការថែរក្សាការងារឱ្យបិតបេរ |
| | ពេលរសៀល | មេរៀនទី៣ - ផ្នែកទី២: កត្តាដែលជះឥទ្ធិពលទៅលើលទ្ធភាពនៃការទទួលបានការងារធ្វើ |
| ថ្ងៃទី៣ | ពេលព្រឹក | មេរៀនទី៤ - ផ្នែកទី១: ដំណើរការនៃការដោះស្រាយបញ្ហានៅក្នុងការប្រឹក្សាយោបល់ការងារ |
| | ពេលរសៀល | មេរៀនទី៤ - ផ្នែកទី២: ការអនុវត្តនូវដំណាក់កាលទាំង ៨ នៅក្នុងការវាយតម្លៃការប្រឹក្សាយោបល់ការងារ |
| ថ្ងៃទី៤ | ពេលព្រឹក | មេរៀនទី៤-ផ្នែកទី៣: ការធ្វើបទបង្ហាញរបស់ក្រុមពិភាក្សាតូចៗ និងការទទួលបានព័ត៌មានត្រលប់អំពីការអនុវត្តនៅក្នុងដំណាក់កាលនីមួយៗនៃដំណើរការប្រឹក្សាយោបល់ការងារ |
| | ពេលរសៀល | មេរៀនទី៥ - ផ្នែកទី១: ការរៀបចំផែនការ និងការចុះជួបនិយោជក |
| ថ្ងៃទី៥ | ពេលព្រឹក | មេរៀនទី៥ - ផ្នែកទី២: ការអនុវត្តក្នុងការចុះជួបនិយោជក |
| | ពេលរសៀល | មេរៀនទី៦: ផែនការសកម្មភាព និងការវាយតម្លៃវគ្គបណ្តុះបណ្តាល |

ការធ្វើបទបង្ហាញ(រយៈពេល ១៥ នាទី): ការរំលឹក និងការបញ្ជាក់ឡើងវិញនូវចំណុចដែលមាននៅក្នុងកម្មវិធីបណ្តុះបណ្តាល។ ការពន្យល់ដោយសង្ខេបអំពីប្រធានបទសំខាន់ៗរបស់វគ្គបណ្តុះបណ្តាល និងវិធីសាស្ត្របណ្តុះបណ្តាលដែលនឹងត្រូវប្រើប្រាស់។

- សេចក្តីសង្ខេបអំពីដំណើរការនៃការប្រឹក្សាយោបល់ការងារ
- តម្រូវការប្រឹក្សាយោបល់ការងារនៅប្រទេសកម្ពុជា

- ការបង្កើតទំនាក់ទំនង
- ទម្រង់គំរូនៃលទ្ធភាពទទួលបានការងារធ្វើ: កត្តាដែលជះឥទ្ធិពលទៅលើលទ្ធភាពទទួលបានការងារធ្វើ
- ការប៉ាន់ស្មានអំពីតម្រូវការរបស់អតិថិជន
- ការកំណត់បញ្ហានៃលទ្ធភាពទទួលបានការងារធ្វើ
- ការបញ្ជាក់អំពីបញ្ហានៃលទ្ធភាពទទួលបានការងារធ្វើ
- ការបង្កើតផែនការសកម្មភាព
- ការបង្កើតនូវទំនាក់ទំនងជាមួយអតិថិជនប្រកបដោយប្រសិទ្ធភាពខ្ពស់
- ការប្រើប្រាស់នូវជំនាញគ្រប់គ្រងហេតុការណ៍ដើម្បីគាំទ្រ និងសង្កេតទៅលើអតិថិជន ព្រមជាមួយនឹងការរៀបចំឯកសារឱ្យបានសមស្រប
- ដំណាក់កាលនានាដែលពាក់ព័ន្ធទៅនឹងការរៀបចំចុះជួបនិយោជក

វិធីសាស្រ្តក្នុងការបណ្តុះបណ្តាល ដែលនឹងត្រូវប្រើប្រាស់នៅក្នុងវគ្គបណ្តុះបណ្តាលរួមមានៈ ការធ្វើបទបង្ហាញរបស់អ្នកសម្របសម្រួល ការពិភាក្សាជាក្រុម លំហាត់អនុវត្តដូចជា បទបង្ហាញ ការអនុវត្តសាកល្បង (ការសម្តែងនៅតាមក្រុមពិភាក្សាតូចៗ): ការផ្តល់ព័ត៌មានត្រលប់ (Feedback) របស់សិក្ខាកាមម្នាក់ៗ។



# លំហាត់ទី ១.២: ការកំណត់គោលបំណងនៃការសិក្សាដោយខ្លួនឯង



រយៈពេល: ២០នាទី

គោលបំណង:

- ✓ សិក្ខាកាមគ្រប់រូបលើកឡើងអំពីគោលបំណងនៃការបណ្តុះបណ្តាលរបស់ខ្លួន។

សេចក្តីណែនាំ:

- ✓ សិក្ខាកាមគ្រប់រូបធ្វើការគូសបញ្ជាក់អំពីគោលបំណងនៃការបណ្តុះបណ្តាលរៀងៗខ្លួន ដោយប្រើប្រាស់នូវទម្រង់ខាងក្រោមដែលមានចំណងជើងថា **"គោលបំណងនៃការបណ្តុះបណ្តាលរបស់សិក្ខាកាមគ្រប់រូប"** (រយៈពេល ២០នាទី)
- ✓ អ្នកផ្តល់ការបណ្តុះបណ្តាលនឹងដឹកនាំការពិភាក្សាដោយផ្អែកទៅលើគោលបំណងរបស់សិក្ខាកាមនៅក្នុងក្រុមពិភាក្សាធំ (រយៈពេល ២០នាទី)
- ✓ សរសេរអំពីចម្លើយនៅលើក្រដាសដែលបានចែកជូន ហើយរក្សាទុកក្រដាសដែលបានសរសេររួច និងពិនិត្យឡើងវិញនៅពេលបញ្ចប់វគ្គបណ្តុះបណ្តាល ដើម្បីប្រាកដថាវគ្គបណ្តុះបណ្តាលទាំងមូលបានឆ្លើយតបទៅនឹងគោលបំណងនៃការបណ្តុះបណ្តាលរបស់សិក្ខាកាមគ្រប់រូប។

## គោលបំណងនៃការបណ្តុះបណ្តាលរបស់សិក្ខាកាមគ្រប់រូប

១. លើកឡើងពី ៣ ទៅ ៥ ចំណុចអំពីគោលបំណងនៃការបណ្តុះបណ្តាល:

ខ្ញុំចង់សិក្សាអំពី:

២. តើបទពិសោធន៍ការងារអ្វីខ្លះដែលឱ្យលោកអ្នកយល់ដឹងអំពីចំណុចដែលមាននៅក្នុងគោលបំណងនៃការបណ្តុះបណ្តាលនេះ?



# បទបង្ហាញទី ១.១ : សេចក្តីសង្ខេបអំពីដំណើរការ ប្រឹក្សាយោបល់ការងារ



ការកំណត់និយមន័យ "**ការវាយតម្លៃទៅលើការប្រឹក្សាយោបល់**" និងការបញ្ជាក់អំពីគោលគំនិតសំខាន់ៗ រួមមាន:

ទំព័របង្ហាញទី ១.១

**តើអ្វីទៅជាការវាយតម្លៃការប្រឹក្សាយោបល់?**

- ជាការចាប់ផ្តើមដំណើរការប្រឹក្សាយោបល់ជាមួយអតិថិជនដែលមានការលំបាកក្នុងការកំណត់ការងាររបស់ខ្លួនទៅនឹងតម្រូវការនៅក្នុងទីផ្សារការងារ
- ជាកិច្ចខិតខំប្រឹងប្រែងសហការក្នុងការវាយតម្លៃការងារដែលពាក់ព័ន្ធទៅនឹងតម្រូវការដែលធ្វើឱ្យលទ្ធភាពទទួលបានការងារធ្វើរបស់អ្នកទាំងនោះល្អប្រសើរឡើងវិញ
- ការជួយជ្រោមជ្រែងដល់អ្នកស្វែងរកការងារធ្វើឱ្យក្លាយជាបុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំ ការទទួលបាន និងថែរក្សាការងាររបស់ខ្លួនឱ្យបានឋិតថេរ ។

កំណត់ចំណាំ:

- ***ការវាយតម្លៃទៅលើជាតុផ្សំនៅក្នុងការប្រឹក្សាយោបល់ការងារ*** គឺជាដំណើរការចាប់ផ្តើមដំបូង ឬកំពុងអនុវត្តនៃការប្រឹក្សាយោបល់ការងារជូនដល់អតិថិជនដែលជួបប្រទះការលំបាកធ្ងន់ធ្ងរនៅក្នុងទីផ្សារការងារ
- ដោយសារមានការសហការយ៉ាងស្អិតរមួតរវាងអតិថិជន និងអ្នកផ្តល់ប្រឹក្សាយោបល់ការងារ ដំណើរការនេះបានជួយដល់អ្នកស្វែងរកការងារធ្វើវាយតម្លៃអំពីតម្រូវការនានាដែលពាក់ព័ន្ធទៅនឹងការងារ និងជួយបង្កើននូវលទ្ធភាពទទួលបានការងារធ្វើរបស់អ្នកទាំងនោះ ដើម្បីទទួលបានការងារសមរម្យ។ បន្ថែមលើនេះ ដំណើរការនេះក៏ជួយដល់អ្នកស្វែងរកការងារធ្វើទាំងឡាយណាដែលមិនអាចពង្រឹងសមត្ថភាពរបស់ខ្លួនឱ្យបានឆាប់រហ័សនៅក្នុងការរៀបចំ ការទទួលបាន និងការថែរក្សានូវការងាររបស់ខ្លួនឱ្យបានឋិតថេរ។

ទំព័របង្ហាញទី ១.២

**តើអ្វីទៅជាលទ្ធផលនៃការវាយតម្លៃការប្រឹក្សាយោបល់ការងារ?**

អ្នកស្វែងរកការងារធ្វើត្រូវបានជួយ ដូចជា៖

- កំណត់អំពីការលំបាករបស់ខ្លួនក្នុងការស្វែងរកការងារធ្វើ
- កំណត់គោលដៅ
- បង្កើតផែនការសកម្មភាពដែលច្បាស់លាស់ ដើម្បីស្វែងរកការងារធ្វើដែលសមរម្យ
- ប្រើប្រាស់ធនធានដែលមាននៅក្នុងមជ្ឈមណ្ឌលការងារ និងនៅក្នុងសហគមន៍ ដើម្បីបង្កើនលទ្ធភាពទទួលបានការងារធ្វើ
- គិតពិចារណាទៅលើបទអន្តរាគមន៍ ឬសកម្មភាពដទៃទៀតដែលអាចជួយដល់អ្នកស្វែងរកការងារធ្វើ ពុះពារទៅនឹងបញ្ហាដែលបានជួបប្រទះក្នុងការងារ ដូចជានៅក្នុងដំណើរការវាយតម្លៃ (ឧទា.បញ្ហានៅក្នុងលទ្ធភាពការទទួលបានការងារធ្វើទាំង៥យ៉ាង)

ទំព័របង្ហាញទី ១.៣

**កត្តាទាំង ៥ យ៉ាងនៃលទ្ធភាពទទួលបានការងារធ្វើ**

- កត្តាបុគ្គល (ដូចជាជំនាញក្នុងការធ្វើបទបង្ហាញ)
- ការជ្រើសរើសអាជីព (មានគោលបំណងការងារច្បាស់លាស់)
- ជំនាញក្នុងការងារ (ជំនាញដែលតម្រូវសម្រាប់បំពេញការងារ)
- សមត្ថភាពក្នុងការស្វែងរកការងារធ្វើ (តើបែបបទណាខ្លះក្នុងការស្វែងរកការងារធ្វើដោយខ្លួនឯង?)
- ជំនាញក្នុងការថែរក្សាការងារឱ្យបានឋិតថេរ (ការផ្ដោតទៅលើការងារ)

នៅក្នុងការប្រឹក្សាយោបល់ការងារ អ្នកស្វែងរកការងារធ្វើ ត្រូវបានជួយជ្រោមជ្រែងក្នុងការវាយតម្លៃអំពីការលំបាករបស់ខ្លួនក្នុងការស្វែងរកការងារធ្វើ តាមរយៈការកំណត់គោលដៅ និងការបង្កើតនូវ "**ផែនការសកម្មភាព**" ដែលមានលក្ខណៈប្រាកដប្រជាសម្រាប់ស្វែងរកការងារធ្វើសមរម្យ។ "**ផែនការសម្មភាព**" ក៏មានរួមបញ្ចូលនូវរាល់

សកម្មភាព និងបទអន្តរាគមន៍ទាំងឡាយរបស់អ្នកផ្តល់ប្រឹក្សាយោបល់ការងារ ឬសេវារបស់មជ្ឈមណ្ឌលការងារ ឬតាមរយៈភ្នាក់ងារដទៃទៀតនៅក្នុងសហគមន៍ ដើម្បីបង្កើនលទ្ធភាពទទួលបានការងារដល់អ្នកស្វែងរកការងារធ្វើ និងការចូលរួមនៅក្នុងទីផ្សារការងារ។ នៅក្នុងដំណើរការប្រឹក្សាយោបល់ការងារ ក៏រួមមាននូវបទអន្តរាគមន៍ដែលមាននៅក្នុងការប្រឹក្សាយោបល់ដទៃទៀតដែលជាប្រយោជន៍ដល់លទ្ធភាពក្នុងការទទួលបានការងារធ្វើរួមមាន៖ **កត្តាផ្ទាល់ខ្លួន** ដូចជាការសម្របខ្លួនទៅនឹងបរិស្ថានជុំវិញ ការថែទាំកុមារ និងការធ្វើដំណើរជាដើម **ការជ្រើសមុខរបរ** (មានគោលដៅការងារច្បាស់លាស់) **ជំនាញ និងលក្ខខណ្ឌក្នុងការបំពេញការងារ ជំនាញក្នុងការស្វែងរកការងារធ្វើ** និង**សមត្ថភាពក្នុងការថែរក្សាការងារឱ្យបានឋិតថេរ** (ឥរិយាបថក្នុងការទំនាក់ទំនងជាមួយអ្នកដទៃ ជំនាញទន់ដែលបំពេញបន្ថែមដល់ជំនាញបច្ចេកទេស)។

**ការពន្យល់អំពីតម្រូវការនៅក្នុងការប្រឹក្សាយោបល់ការងារ**

**ទំព័របង្ហាញទី ១.៤**

ការប្រឹក្សាយោបល់ការងារបានជួយដល់អ្នកស្វែងរកការងារធ្វើ តាមរយៈការផ្តល់ដំបូន្មាន និងព័ត៌មានផ្សេងៗ ដូចជា៖

- ឱកាសការងារ និងប្រភពព័ត៌មានដទៃទៀត
- បណ្តាញទំនាក់ទំនងក្រៅផ្លូវការ
- ចរិកលក្ខណៈបុគ្គលទៅនឹងតម្រូវការការងារ
- តម្រូវការសិក្សា និងការបណ្តុះបណ្តាលក្នុងការឆ្ពោះទៅកាន់កម្រិតការងារ
- សក្តានុពលនៅក្នុងការបណ្តុះបណ្តាលតាមរយៈការអនុវត្តការងារប្រចាំថ្ងៃ
- សេចក្តីរំពឹងទុករបស់និយោជក និងតម្រូវការជំនាញនៅក្នុងមុខរបរណាមួយ
- កម្មវិធីជួយស្វែងរកការងារធ្វើនៅក្នុងសហគមន៍
- ព័ត៌មានស្តីអំពីការស្វែងរកការងារធ្វើ
- វិធីសាស្ត្រ និងទីកន្លែងដែលនាំទៅកាន់ការទទួលបានការងារធ្វើ
- ការពិពណ៌នាពីមុខតំណែង (ចំណាត់ថ្នាក់មុខរបរ និងនិយមន័យជាដើម)
- បញ្ជីរាយនាមមុខវិជ្ជាសិក្សា និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ឱកាសក្នុងការប្រកបមុខរបរដោយខ្លួនឯង
- ជំនាញក្នុងការថែរក្សាការងារឱ្យបានឋិតថេរ

# លំហាត់ទី ១.៣
# ចែករំលែកព័ត៌មានអំពីមជ្ឈមណ្ឌលការងាររបស់ខ្លួន

## ក្រុមពិភាក្សា

ហេតុអ្វីបានជាមានការផ្តល់ប្រឹក្សាយោបល់ការងារដល់ទៅ ៩៥% នៅក្នុងប្រទេសដែលមានទីផ្សារការងារក្រៅប្រព័ន្ធទៅវិញ?

- ទាញយកចំលើយពីក្រុមពិភាក្សានីមួយៗ។
- ការរំលឹកឡើងវិញនូវចំណុចដែលមានក្នុង **ទំព័របង្ហាញទី ១.៤** ស្តីអំពីអត្ថប្រយោជន៍នៃសេវាប្រឹក្សាយោបល់ការងារ។
- ចែកជូនឯកសារ **ឯកសារទី ១.១** (Handout 1.1) ដោយធ្វើការរំលឹកឡើងវិញអំពីចំណុចសំខាន់ៗ និងស្នើឱ្យសិក្ខាកាមទាំងអស់ផ្តល់នូវឧទាហរណ៍ដោយផ្អែកលើបទពិសោធន៍ការងារនៅមជ្ឈមណ្ឌលការងាររបស់ខ្លួន។

## ឯកសារទី ១.១ (Handout 1.1)

## សេវាការងារនៅប្រទេសកម្ពុជា: បញ្ហាប្រឈម និងភាពសុទិដ្ឋិនិយម

ហេតុអ្វីបានជាមានការប្រឹក្សាយោបល់ការងារដល់ទៅ ៩៥% នៅក្នុងប្រទេសដែលមានទីផ្សារការងារក្រៅប្រព័ន្ធទៅវិញ?

- ឱកាសការងារមាននៅក្នុងវិស័យជាច្រើន ទោះបីជាសេដ្ឋកិច្ចប្រទេសកម្ពុជាទាំងមូលមិនបានបង្កើតការងារឱ្យបានគ្រប់គ្រាន់ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ស្រទាប់យុវជនដែលទើបឈានចូលប្រឡូកនៅក្នុងទីផ្សារការងារ។ ជ្រុងមួយនៃបញ្ហានេះ គឺយុវជនទាំងនោះមិនមានប្រភពព័ត៌មានក្នុងការស្វែងរកការងារធ្វើ។
- បណ្តាញព័ត៌មានដែលនិយាយពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត កំពុងពេញនិយមនៅក្នុងប្រទេសកម្ពុជារួមមាន: វិស័យកាត់ដេរ និងសំណង់ ដែលកម្មករក្មេងៗជាច្រើនបានធ្វើការទំនាក់ទំនងគ្នា ឬមកពីភូមិ ឬស្រុកជាមួយគ្នា។
- ទោះបីជាយ៉ាងនេះក៏ដោយ ការស្វែងរកការងារធ្វើបានតម្រូវឱ្យមានការរៀបចំជាប្រព័ន្ធ ជាពិសេសចំពោះយុវជនដែលមានក្តីស្រមៃការងារដែលខ្លួនចង់បាន។ ឧទាហរណ៍: និយោជកមានតម្រូវការបុគ្គលិក ឬកម្មករយ៉ាងច្រើន ផ្នែកកែច្នៃផលិតកសិ-ឧស្សាហកម្ម ក៏ប៉ុន្តែឱកាសការងារទាំងនោះមិនអាចទទួលបានដោយស្វ័យប្រវត្តិនោះទេ។ ទន្ទឹមនឹងនេះ ក៏មានប្រព័ន្ធខ្លះដែលតម្រូវឱ្យធ្វើការផ្គូផ្គងអ្នកស្វែងរកការងារធ្វើទៅនឹងការងារដែលមានសក្តានុពល(ការងារដែលមានមុខតំណែង និងប្រាក់បៀវត្សខ្ពស់)។
- កម្រិតការសិក្សាអប់រំ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលទៅកាន់កម្រិតការងារណាមួយ ហេតុដូចនេះអ្នកស្វែងរកការងារធ្វើត្រូវធ្វើការស្វែងយល់ឱ្យបានច្បាស់លាស់អំពីលក្ខខណ្ឌនៃការសិក្សាអប់រំ ឬការបណ្តុះបណ្តាលចំពោះការជ្រើសរើសមុខរបរ ឬអាជីពរបស់ខ្លួន។
- ចំពោះលោកអ្នកដែលពុំបានឆ្លងកាត់ការសិក្សាអប់រំ ឬពុំមានជំនាញដូចជាអ្នករត់តុ និងកម្មករកាត់ដេរបានសិក្សាជំនាញរបស់ខ្លួនតាមរយៈការអនុវត្តការងារប្រចាំថ្ងៃ ដែលមិនមែនជាផ្នែកនៃការសិក្សាអប់រំ ឬការបណ្តុះបណ្តាលដែលបានរៀបចំនោះទេ។
- ការផ្សព្វផ្សាយព័ត៌មានជ្រើសរើសបុគ្គលិកនៅលើសារព័ត៌មាន Cambodia Daily ជាភាសាអង់គ្លេសមានន័យថាជំនាញភាសាអង់គ្លេសត្រូវបានរួមបញ្ចូល (មានន័យថាអ្នកស្វែងរកការងារធ្វើមានចំណេះដឹងភាសាអង់គ្លេសគ្រប់គ្រាន់) រីឯលក្ខខណ្ឌការងាររួមមានកម្រិតបរិញ្ញាបត្រ និងបទពិសោធន៍ការងារ គឺជាកត្តាដែលមិនប្រែប្រួល។
- ទោះបីជាយ៉ាងនេះក៏ដោយ នៅក្នុងសភាពជាក់ស្តែងយុវជន និងយុវនារីដែលរស់នៅតាមទីជនបទ និងនៅទីក្រុងដែលអាចចូលប្រឡូកនៅក្នុងទីផ្សារការងារបាន អ្នកទាំងនោះបានសិក្សាជំនាញរបស់ខ្លួនតាមរយៈ

ការអនុវត្តការងារប្រចាំថ្ងៃ។ ទន្ទឹមនឹងនេះ យើងសង្កេតឃើញថាមិនមានយន្តការកែសម្រួលនៅក្នុងទីផ្សារការងារសម្រាប់អ្នកទាំងនោះទេ រួមមានការប្រឹក្សាយោបល់ការងារ ការផ្តល់ព័ត៌មាន ការផ្តល់ដំបូន្មានការងារ ការអប់រំ និងបញ្ជីរាយឈ្មោះវគ្គបណ្តុះបណ្តាល ក៏ដូចជាការបណ្តុះបណ្តាលអំពីការប្រើប្រាស់នូវវិធីសាស្ត្រទាំងនោះ។ ម្យ៉ាងវិញទៀត មិនមានប្រព័ន្ធផ្លូវការ ឬក្រៅផ្លូវការណាមួយដែលអប់រំអំពីដំណាក់កាលអន្តកាលរវាងការសិក្សា និងការងារនោះទេ។ យុវជនទាំងនោះបានបញ្ចប់ការសិក្សា ហើយក៏មិនមានបំណងត្រលប់ចូលសាលា ឬសាកលវិទ្យាល័យវិញទេ ហើយក៏មិនរង់ចាំការសិក្សាអំពីមូលដ្ឋានគ្រឹះនៃជំនាញវិជ្ជាជីវៈ ឬបច្ចេកទេស ដើម្បីឱ្យមានចំណេះដឹងគ្រប់គ្រាន់សម្រាប់បំពេញការងារនោះដែរ។ យុវជនទាំងនោះត្រូវការកន្លែងដែលត្រូវទៅ និងមនុស្សនិយាយជាមួយ អ្នកប្រាប់ព័ត៌មាន អ្នកមគ្គុទេសន៍ និងអ្នកជួយជ្រោមជ្រែងក្នុងការបង្កើតឱកាសការងារសម្រាប់ពេលបច្ចុប្បន្ននេះ។

# មេរៀនទី ២

# ដំណើរការទទួលបានសេវារបស់អ្នកស្វែងរកការងារធ្វើ និងការធ្វើបទសម្ភាសន៍កំណត់អំពីតម្រូវការសេវា ( SND )



**គោលបំណង នៃការសិក្សា:**

នៅពេលបញ្ចប់មេរៀនទី ២ នេះ សិក្ខាកាមទាំងអស់នឹង:

- មានការយល់ដឹងអំពីបែបបទនៃការរៀបចំដំណើរនៃការទទួលបាន សេវារបស់អ្នកស្វែងរកការងារធ្វើ
- មានការយល់ដឹងពីវិធីសាស្ត្រក្នុងការធ្វើបទសម្ភាសន៍ដើម្បីកំណត់អំពីតម្រូវការសេវា (SND) ជាមួយអ្នកស្វែងរកការងារធ្វើប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់
- មានការយល់ដឹងអំពីវិធីសាស្ត្រ និងទីកន្លែងដែលត្រូវបញ្ជូនអ្នកស្វែងរកការងារធ្វើបន្ទាប់ពីបានបញ្ចប់ការធ្វើបទសម្ភាសន៍ SND ប្រកបដោយជោគជ័យ
- មានការយល់ដឹងអំពីប្រភេទធនធានដែលអាចផ្តល់ជូនអ្នកស្វែងរកការងារធ្វើ (រួមមានបណ្ណផ្សព្វផ្សាយ និងកូនសៀវភៅណែនាំជាដើម)

**រយៈពេល:** ៣ ម៉ោង

**សេចក្តីសង្ខេប:**

នៅក្នុងមេរៀននេះ

- បទបង្ហាញទី ២.១: សេចក្តីសង្ខេបអំពីការទទួលអតិថិជន និងការធ្វើបទសម្ភាសន៍ SND
- លំហាត់ទី ២.១: ព័ត៌មានរបស់អតិថិជន
- បទបង្ហាញទី២.២: ដំណើរការនៃការទទួលព័ត៌មាន
- លំហាត់ទី២.២:សំនួរដែលអាចចោទសួរដោយអ្នកស្វែងរកការងារធ្វើក្នុងពេលមកកាន់មជ្ឈមណ្ឌលការងារ
- បទបង្ហាញទី២.៣: ដំណើរការនៃការកំណត់អំពីតម្រូវការសេវា SND – ជម្រើសចំនួន ៣ យ៉ាងក្នុងការតាមដាន (Follow-up)
- លំហាត់ទី២.៣: ការយល់ឃើញចំពោះខ្លួនឯង និងរបស់អតិថិជន នៅក្នុងការធ្វើបទសម្ភាសន៍ SND
- បទបង្ហាញទី២.៤: ដំណាក់កាលទាំង ៦ នៅក្នុងការធ្វើបទសម្ភាសន៍ SND
- លំហាត់ទី២.៤: ការអនុវត្តការធ្វើបទសម្ភាសន៍ SND
- ឧបសម្ព័ន្ធទី២.១: ទម្រង់អ្នកស្វែងរកការងារធ្វើ
- ឧបសម្ព័ន្ធទី២.២: ទម្រង់ SND សម្រាប់អ្នកស្វែងរកការងារធ្វើ
- ឧបសម្ព័ន្ធទី២.៣:ចំណេះដឹង និងជំនាញសម្រាប់ធ្វើបទសម្ភាសន៍ SND
- ឧបសម្ព័ន្ធទី២.៤: ទម្រង់សម្រាប់សម្តែងជាអតិថិជន ក្នុងការធ្វើបទសម្ភាសន៍ SND
- ឧបសម្ព័ន្ធទី ២.៥: ទម្រង់ទទួលព័ត៌មានត្រឡប់(Feedback form)
- ឧបសម្ព័ន្ធទី ២.៦: តារាងអ្នកសង្កេតការណ៍



# បទបង្ហាញទី ២.១: សេចក្តីសង្ខេបអំពីការទទួល អតិថិជន និងការធ្វើបទសម្ភាសន៍ SND



**សេចក្តីសង្ខេប : ដំណើរការទទួលសេវា និងការធ្វើបទសម្ភាសន៍ SND**

ដំណើរការទទួលសេវា

- បណ្តុំព័ត៌មាន

⇩

ការធ្វើបទសម្ភាសន៍ SND

⇩

ដំណាក់កាលទាំង ៦

ការបញ្ជូនអតិថិជនជាអ្នកស្វែងរកការងារធ្វើ

**គោលការណ៍នៃការផ្តល់សេវាដែលជួយណែនាំដល់មន្ត្រីមជ្ឈមណ្ឌលការងារ**

- សេវា: ផ្តោតទៅលើអតិថិជនជាចំបង
- សេវា: ផ្អែកទៅលើតម្រូវការអតិថិជន
- អ្នកស្វែងរកការងារធ្វើ: ទទួលបាននូវប្រភេទ/កម្រិតនៃសេវាដែលនឹងត្រូវផ្តល់ជូន
- សេវា: រួមមានបរិស្ថាននៃការផ្តល់ជូនអ្នកស្វែងរកការងារធ្វើ ដើម្បីលើកឡើងអំពីតម្រូវការការងារ និងកម្រិតនៃសេវា ដែលត្រូវការ
- សេវា: ការគោរពដល់សមត្ថភាពរបស់អ្នកស្វែងរកការងារធ្វើ និងស្វ័យភាព(មានសិទ្ធិ)ក្នុងការជ្រើសរើសការងារ ដែលសមស្រប



## លំហាត់ទី ២.១: ព័ត៌មានរបស់អតិថិជន



**រយៈពេល: ៣៥នាទី**

**គោលបំណង:**

- ការពិភាក្សាអំពីប្រភេទព័ត៌មានដែលត្រូវការនៅក្នុងដំណើរការសាកសួរអតិថិជន

**ការណែនាំ:**

១). នៅក្រុមពិភាក្សាដែលមានសមាជិក ០២ រូប ធ្វើការពិភាក្សាអំពីព័ត៌មានទាំងឡាយដែលអ្នកយល់ថាមានអត្ថប្រយោជន៍ ហើយនឹងត្រូវទទួលបានពីអតិថិជននៅក្នុងទម្រង់ទទួលព័ត៌មាន (រយៈពេល ១៥ នាទី)

២). នៅក្នុងក្រុមពិភាក្សាធំ លោកអ្នកត្រូវរាយការណ៍ចម្លើយរបស់ខ្លួន និងធ្វើការពិភាក្សា (រយៈពេល ២០នាទី)



# បទបង្ហាញទី ២.២: ដំណើរការនៃការទទួលបានព័ត៌មាន



## ដំណើរការនៃការទទួលបានព័ត៌មាន

- អ្នកស្វែងរកការងារធ្វើមកដល់មជ្ឈមណ្ឌលការងារ
- អ្នកស្វែងរកការងារធ្វើចុះឈ្មោះជាមួយអ្នកទទួលភ្ញៀវ និងទទួលបានទម្រង់បែបបទដើម្បីបំពេញ
- អ្នកស្វែងរកការងារធ្វើបំពេញទម្រង់បែបបទ និងប្រគល់ជូនអ្នកទទួលភ្ញៀវ (ប្រវត្តិរូបសង្ខេប ប្រសិនបើមានតម្រូវការ)
- អ្នកទទួលភ្ញៀវកំណត់ពេលវេលាក្នុងការធ្វើបទសម្ភាសន៍កំណត់អំពីតម្រូវការរបស់អតិថិជន (SND)

## បណ្ដុំព័ត៌មាន

- ព័ត៌មានទូទៅរបស់អ្នកស្វែងរកការងារធ្វើ
  - ✓ នាមត្រកូល
  - ✓ នាមខ្លួន
  - ✓ អាសយដ្ឋាន
  - ✓ លេខទូរស័ព្ទ
- កម្រិតការសិក្សាអប់រំ និងការបណ្ដុះបណ្ដាលដែលបានបញ្ចប់
  - ✓ កម្រិតការសិក្សាអប់រំដែលបានបញ្ចប់
  - ✓ វគ្គបណ្ដុះបណ្ដាលដែលពាក់ព័ន្ធទៅនឹងការងារដែលបានបញ្ចប់
- បទពិសោធន៍ការងារ
  - ✓ មុខតំណែងដែលធ្លាប់ធ្វើពីមុន
  - ✓ និយោជក
  - ✓ រយៈពេលបម្រើការងារ
  - ✓ ប្រាក់ឈ្នួល/ប្រាក់បៀវត្ស
  - ✓ មូលហេតុនៃការលាឈប់
- គោលដៅការងារ



# លំហាត់ទី ២.២: សំនួរដែលអាចចោទសួរដោយអ្នកស្វែងរកការងារធ្វើក្នុងពេលមកកាន់មជ្ឈមណ្ឌលការងារ



រយៈពេល: ២០ នាទី

គោលបំណង:

- ការកំណត់អំពីសំនួរដែលអាចចោទសួរដោយអ្នកស្វែងរកការងារធ្វើក្នុងពេលមកកាន់មជ្ឈមណ្ឌលការងារ

សេចក្តីណែនាំ:

១. ក្រុមពិភាក្សាដែលមានសមាជិកជាមន្ត្រីមជ្ឈមណ្ឌលការងារចំនួន ០២ នាក់ (រយៈពេល ១០ នាទី)

- កំណត់នូវសំនួរដែលអ្នកស្វែងរកការងារធ្វើអាចនឹងចោទសួរបន្ទាប់ពីបានបំពេញនូវទម្រង់ដែលផ្តល់ជូន
- កំណត់នូវបញ្ហារបស់អ្នកស្វែងរកការងារធ្វើក្នុងការបំពេញទម្រង់ដែលបានផ្តល់ជូន
- ក្នុងនាមជាមន្ត្រីមជ្ឈមណ្ឌលការងារ តើលោកអ្នកឆ្លើយទៅនឹងសំនួរ និងដោះស្រាយបញ្ហាដែលបានលើកឡើងខាងលើយ៉ាងដូចម្តេច?

២. រាយការណ៍ពីចម្លើយរបស់លោកអ្នកនៅក្នុងក្រុមពិភាក្សាធំ (រយៈពេល ១០ នាទី)



# បទបង្ហាញទី ២.៣: ដំណើរការនៃការកំណត់អំពីតម្រូវការសេវា (SND) - ជម្រើសចំនួន ៣ យ៉ាងក្នុងការតាមដាន (Follow-up)



សមាសភាពក្នុងការធ្វើបទសម្ភាសន៍ SND

ដំណាក់កាលទាំង ៦ នៅក្នុងការធ្វើបទសម្ភាសន៍ SND

| | |
|---|---|
| ចំណេះដឹង/ការយល់ដឹង អំពីដំណាក់កាលនីមួយៗ | ជំនាញក្នុងការអនុវត្ត ដំណាក់កាលនីមួយៗ |
| តើអ្វីទៅ? | ធ្វើយ៉ាងដូចម្តេច? |

តើអ្វីទៅ? ⟷ ធ្វើយ៉ាងដូចម្តេច?

ការយល់ដឹងរបស់មន្ត្រីមជ្ឈមណ្ឌលការងារ និងអំពីតួនាទីរបស់អ្នកស្វែងរកការងារធ្វើ / ការយល់ឃើញនៅក្នុងការធ្វើបទសម្ភាសន៍ SND

| | | |
|---|---|---|
| តាមរយៈការមើលឃើញរបស់យើង | តើយើងគិតថាខ្លួនជាមន្ត្រីមជ្ឈមណ្ឌលការងារយ៉ាងដូចម្តេច? | តើយើងគិតចំពោះអតិថិជន: អ្នកស្វែងរកការងារធ្វើយ៉ាងដូចម្តេច? |
| តាមរយៈការមើលឃើញរបស់អតិថិជន | តើអតិថិជនគិតចំពោះខ្លួនឯងយ៉ាងដូចម្តេច? | តើអតិថិជនគិតចំពោះមន្ត្រីមជ្ឈមណ្ឌលការងារយ៉ាងដូចម្តេច? |



# លំហាត់ទី ២.៣: ការយល់ឃើញចំពោះខ្លួនឯង និង របស់អតិថិជននៅក្នុងការធ្វើបទសម្ភាសន៍ SND



រយៈពេល : ៣០នាទី

គោលបំណង :

ក្នុងនាមជាមន្ត្រីមជ្ឈមណ្ឌលការងារត្រូវមានការយល់ដឹងអំពីគំនិតផ្សេងៗរបស់អតិថិជន និងខ្លួនយើងផ្ទាល់ក៏ដូចជាការយល់ឃើញរបស់អតិថិជនចំពោះខ្លួនឯង និងចំពោះមន្ត្រីមជ្ឈមណ្ឌលការងារ។

សេចក្តីណែនាំ :

១. នៅក្នុងក្រុមពិភាក្សាដែលមានសមាជិក ០៣ នាក់ ត្រូវឆ្លើយសំនួរខាងក្រោម និងកត់ត្រាចម្លើយនៅលើក្រដាសធំ (រយៈពេល ១៥ នាទី)៖

- តើយើងគិតថាខ្លួនជាមន្ត្រីមជ្ឈមណ្ឌលការងារយ៉ាងដូចម្តេច? (ឧ: ការផ្តោតទៅលើសេវាជាចំបងប្រកបដោយសីលធម៌វិជ្ជាជីវៈ និងការយល់ចិត្ត)

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

- តើយើងគិតចំពោះអតិថិជនយ៉ាងដូចម្តេច? (ឧ: ការទទួលខុសត្រូវក្នុងការស្វែងរកការងារឱ្យធ្វើការគិតតែទៅលើចំណុចអាក្រក់ និងការមិនសប្បាយចិត្ត)

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

- តើអតិថិជនគិតចំពោះខ្លួនឯងយ៉ាងដូចម្តេច? (ឧ: ជាជនរងគ្រោះពីភាពគ្មានការងារធ្វើការធ្វើពុត)

- តើអតិថិជនគិតចំពោះមន្ត្រីមជ្ឈមណ្ឌលការងារយ៉ាងដូចម្តេច? (ឧ: ការិយាល័យធិបតេយ្យ ឬមិនសូវមានឥទ្ធិពលជាដើម)

២. បង្ហាញពីចម្លើយរបស់លោកអ្នកនៅក្នុងក្រុមពិភាក្សាធំ (រយៈពេល ១៥ នាទី)



## បទបង្ហាញទី ២.៤: ដំណាក់កាលទាំង ៦ នៅក្នុងការធ្វើបទសម្ភាសន៍ SND



ដំណាក់កាលទាំង ៦ ក្នុងការធ្វើបទសម្ភាសន៍ SND រួមមាន៖

១. ការចាប់ផ្តើមធ្វើបទសម្ភាសន៍

២. ការប្រមូលព័ត៌មានសំខាន់ៗ

៣. ការសង្ខេបអំពីតម្រូវការរបស់អតិថិជន/សេវា

៤. ការពិនិត្យទៅលើជម្រើសនៃសេវារបស់មជ្ឈមណ្ឌលការងារ

៥. ការឯកភាពទៅលើដំណាក់កាលបន្ទាប់

៦. ការបំពេញសំណុំឯកសារ

**១. ការចាប់ផ្តើមធ្វើបទសម្ភាសន៍**

- ការសម្តែងការគួរសមចំពោះអតិថិជន
- ការលើកឡើងពីគោលបំណងនៃការធ្វើបទសម្ភាសន៍

**២. ការប្រមូលព័ត៌មានសំខាន់ៗ**

- ការពិនិត្យឡើងវិញនូវទម្រង់ ឬ CV របស់អ្នកស្វែងរកការងារធ្វើ
- ការពិនិត្យទៅលើបណ្តុំព័ត៌មានដែលត្រូវការ
- ការកំណត់ចំពោះអតិថិជនដែលមានការងារហើយ និងធ្វើការចុះឈ្មោះសម្រាប់និយោជកថ្មីរបស់ខ្លួនប៉ុណ្ណោះ។ ប្រសិនជាដូច្នេះ ដំណើរការ SND ត្រូវបានបញ្ចប់សម្រាប់អតិថិជននេះ

## ២. ការប្រមូលព័ត៌មានសំខាន់ៗ (ត)

- តើមានគោលដៅការងារច្បាស់លាស់ដែរឬទេ?
  - តើត្រូវការជំនួយក្នុងការកំណត់គោលដៅការងារដែរឬទេ?
  - តើមានជំនាញការងារចាំបាច់សម្រាប់គោលដៅការងារដែរឬទេ?
  - តើត្រូវការជំនួយក្នុងការកំណត់អំពីការបណ្ដុះបណ្ដាល/ការសិក្សា ដើម្បីទទួលបាននូវជំនាញការងារ/តម្រូវការផ្សេងៗដែរឬទេ?

## ២. ការប្រមូលព័ត៌មានសំខាន់ៗ (ត)

- តើមានជំនាញស្វែងរកការងារធ្វើ ដើម្បីទទួលបានការងារដែរឬទេ?
  - តើត្រូវការជំនួយក្នុងការអភិវឌ្ឍជំនាញស្វែងរកការងារធ្វើឱ្យកាន់តែប្រសើរដែរឬទេ?
- តើមានសមត្ថភាពក្នុងការថែរក្សាការងារឱ្យបានឋិតថេរដែរឬទេ?
  - តើត្រូវការជំនួយក្នុងការអភិឌ្ឍជំនាញថែរក្សាការងារឱ្យបានឋិតថេរ/ឥរិយាបថដែរឬទេ?

## ២. ការប្រមូលព័ត៌មានសំខាន់ៗ (ត)

- តើមានការគាំទ្រពីបុគ្គលខ្លួនឯង/ក្រុមគ្រួសារ/សហគមន៍ ដើម្បីទទួលបានការងារធ្វើ( ឧ: ការថែទាំកុមារ )ដែរឬទេ
  - តើត្រូវការជំនួយក្នុងការបង្កើតការគាំទ្រទាំងនេះដែរឬទេ?

**៣. សេចក្ដីសង្ខេបអំពីតម្រូវការរបស់អតិថិជន/សេវា**

- សេចក្ដីសង្ខេប និងការឯកភាពជាមួយអតិថិជនអំពីតម្រូវការចាំបាច់ ដើម្បីឱ្យមានការងារធ្វើឡើងវិញ (ដូចមាននៅក្នុងចំណុចទី ២)
- ការកំណត់ចំពោះអតិថិជនដែលមានការងារធ្វើដោយមិនត្រូវការសេវាផ្ដល់

**៤. ការពិនិត្យទៅលើជម្រើសនៃសេវារបស់មជ្ឈមណ្ឌលការងារ**

- ការពិនិត្យឡើងវិញទៅលើជម្រើសនៃសេវារបស់មជ្ឈមណ្ឌលការងារ
- ការជួយជ្រោមជ្រែងដល់អតិថិជនក្នុងការសម្រេចចិត្តជ្រើសរើសយកសេវាណាមួយ
- ការណែនាំអតិថិជនទៅកាន់សេវាអាទិភាពណាមួយ

**៥. ការឯកភាពទៅលើជំណាក់កាលបន្ទាប់**

- កាគូសបញ្ជាក់អំពីជំណាក់កាលបន្ទាប់ដែលអតិថិជនត្រូវ:
  - ✓ ស្វែងរកការងារធ្វើដោយខ្លួនឯង ឬប្រើប្រាស់នូវទិន្នន័យការងាររបស់មជ្ឈមណ្ឌលការងារ ឬ
  - ✓ ណែនាំទៅកាន់សេវាប្រឹក្សាយោបល់ការងារ
- ពិនិត្យទៅលើការតាំងចិត្តរបស់អតិថិជន

**៦. ការបំពេញសំណុំឯកសារ**

- ការបំពេញរបាយការណ៍ទៅក្នុងកំព្យូទ័រស្ដីពីការធ្វើបទសម្ភាសន៍ SND
- ធ្វើការបំពេញផ្នែកបញ្ជូននៃរបាយការណ៍ទៅក្នុងកំព្យូទ័រស្ដីពីការធ្វើបទសម្ភាសន៍ SND ដូចដែលបានតម្រូវឱ្យ



# លំហាត់ទី ២.៤: ការអនុវត្តការធ្វើបទសម្ភាសន៍ SND



**រយៈពេល : ៨០នាទី**

**គោលបំណង :**

- ផ្តល់ឱកាសដល់សិក្ខាកាមទាំងអស់ក្នុងការអនុវត្ត និងការសង្កេតអំពីការធ្វើបទសម្ភាសន៍ SND

**សេចក្តីណែនាំ :**

១. អ្នកផ្តល់ការបណ្តុះបណ្តាលនឹងបង្ហាញជូនអំពីវិធីសាស្ត្រធ្វើបទសម្ភាសន៍ SND។ មុននឹងធ្វើការបង្ហាញជូន សិក្ខាកាមទាំងអស់ត្រូវបានណែនាំឱ្យប្រើប្រាស់នូវទម្រង់ទទួលព័ត៌មានត្រលប់ (Feedback form) និងស្នើឱ្យធ្វើការកត់ត្រាអំពីការធ្វើបទសម្ភាសន៍ SND ដែលបានអនុវត្ត។ បន្ទាប់ពីបានបង្ហាញជូន អ្នកផ្តល់ការបណ្តុះបណ្តាលនឹងជួយសម្របសម្រួលការពិភាក្សាអំពីចំណុចខ្លាំង និងចំណុចនានាដែលធ្វើឱ្យបទសម្ភាសន៍ SND មានប្រសិទ្ធភាព (រយៈពេល ៣០ នាទី)។

២. ធ្វើការបែងចែកជាក្រុមពិភាក្សាដែលមានសមាជិក ៣ នាក់ ហើយផ្លាស់ប្តូរគ្នាសម្តែង (រយៈពេល ៦០ នាទី) រួមមាន:

- មន្ត្រីមជ្ឈមណ្ឌលការងារ
- អតិថិជន
- អ្នកសង្កេតការ

(ជាដំបូង សមាជិកនៅក្នុងក្រុមពិភាក្សានីមួយៗត្រូវបំពេញទម្រង់សម្តែងជាអតិថិជនជាមុនសិន (ឧបសម្ព័ន្ធទី ២.៤) ដែលជួយណែនាំក្នុងការសម្តែងជាអតិថិជន ឬអ្នកស្វែងរកការងារធ្វើ។ ចំពោះការអនុវត្តការធ្វើបទសម្ភាសន៍នីមួយៗត្រូវមានរយៈពេល ១០ - ១៥ នាទី ដែលក្នុងនោះអ្នកសង្កេតការនឹងធ្វើការកត់ត្រាដោយប្រើប្រាស់នូវទម្រង់ទទួលព័ត៌មានត្រលប់ដែលមាននៅក្នុងឧបសម្ព័ន្ធទី ២.៥ ។ ចំពោះសិក្ខាកាមដែលសម្តែងជាមន្ត្រីមជ្ឈមណ្ឌលការងារនឹងត្រូវប្រើប្រាស់នូវទម្រង់ធ្វើបទសម្ភាសន៍ SND ដែលមាននៅក្នុងឧបសម្ព័ន្ធទី ២.២ ។ បន្ទាប់ពីបានអនុវត្តការធ្វើបទសម្ភាសន៍រួចមក អ្នកសង្កេតការនឹងផ្តល់នូវព័ត៌មានត្រលប់ទៅកាន់សមាជិកក្រុមទាំង ០២ នាក់របស់ខ្លួន (រយៈពេល ៤០ នាទី)។

៣. ជ្រើសរើសអ្នកនាំពាក្យមួយរូប ដើម្បីរាយការណ៍អំពីការអនុវត្តការធ្វើបទសម្ភាសន៍នៅក្នុងក្រុមពិភាក្សាធំ ។ បន្ទាប់មកអ្នកផ្តល់ការបណ្តុះបណ្តាលនឹងកោះហៅ ២ ឬ ៣ ក្រុមឱ្យធ្វើការសម្តែងអំពីការធ្វើបទសម្ភាសន៍ SND របស់ខ្លួនឡើងវិញ(រយៈពេល ៤០ នាទី)។

# ឧបសម្ព័ន្ធទី ២.១
# ទម្រង់អ្នកស្វែងរកការងារធ្វើ

## ព័ត៌មានទូទៅ

នាមត្រកូល: ______________________ នាមខ្លួន: ______________________

អាសយដ្ឋាន: ______________________________________________

លេខទូរស័ព្ទ: ______________________

## ការសិក្សាអប់រំ និងការបណ្តុះបណ្តាលដែលបានបញ្ចប់ :

កម្រិតការសិក្សាអប់រំ

______________________________________________

______________________________________________

វគ្គសិក្សាទាក់ទងទៅនឹងការងារ

______________________________________________

______________________________________________

## បទពិសោធន៍ការងារ

| | ការងារទី ១ | ការងារទី ២ | ការងារទី ៣ |
|---|---|---|---|
| មុខតំណែង | | | |
| ឈ្មោះនិយោជក | | | |
| រយៈពេលបម្រើការងារ | | | |
| ប្រាក់ឈ្នួល/ ប្រាក់បៀវត្ស | | | |
| មូលហេតុនៃការបោះបង់ការងារ | | | |

## គោលដៅការងារ

______________________________________________

______________________________________________

______________________________________________

តើប្រវត្តិរូបសង្ខេបរបស់អតិថិជនមានភ្ជាប់មកជាមួយដែរឬទេ ? ☐ មាន ☐ មិនមាន

# ឧបសម្ព័ន្ធទី ២.២
# ទម្រង់ SND សម្រាប់អ្នកស្វែងរកការងារធ្វើ

១. អតិថិជនមានគោលដៅការងារច្បាស់លាស់: ☐ មាន ☐ មិនមាន

១.១ បើមាន សូមបញ្ជាក់:

---

១.២ បើមិនមាន អតិថិជនត្រូវការជំនួយ: សូមបញ្ជាក់:

---

២. អតិថិជនមានជំនាញការងារដើម្បីសម្រេចគោលដៅការងារ: ☐ មាន ☐ មិនមាន

២.១ បើមាន សូមបញ្ជាក់:

---

២.២ បើមិនមាន អតិថិជនត្រូវការជំនួយ: សូមបញ្ជាក់:

---

៣. អតិថិជនមានជំនាញស្វែងរកការងារធ្វើគ្រប់គ្រាន់: ☐ មាន ☐ មិនមាន

៣.១ បើមាន សូមបញ្ជាក់:

---

៣.២ បើមិនមាន អតិថិជនត្រូវការជំនួយ: សូមបញ្ជាក់:

---

៤. អតិថិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរក្សាការងារឱ្យបានឋិតថេរ ☐ មាន ☐ មិនមាន
(ឧទា: បុគ្គលខ្លួនឯង / ក្រុមគ្រួសារ/ ការយកចិត្តទុកដាក់គាំទ្រជាសំខាន់)

៤.១ បើមាន សូមបញ្ជាក់:

---

៤.២ បើមិនមាន អតិថិជនត្រូវការជំនួយ: សូមបញ្ជាក់:

---

៥. សកម្មភាពក្នុងការតាមដាន (Follow-up) នៃការធ្វើបទសម្ភាសន៍ SND

៥.១ អតិថិជនដែលមានការងាររួចហើយ: មិនត្រូវការជំនួយនាថ្ងៃអនាគត ☐ មាន ☐ មិនមាន

៥.២ អតិថិជនត្រូវបានណែនាំទៅកាន់ទិន្នន័យការងារ/សរសេរនៅលើឯកសាររបស់មជ្ឈមណ្ឌលការងារ ☐ មាន ☐ មិនមាន

៥.៣ អតិថិជនត្រូវបានណែនាំទៅកាន់សេវាប្រឹក្សាយោបល់ការងារ ☐ មាន ☐ មិនមាន

សូមបញ្ជាក់អំពីចំណុចអាទិភាព:

---

# ឧបសម្ព័ន្ធទី ២.៣

## ចំណេះដឹង និងជំនាញសម្រាប់ធ្វើបទសម្ភាសន៍ SND

| ដំណាក់កាល | ចំណេះដឹង | ជំនាញ |
|---|---|---|
| ការចាប់ផ្តើមធ្វើបទសម្ភាសន៍ | | |
| ការប្រមូលព័ត៌មានសំខាន់ៗ | | |
| ការសង្ខេបអំពីតម្រូវការអតិថិជន/សេវា | | |
| ការពិនិត្យទៅលើសេវារបស់មជ្ឈមណ្ឌលការងារ | | |
| ការឯកភាពទៅលើដំណាក់កាលបន្ទាប់ | | |
| ការបំពេញសំណុំឯកសារ | | |

ឧ: អាចធ្វើការរួមបញ្ចូលនូវ:

- តើអ្វីទៅជាគោលដៅការងារច្បាស់លាស់?
- តើត្រូវមានជំនាញការងារអ្វីខ្លះដើម្បីសម្រេចបាននូវគោលដៅការងារ?

អាចរួមបញ្ចូលនូវ:

- សួរសំនួរច្បាស់លាស់
- ការបកស្រាយ
- ការសង្ខេប
- ជំនាញដែលបានទទួលការបណ្តុះបណ្តាលជាដើម

# ឧបសម្ព័ន្ធទី ២.៤
# ទម្រង់សម្តែងជាអតិថិជនក្នុងការធ្វើបទសម្ភាសន៍ SND

មុននឹងធ្វើការសម្តែងជាអតិថិជនដែលមាននៅក្នុងលំហាត់ទី ៣.៦ ស្តីពីការអនុវត្តការធ្វើបទសម្ភាសន៍ SND សិក្ខាកាមគ្រប់រូបត្រូវកំណត់តួសម្តែងរបស់ខ្លួនដោយប្រើប្រាស់នូវទម្រង់ដែលមានដូចខាងក្រោម។

**ព័ត៌មានរបស់អតិថិជនៈ**

១. ឈ្មោះ :

________________________________________

២. កម្រិតការសិក្សា/វគ្គបណ្តុះបណ្តាលដែលបានបញ្ចប់ៈ

________________________________________

________________________________________

៣. បទពិសោធន៍ការងារៈ

ការងារទី១: ______________ ចំនួនឆ្នាំដែលបានបំពេញ ________

ការងារទី២: ______________ ចំនួនឆ្នាំដែលបានបំពេញ ________

ការងារទី៣: ______________ ចំនួនឆ្នាំដែលបានបំពេញ ________

ការងារទី៤: ______________ ចំនួនឆ្នាំដែលបានបំពេញ ________

៤. មូលហេតុនៃការលាឈប់ពីការងារចុងក្រោយៈ

________________________________________

៥. តើមានគោលដៅការងារដែរឬទេ ? ☐ មាន ☐ មិនមាន

បើមាន តើជាអ្វីទៅ ?

________________________________________

បើមិនមាន តើហេតុអ្វី ?

________________________________________

៦. តើមានជំនាញការងារគ្រប់គ្រាន់ដែរឬទេ ? ☐ មាន ☐ មិនមាន

បើមាន តើជាអ្វីទៅ ?

________________________________________

បើមិនមាន តើហេតុអ្វី ?

________________________________________

៧. តើមានជំនាញក្នុងការស្វែងរកការងារធ្វើដែរឬទេ ? ☐ មាន ☐ មិនមាន

បើមាន តើជាអ្វីទៅ ?

________________________________________

បើមិនមាន តើជំនាញស្វែងរកការងារធ្វើមានកម្រិតណា ?

________________________________________

៨. តើមានសមត្ថភាពក្នុងការថែរក្សាការងារដែរឬទេ ? ☐ មាន ☐ មិនមាន

បើមាន តើជាអ្វីទៅ ?

________________________________________

បើមិនមាន តើសមត្ថភាពកម្រិតណាសម្រាប់ថែរក្សាការងារឱ្យបានឋិតថេរ ?

________________________________________

# ឧបសម្ព័ន្ធទី ២.៥

# ទម្រង់ទទួលព័ត៌មានត្រលប់ ( Feedback form )

## សេចក្តីណែនាំចំពោះការផ្តល់ និងការទទួលព័ត៌មានត្រលប់

ការផ្តល់ព័ត៌មានត្រលប់:

- ការផ្តោតទៅលើបញ្ហាពាក់ព័ន្ធ
- ការពិពណ៌នា និងការវាយតម្លៃ
- ការផ្តោតលើការងារ ( កិច្ចការ ) ដែលអាចផ្លាស់ប្តូរបាន
- ការងារដែលអាចអនុវត្តទៅបាន
- ការចែករំលែកនូវព័ត៌មាន

ប្រការដែលគួរធ្វើ:

- មានភាពប្រាកដនិយម (ផ្ទុយទៅនឹងលក្ខណៈទូទៅ)
- ការយល់ដឹងពីអារម្មណ៍របស់អតិថិជនបានឆាប់រហ័ស
- ការប្រើប្រាស់នូវវិធីសាស្ត្រស្ទាបស្ទង់ ( មិនទាន់មានភាពប្រាកដប្រជា ឬដាច់ខាត )
- ការផ្តោតទៅលើឥរិយាបថដែលអាចផ្លាស់ប្តូរបាន
- ការប្រើប្រាស់នូវគោលការណ៍ជាក់ស្តែង ( តាមដែលអាចធ្វើទៅបាន )
- ការផ្តល់ព័ត៌មានត្រឡប់របស់លោកអ្នកត្រូវប្រកបទៅដោយឥរិយាបថគាំទ្រ

ប្រការដែលមិនគួរធ្វើ:

- ធ្វើការផ្លាស់ប្តូរតាមចំណង់ ឬតម្រូវការរបស់ខ្លួន
- ការដាក់បន្ទុកធ្ងន់ធ្ងរ (ត្រូវមានកិច្ចការ ឬមួយចំណុចនៅក្នុងពេលតែមួយ)
- ភ្លេចស្តាប់អតិថិជន
- ប្រើពាក្យចំអកឡកឡឺយ បញ្ឈឺចិត្ត និងការបន្ទុះបង្អាប់
- ភ្លេចផ្តល់នូវព័ត៌មានត្រលប់ដែលមានលក្ខណៈវិជ្ជមាន
- ធ្វើឱ្យអតិថិជន " ទាល់ច្រក "

ការទទួលព័ត៌មានត្រលប់

- កាត់បន្ថយនូវកត្តាដែលរំខានដល់អារម្មណ៍របស់លោកអ្នកក្នុងការទទួលព័ត៌មានត្រលប់
- បញ្ជាក់ឱ្យបានច្បាស់លាស់អំពីព័ត៌មានត្រលប់ដែលលោកអ្នកចង់បាន
- ពិចារណា ឬពិនិត្យទៅលើចំណុចដែលលោកអ្នកបានស្តាប់ឮ
- ចែករំលែកនូវចម្លើយរបស់លោកអ្នកទៅលើព័ត៌មានត្រលប់

# ឧបសម្ព័ន្ធទី ២.៦

# តារាងអ្នកសង្កេតការណ៍

| ដំណាក់កាល | ការសង្កេតការណ៍ |
|---|---|
| **១. ការចាប់ផ្តើមធ្វើបទសម្ភាសន៍**<br>• ការសម្តែងការគួរសមចំពោះអតិថិជន<br>• ការលើកឡើងពីគោលបំណងនៃការធ្វើបទសម្ភាសន៍<br>**២. ការប្រមូលព័ត៌មានសំខាន់ៗ**<br>• ការពិនិត្យឡើងវិញនូវទម្រង់ ឬ CV របស់អ្នកស្វែងរកការងារធ្វើ<br>• ការពិនិត្យទៅលើបណ្តុំព័ត៌មានដែលត្រូវការ<br>• ការកំណត់ចំពោះអតិថិជនដែលមានការងារធ្វើ និងធ្វើការចុះឈ្មោះសម្រាប់និយោជកថ្មីរបស់ខ្លួនប៉ុណ្ណោះ។ ប្រសិនជាដូច្នេះ ដំណើរការ SND ត្រូវបានបញ្ចប់សម្រាប់អតិថិជននេះ<br>• តើមានគោលដៅការងារច្បាស់លាស់ដែរឬទេ? តើត្រូវការជំនួយក្នុងការកំណត់គោលដៅការងារដែរឬទេ?<br>• តើមានជំនាញការងារចាំបាច់សម្រាប់គោលដៅការងារដែរឬទេ? តើត្រូវការជំនួយក្នុងការកំណត់អំពីការបណ្តុះបណ្តាល/ ការសិក្សាអប់រំ ដើម្បីទទួលបាននូវជំនាញការងារ/ តម្រូវការផ្សេងៗដែរឬទេ?<br>• តើមានជំនាញស្វែងរកការងារធ្វើ ដើម្បីទទួលបានការងារដែរឬទេ? តើត្រូវការជំនួយក្នុងការអភិវឌ្ឍជំនាញស្វែងរកការងារធ្វើឱ្យកាន់តែប្រសើរដែរឬទេ?<br>• តើមានសមត្ថភាពក្នុងការថែរក្សាការងារឱ្យបានឋិតថេរដែរឬទេ? តើត្រូវការជំនួយក្នុងការអភិវឌ្ឍជំនាញថែរក្សា ការងារ/ឥរិយាបថដែរឬទេ?<br>• តើមានការគាំទ្រពីបុគ្គលខ្លួនឯង/ក្រុមគ្រួសារ/ សហគមន៍ ដើម្បីទទួលបានការងារធ្វើ( ឧ: ការថែទាំកុមារ) ដែរឬទេ? តើត្រូវការជំនួយក្នុងការបង្កើតការគាំទ្រទាំងនេះដែរឬទេ? | |

| ដំណាក់កាល | ការសង្កេតការណ៍ |
|---|---|
| **៣. សេចក្ដីសង្ខេបអំពីតម្រូវការរបស់អតិថិជន/សេវា**<br>• សេចក្ដីសង្ខេប និងការព្រមព្រៀងជាមួយអតិថិជនអំពីតម្រូវការដែលអតិថិជនត្រូវការ ដើម្បីមានការងារធ្វើឡើងវិញ (ដូចមាននៅក្នុងចំណុចទី ២)<br>• ការកំណត់ចំពោះអតិថិជនដែលមានការងារធ្វើ ដោយមិនត្រូវការសេវាផ្ទួផ្ទង<br>**៤. ការពិនិត្យទៅលើជម្រើសនៃសេវារបស់មជ្ឈមណ្ឌលការងារ**<br>• ការពិនិត្យឡើងវិញទៅលើជម្រើសសេវារបស់មជ្ឈមណ្ឌលការងារ<br>• ការជួយដល់អតិថិជនក្នុងការសម្រេចចិត្តជ្រើសរើសយកសេវាណាមួយ<br>• ការណែនាំអតិថិជនទៅកាន់សេវាអាទិភាពណាមួយ<br>**៥. ការឯកភាពទៅលើដំណាក់កាលបន្ទាប់**<br>• ការគូសបញ្ជាក់អំពីដំណាក់កាលបន្ទាប់ដែលអតិថិជនត្រូវ:<br>- ស្វែងរកការងារធ្វើដោយខ្លួនឯង ឬប្រើប្រាស់នូវទិន្នន័យការងាររបស់មជ្ឈមណ្ឌលការងារ ឬ<br>- ណែនាំទៅកាន់សេវាប្រឹក្សាយោបល់ការងារ<br>• ពិនិត្យទៅលើការតាំងចិត្តរបស់អតិថិជន<br>**៦. ការបំពេញសំណុំឯកសារ**<br>• ការបំពេញរបាយការណ៍ទៅក្នុងកំព្យូទ័រអំពីការធ្វើបទសម្ភាសន៍ SND<br>• ធ្វើការបំពេញផ្នែកបញ្ជូននៃរបាយការណ៍ទៅក្នុងកុំព្យូទ័រអំពីការធ្វើបទសម្ភាសន៍ SND ដូចដែលបានតម្រូវឱ្យ | |

# មេរៀនទី ៣

# ការបង្កើតទម្រង់គំរូនៃលទ្ធភាពទទួលបានការងារធ្វើ និងភាពគ្រប់គ្រាន់សម្រាប់អ្នកប្រើប្រាស់សេវា



**គោលបំណងនៃការសិក្សា:** នៅពេលបញ្ចប់មេរៀនទី ៣ នេះ សិក្ខាកាមទាំងអស់នឹង:

- យល់ដឹងអំពីកត្តាដែលជះឥទ្ធិពលដល់លទ្ធភាពក្នុងការទទួលបានការងារធ្វើ
- យល់ដឹងអំពីទម្រង់គំរូនៃលទ្ធភាពទទួលបានការងារធ្វើ និងសមត្ថភាពគ្រប់គ្រាន់របស់អ្នកប្រើប្រាស់សេវា រួមមាន ៥ ចំណុចសំខាន់ : ការគ្រប់គ្រងខ្លួនឯង ការសម្រេចចិត្តក្នុងការចាប់យកអាជីព ការពង្រឹងជំនាញ ការស្វែងរកការងារធ្វើ និងការថែរក្សាការងារឱ្យបានឋិតថេរ
- មានលទ្ធភាពពន្យល់អំពីទម្រង់គំរូនៃលទ្ធភាពទទួលបានការងារធ្វើទៅនឹងស្ថានភាពជាក់ស្តែងនៅក្នុងទីផ្សារការងារ
- មានលទ្ធភាពកំណត់អំពីដំណាក់កាលសំខាន់ៗនៅក្នុងដំណាក់កាលអន្តរកាលទៅនឹងការងារ
- យល់ដឹងអំពីដំណើរការដែលអ្នកប្រើប្រាស់សេវាត្រូវបានជួយជ្រោមជ្រែងក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងការទទួលបាននូវជំនាញដែលអ្នកទាំងនោះអាចទាញជាប្រយោជន៍ក្នុងការចាប់យកឱកាសការងារដូចដែលបានគ្រោងទុក

**រយៈពេល:** ៣ ម៉ោង

**សេចក្តីសង្ខេប:** នៅក្នុងមេរៀននេះ

- បទបង្ហាញទី៣.១: កត្តាដែលជះឥទ្ធិពលដល់លទ្ធភាពទទួលបានការងារធ្វើ
- បទបង្ហាញទី៣.២: ការបង្កើតទម្រង់គំរូដើម្បីធ្វើឱ្យលទ្ធភាពទទួលបានការងារធ្វើមានភាពល្អប្រសើរ
- បទបង្ហាញទី៣.៣: ដំណាក់កាលអន្តរកាលទៅកាន់ពិភពការងារ និងចំណុចទាំង ៥ យ៉ាង ដែលមាននៅក្នុងលទ្ធភាពទទួលបាន ការងារធ្វើ
- លំហាត់ទី៣.១: កំណត់បញ្ហាគន្លឹះដែលពាក់ព័ន្ធទៅនឹងទម្រង់គំរូនៃលទ្ធភាពទទួលបានការងារធ្វើ និងភាពគ្រប់គ្រាន់របស់អតិថិជននៅក្នុងទីផ្សារការងារនៅក្នុងប្រទេសកម្ពុជា
- ឧបសម្ព័ន្ធទី៣.១: សំនួរជ្រើសរើស **ត្រូវ** ឬ**ខុស** ស្តីអំពីស្ថានភាពជាក់ស្តែងនៅក្នុងទីផ្សារការងារនៅប្រទេសកម្ពុជា
- ឧបសម្ព័ន្ធ ៣.២: ប្រធានបទសម្រាប់ក្រុមពិភាក្សាតូចៗមាននៅក្នុងលំហាត់ទី៣.១ ពាក់ព័ន្ធទៅការអភិវឌ្ឍលទ្ធភាពទទួលបានការងារធ្វើ



# បុព្វកថា/គោលគំនិតមូលដ្ឋាន



## ចំណុចចំបងនៃសេវាប្រឹក្សាយោបល់ការងារនៅក្នុងទម្រង់គំរូនៃលទ្ធភាពទទួលបានការងារធ្វើ

ក្នុងការបង្កើតទម្រង់គំរូឱ្យទទួលបានជោគជ័យពីដំណាក់ការអន្តរកាលទៅកាន់ការងារ បានតម្រូវឱ្យមានការបញ្ចូលគ្នានូវរាល់កត្តាដែលជះឥទ្ធិពលដល់លទ្ធភាពទទួលបានការងារធ្វើ។ នៅក្នុងចំណុចនេះយើងបានកំណត់ នូវកត្តាគន្លឹះមួយចំនួនមានដូចខាងក្រោម:

- ព័ត៌មានទីផ្សារការងារ
- ជំនួយក្នុងការស្វែងរកការងារធ្វើ
- ការអប់រំ
- ការបណ្តុះបណ្តាល
- អាជីព និងការប្រឹក្សាយោបល់ការងារ
- ការអនុវត្តនៅក្នុងទីផ្សារការងារ

បញ្ហាប្រឈម គឺពាក់ព័ន្ធពីអ្នកស្វែងរកការងារធ្វើពីមួយទៅមួយ និងការតម្រង់ទិសអ្នកទាំងនោះឱ្យឆ្ពោះទៅកាន់គោលដៅរួមដែលធ្វើឱ្យលទ្ធភាពទទួលបានការងារធ្វើមានភាពល្អប្រសើរឡើងវិញ។

# បទបង្ហាញទី ៣.១: កត្តាដែលជះឥទ្ធិពល ដល់លទ្ធភាពទទួលបានការងារធ្វើ

ទំព័របង្ហាញទី ៣.១ ( Slide Presentation )

រូបទី១: តារាងស្តីពីការអភិវឌ្ឍលទ្ធភាពទទួលបានការងារធ្វើ



ក្រាហ្វិកស្តីអំពីការបង្កើតទម្រង់គំរូនៃលទ្ធភាពទទួលបានការងារធ្វើ (**ទំព័របង្ហាញទី ៣.១**) បានបង្ហាញពីកត្តាដែលជះឥទ្ធិពលដល់លទ្ធភាពទទួលបានការងារធ្វើ។ កត្តាដែលជួយពង្រឹងដល់លទ្ធភាពទទួលបានការងារធ្វើមាននៅខាងឆ្វេងនៃក្រាហ្វិកដែលទាក់ទងទៅនឹងបុគ្គលិកលក្ខណៈរបស់បុគ្គលរួមមាន **ការអប់រំ ការបណ្តុះបណ្តាល និងការបណ្តុះបណ្តាលឡើងវិញ ការប្រឹក្សាយោបល់ការងារ ការវាយតម្លៃមុននឹងធ្វើការសិក្សា និងការវាយតម្លៃជំនាញ** ។ ចំណុចទាំងនេះ គឺជាចំណុចចំបងរបស់វគ្គបណ្តុះបណ្តាល។ យើងនឹងបង្ហាញជូនអំពីផែនការសកម្មភាពប្រចាំសប្តាហ៍ពីបែបផែនដែលកត្តាទាំងនេះមានទំនាក់ទំនងគ្នាទៅវិញទៅមក និងការប្រឹក្សាយោបល់ការងារដែលជួយអ្នកស្វែងរកការងារធ្វើពង្រឹងលទ្ធភាពទទួលបានការងារធ្វើរបស់ខ្លួន។ ទន្ទឹមនឹងនេះ ការជួយដល់អ្នកស្វែងរកការងារធ្វើ គឺអាស្រ័យទៅលើចំណុចដែលមានខាងលើ ដើម្បីទទួលបានការងារធ្វើណាមួយដែលសមរម្យ។

នៅផ្នែកខាងស្តាំនៃរូបទី១ ខាងលើ បានបង្ហាញពី **លក្ខណៈទូទៅនៃទីផ្សារការងារ** ដែលជះឥទ្ធិពលដល់លទ្ធភាពទទួលបានការងារធ្វើរបស់អ្នកស្វែងរកការងារធ្វើ។ ទាំងអស់នេះ គឺជាចំណុចដ៏សំខាន់ក្នុងការគ្រប់គ្រងបុគ្គលិករបស់និយោជក និងការអនុវត្តក្នុងការជ្រើសរើស។

នៅក្នុងជំហានដំបូង អ្នកផ្តល់ប្រឹក្សាយោបល់ការងារចាំបាច់ត្រូវរៀបចំផែនការសកម្មភាពសម្រាប់បទអន្តរាគមន៍នៅក្នុងការប្រឹក្សាយោបល់ការងារ ដោយកំណត់នូវចំណុចគន្លឹះដែលជួយដល់អ្នកទាំងនោះឱ្យឆ្លងផុតពីដំណាក់កាលអន្តរកាលទៅកាន់ពិភពការងារ។ ដំណាក់កាលអន្តរកាលរួមមាន ៥ ដំណាក់កាល (ទំព័របង្ហាញទី៣.២)។



# បទបង្ហាញទី ៣.២: ការបង្កើតទម្រង់គំរូដើម្បីធ្វើឱ្យលទ្ធភាពទទួលបានការងារធ្វើមានភាពល្អប្រសើរ



**ទំព័របង្ហាញទី ៣.២**

ដំណាក់កាលអន្តរកាលទៅកាន់ពិភពការងារ រួមមាន ៥ ដំណាក់កាល:

- ការស្គាល់ខ្លួនឯង
- ការស្គាល់ និងយល់ដឹងពីបរិស្ថានជុំវិញខ្លួន
- ការត្រៀមខ្លួនរួចជាស្រេច
- ការទទួលបានការងារធ្វើ
- ការសម្របខ្លួនទៅនឹងការងារដែលទទួលបាន

ការគិតពិចារណាអំពីចំណង់ចំណូលចិត្ត ជំនាញ និងអត្តចរិករបស់ខ្លួន គឺ

តើគោលបំណងមុខរបររបស់លោកអ្នកមានភាពជាក់លាក់ និងកំពុងតែមានតម្រូវនៅក្នុងតំបន់របស់លោកអ្នកដែរឬទេ?

តើលោកអ្នកអាចបង្កើនជំនាញរបស់ខ្លួន ដើម្បីឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រកួតប្រជែងនៅក្នុងទីផ្សារការងារដែរឬទេ?

តើលោកអ្នកបានប្រើប្រាស់បច្ចេកទេសសមស្របក្នុងការជានាការងាររបស់ខ្លួនដែរឬទេ?

នៅក្នុងបរិស្ថានការងារ តើដូចគ្នាទៅនឹងអត្តចរិក និងចំណង់ចំណូលចិត្តរបស់លោកអ្នកដែរឬទេ?

- ការស្គាល់ខ្លួនឯង (ការវាយតម្លៃទៅលើចំណង់ចំណូលចិត្តរបស់ខ្លួន ជំនាញ ឬសមត្ថភាព អត្តចរិក និងការប្រឹក្សាយោបល់ជាដើម)
- ការយល់ និងស្គាល់ពីបរិស្ថានជុំវិញខ្លួន (ការស្វែងយល់អំពីកន្លែងការងារ នរណាជាអ្នកជ្រើសរើសបុគ្គលិក ទីកន្លែងណាដែលមានសក្តានុពលក្នុងការអភិវឌ្ឍបទដ្ឋានជំនាញ និងជំនាញដែលកំពុងត្រូវការជាដើម)
- ការត្រៀមខ្លួនរួចជាស្រេច (ការសិក្សាអប់រំ ឬការបណ្តុះបណ្តាលឱ្យកាន់តែល្អប្រសើរ ការស្វែងយល់អំពីការងារដែលអាចរកបាន និងការបណ្តុះបណ្តាលអំពីសហគ្រិនភាព)
- ការទទួលបានការងារធ្វើ (ទទួលបានការងារល្អ ការទំនាក់ទំនងជាមួយនិយោជក ការត្រៀមខ្លួនធ្វើបទសម្ភាសន៍ការងារជាដើម)
- ការសម្របខ្លួនទៅនឹងការងារដែលទទួលបាន (បរិស្ថានការងារ ការបំពេញការងារ និងសេចក្តីរំពឹងទុករបស់និយោជក)

ចំណុចខាងលើដែលមាននៅក្នុងដំណាក់កាលនេះ មិនមែនកើតឡើងតាមលំដាប់លំដោយនោះទេ ក៏ប៉ុន្តែកើតឡើងដំណាលគ្នា។ ចំណុចទាំងនេះមានទំនាក់ទំនងគ្នាទៅវិញទៅមកដែលរួមចំណែកដល់លទ្ធភាពទទួលបានការងារធ្វើ។

អ្នកផ្តល់ប្រឹក្សាយោបល់ការងារ ត្រូវចេះពន្យល់អ្នកស្វែងរកការងារធ្វើ ឱ្យមានជំនឿទុកចិត្តថា ខ្លួននឹងទទួលបានការងារធ្វើដោយស្របទៅតាមជំនាញ និងសមត្ថភាពរបស់ខ្លួននឹងអាចថែរក្សាការងារនេះឱ្យបានឋិតថេរក្នុងរយៈពេលវែង។ ភាពជឿជាក់ទៅលើសមត្ថភាពរបស់នរណាម្នាក់ គឺជាកត្តាដ៏សំខាន់ដែលជះឥទ្ធិពលពីដំណាក់កាលអន្តកាលទៅកាន់ពិភពការងារនាពេលខាងមុខ។



## បទបង្ហាញទី ៣.៣: ដំណាក់កាលអន្តរកាល ទៅកាន់ពិភពការងារ និងចំណុចទាំង ៥ យ៉ាង ដែលមាននៅក្នុងលទ្ធភាពទទួលបានការងារធ្វើ



ដំណាក់កាលអន្តរកាលទៅកាន់ពិភពការងារមាន ៥ ចំណុចសំខាន់ៗ រួមមានៈ

- **បញ្ហាបរិស្ថានជុំវិញខ្លួន និងបញ្ហាផ្ទាល់ខ្លួនដែលជះឥទ្ធិពលទៅលើលទ្ធភាពស្វែងរកការងារធ្វើ និងការថែរក្សាការងារឱ្យបានឋិតថេរ**
  - ជំនាញ និងឥរិយាបថរបស់បុគ្គលរួមមាន បុគ្គលដែលចេះគោរពខ្លួនឯង ជំនាញក្នុងការទំនាក់ទំនង ជំនាញក្នុងការដោះស្រាយបញ្ហា ឬការសម្របខ្លួន
  - ការគាំពារអាចតម្រូវឱ្យមាននៅក្នុងផ្នែកថែទាំកុមារ មធ្យោបាយក្នុងការធ្វើដំណើរ ការផ្លាស់ប្តូរទីកន្លែង និងកន្លែងស្នាក់នៅជាដើម
  - ការវាយតម្លៃខ្លួនឯង
- **ការសម្រេចចិត្តជ្រើសរើសមុខរបរ (អាជីព)**
  - សមត្ថភាពក្នុងការសម្រេចចិត្តទៅលើគោលដៅមុខរបរ (អាជីព) ច្បាស់លាស់
  - តម្រូវការព័ត៌មានទីផ្សារការងារ
  - ការប្រឹក្សាយោបល់ក្នុងការស្វែងរក (ការស្វែងយល់) អាជីព លក្ខខណ្ឌការងារ និងសេចក្តីរំពឹងទុករបស់និយោជក
- **ការបង្កើន និងពង្រឹងជំនាញ**
  - មានជំនាញចាំបាច់សម្រាប់បំពេញការងារ
  - សេចក្តីត្រូវការក្នុងការសិក្សាអប់រំឱ្យកាន់តែល្អប្រសើរ
  - ការបណ្តុះបណ្តាល
  - ការសិក្សាមិនចេះចប់
- **ការស្វែងរកការងារធ្វើ**
  - សមត្ថភាពក្នុងការស្វែងរកការងារធ្វើនៅក្នុងទីផ្សារការងារដែលពោរពេញទៅដោយការប្រកួតប្រជែង
  - ការយល់ដឹងអំពីការជ្រើសរើសបុគ្គលិក (បណ្តាញក្នុងសង្គម)
  - ការទំនាក់ទំនងនិយោជក

– ជំនាញក្នុងការស្វែងរកការងារធ្វើ

- **ការថែរក្សាការងារឱ្យបានឋិតថេរ**

– បន្តអនុវត្តនូវជំនាញទន់របស់ខ្លួនរួមមាន អាកប្បកិរិយាក្នុងពេលបំពេញការងារ និងជំនាញបច្ចេកទេសដែលមាន

– ការចាត់ចែងការងារ

– ប្រាក់ឈ្នួល ឬប្រាក់ខែ

– ការឆ្លើយតបទៅនឹងសេចក្តីរំពឹងទុករបស់និយោជក

ចំណុចដែលបានរៀបរាប់ខាងលើ គឺជាកត្តាដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកដែលស្របទៅនឹងឥរិយាបថបុគ្គលផ្ទាល់ដែលនាំទៅដល់ការទទួលបានការងារធ្វើ។ ក្នុងនោះក៏មានកត្តាមួយចំនួនដែលជះឥទ្ធិពលដល់លទ្ធភាពទទួលបានការងារធ្វើដែលបណ្តាលមកពីស្ថានភាពទីផ្សារការងារ ការគ្រប់គ្រងបុគ្គលិករបស់និយោជក និងបែបបទក្នុងការជ្រើសរើសបុគ្គលិក។

# លំហាត់ទី ៣.១ : កំណត់បញ្ហាគន្លឹះដែលពាក់ព័ន្ធនៅនឹងទម្រង់គំរូនៃលទ្ធភាពទទួលបានការងារធ្វើ និងភាពគ្រប់គ្រាន់របស់អតិថិជននៅក្នុងទីផ្សារការងារនៅប្រទេសកម្ពុជា

រយៈពេល : ៦០ នាទី

គោលបំណង:

- ✓ សិក្ខាកាមទាំងអស់ ធ្វើការកំណត់អំពីចំណុចសំខាន់ៗដែលមាននៅក្នុងលទ្ធភាពទទួលបានការងារធ្វើក្នុងបរិបទនាពេលបច្ចុប្បន្ន។

សេចក្ដីណែនាំ:

- ✓ សិក្ខាកាមទាំងអស់ត្រូវបែងចែកជាគូរ(ពីរនាក់)។ សមាជិកក្រុមចំនួនពាក់កណ្ដាលត្រូវបានចែកជូននូវកម្រងសំនួរ **ត្រូវ/ខុស** សម្រាប់ធ្វើការពិភាក្សា និងបំពេញ។ (សូមមើលឧបសម្ព័ន្ធទី ៣.១) សមាជិកក្រុមចំនួនពាក់កណ្ដាលទៀតត្រូវបានចែកជូននូវតារាងប្រធានបទដែលមាននៅក្នុងឧបសម្ព័ន្ធទី ៣.២។
- ✓ នៅក្នុងក្រុមដែលបានបែងចែកជាគូរ សិក្ខាកាមគ្រប់រូបត្រូវឆ្លើយរាល់សំនួរនីមួយៗ និង/ឬ តារាងអំពីបញ្ហាផ្សេងៗដែលត្រូវលើកយកមកពិភាក្សាដោយខ្លួនឯង (ឧបសម្ព័ន្ធទី៣.២) បន្ទាប់ពីបានធ្វើការពិភាក្សាអំពីចម្លើយជាមួយនឹងដៃគូររបស់ខ្លួន។ ក្រុមនីមួយៗ ត្រូវធ្វើការជ្រើសរើសអ្នកតំណាងដើម្បីធ្វើការបកស្រាយអំពីហេតុផលនៃចម្លើយរបស់ខ្លួននៅក្នុងក្រុមពិភាក្សាធំ។ (រយៈពេល ២០នាទី)
- ✓ នៅក្នុងក្រុមពិភាក្សាធំត្រូវមានអ្នកតំណាងមកពីក្រុមដែលបានបែងចែកជាគូរ ដើម្បីធ្វើការពន្យល់ពីហេតុផលនៃចម្លើយរបស់ខ្លួន និងអំពីកត្តាដែលមាននៅក្នុងលទ្ធភាពទទួលបានការងារធ្វើដូចមានរៀបរាប់នៅក្នុងកម្រងសំណួរស្ដីអំពីផលប៉ះពាល់ដល់អ្នកប្រើប្រាស់សេវា។ (រយៈពេល ២០នាទី)
- ✓ អ្នកសម្របសម្រួលនឹងដឹកនាំការពិភាក្សាអំពីលទ្ធផល និងរបកគំហើញដែលបានមកពីប្រភពទិន្នន័យព័ត៌មានទីផ្សារការងារ (LMI) នៅប្រទេសកម្ពុជា។ (រយៈពេល ២០នាទី)

## ឧបសម្ព័ន្ធទី ៣.១
## សំនួរជ្រើសរើស ត្រូវ/ខុស ស្ដីអំពីស្ថានភាពជាក់ស្ដែងនៅក្នុងទីផ្សារការងារនៅប្រទេសកម្ពុជា

១. _____ បើតាមសមាមាត្រនៃចំនួនសរុបជនងាយរងគ្រោះក្នុងការងារ ស្ត្រីមានអត្រាខ្ពស់ជាងបុរស។

២._____ កម្មករកម្ពុជាដែលបានចេញទៅធ្វើការក្រៅប្រទេសភាគច្រើនបានឈប់ពីការប្រកបរបរកសិកម្ម និងការងារនៅក្នុងស្រុក។

៣._____ នៅប្រទេសកម្ពុជាការចូលរួមនៅក្នុងកម្លាំងពលកម្មរវាងបុរស និងស្ត្រី មានកម្រិតប្រហាក់ប្រហែលគ្នា ទោះបីជានៅក្នុងទីផ្សារការងារមានទំនោរក្នុងការបែងចែកទៅតាមភេទក៏ដោយ។

៤. _____ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី ២៥ ដល់ ៥៥ ឆ្នាំ គឺជាចំនួនច្រើនជាងគេ បើប្រៀបធៀបទៅនឹងចំនួនប្រជាជនសរុប។

៥. _____ ជាទូទៅអត្រាអ្នកគ្មានការងារធ្វើ និងអត្រាអ្នកមានការងារធ្វើមិនជាក់លាក់នៅជនបទមានអត្រាខ្ពស់ជាងនៅទីក្រុង។

៦. _____ នៅក្នុងអំឡុងវិបត្តិសេដ្ឋកិច្ចពិភពលោក មានអ្នកស្វែងរកការងារធ្វើភាគច្រើនដែលបាត់បង់ការងារនៅតាមរោងចក្រ បានវិលត្រលប់ទៅប្រកបរបរនៅក្នុងវិស័យកសិកម្មវិញ។

៧. _____ នៅក្នុងដំណើរការស្វែងរកការងារថ្មី អ្នកស្វែងរកការងារធ្វើបានធ្វើការសាកសួរមតិយោបល់ពីបណ្ដាមិត្តភ័ក្រ្ត និងប្រភពដទៃទៀតរួមមាន សហជីព អង្គការមិនមែនរដ្ឋាភិបាល និងការចុះផ្សាយក្នុងសារព័ត៌មានជាដើម។

៨. _____ លក្ខណៈពិសេសនៃទីផ្សារការងារនៅប្រទេសកម្ពុជា គឺអត្រាសមាមាត្រខ្ពស់របស់កម្មករ ឬពលករដែលមានការងារធ្វើលើសពីមួយ។

៩._____ កត្តាដែលសំខាន់បំផុតនៅក្នុងដំណើរការស្វែងរកការងារធ្វើ គឺការរៀបចំប្រវត្តិរូបសង្ខេបឱ្យបានត្រឹមត្រូវ និងល្អប្រសើរ។

១០._____យុវជនស្វែងរកការងារធ្វើភាគច្រើនដែលបានបញ្ចប់ការសិក្សាក្នុងកម្រិតអនុវិទ្យាល័យ មានការចាប់អារម្មណ៍ពីឱកាសការងារ និងប្រភេទមុខរបរដែលមានសម្រាប់ពួកគេ។

## ឧបសម្ព័ន្ធទី ៣.១.១

## សំនួរជ្រើសរើស ត្រូវ/ខុស ស្តីអំពីស្ថានភាពជាក់ស្តែងនៅក្នុងទីផ្សារការងារនៅប្រទេសកម្ពុជា

១. ត្រូវ តាមសមាមាត្រចំនួនសរុបនៃជនដែលងាយរងគ្រោះក្នុងការងារស្ត្រីមានអត្រាខ្ពស់ជាងបុរសប្រមាណជាងពាក់កណ្តាល ៥៣.១%។ បើយោងតាមទិន្នន័យជំរឿនប្រជាជនឆ្នាំ២០០៨ បានបង្ហាញថា មួយភាគធំនៃក្រុមជនងាយរងគ្រោះក្នុងការងារត្រូវបានកំណត់ថាជាកម្មករ ឬពលករដែលបម្រើការឱ្យក្រុមគ្រួសាររបស់ខ្លួនដោយពុំមានប្រាក់ឈ្នួល និងកម្មករ ឬពលករដែលមានគណនីដោយឡែករបស់ខ្លួនមានប្រមាណ ៨២.៥% នៃចំនួនប្រជាពលរដ្ឋដែលមានការងារធ្វើអាយុ១៥ឆ្នាំ ឬ១៥ឆ្នាំឡើង។ ទោះ បីជាពុំមានការធ្វើអង្កេតទៅលើការងារក្រៅប្រព័ន្ធក៏ដោយ យើងសង្កេតឃើញថាក្រុមជនដែលងាយរងគ្រោះក្នុងការងារ បានបម្រើការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលទទួលបានប្រាក់ចំណូលទាប និងមិនទទួលបានការគាំពារពីប្រព័ន្ធសុវត្ថិភាពសង្គម ឬសន្តិសុខការងារ ឬប្រាក់ចំណូល ព្រមជាមួយនឹងលក្ខខណ្ឌការងារដែលមិនល្អគ្រប់គ្រាន់។

២. ខុស បើយោងតាមតួលេខដែលផ្តល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្ហាញឱ្យឃើញថាកម្មករ ឬពលករដែលបានធ្វើចំណាកស្រុកទៅបម្រើការងារនៅបរទេសភាគច្រើនធ្វើការក្នុងវិស័យឧស្សាហកម្ម អ្នកបម្រើតាមផ្ទះ និងវិស័យកសិកម្ម។ ការខិតខំប្រឹងប្រែងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការរៀបចំគោលនយោបាយទ្វេភាគី និងពហុភាគីក្នុងគោលបំណង បង្កើន ឱកាសការងារក្រៅប្រទេសសម្រាប់ប្រជាជនកម្ពុជាដែលកំពុងស្វែងរកការងារធ្វើ និងការគ្រប់គ្រងប្រព័ន្ធចំណាកស្រុក(ទេសន្តរប្រវេសន៍) អន្តរជាតិឱ្យបានល្អប្រសើរ ។

៣. ត្រូវ ក្នុងខណៈពេលដែលសេដ្ឋកិច្ចប្រទេសកម្ពុជាកំពុងរីកចម្រើន និងមានការចូលរួមនៅក្នុងសេដ្ឋកិច្ចពិភពលោក ដូចនេះ ទាំងបុរស និងស្ត្រីត្រូវធ្វើការត្រៀមខ្លួនបានល្អប្រសើរក្នុងការចាប់យកឱកាសការងារទាំងឡាយដែលនឹងកើតមានឡើង។ កម្មករ ឬពលករ (អ្នកស្វែងរកការងារធ្វើ) ដែលមានការសិក្សាអប់រំ និងទទួលបានការបណ្តុះបណ្តាលធ្វើជាមូលដ្ឋាន អាចប្រើប្រាស់ជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការប្រឈមទៅនឹងការកំណត់កាលពីសម័យមុនអំពីដែនកំណត់ក្នុងការបំពេញការងាររវាងបុរស និងស្ត្រី និងការធ្វើដំណើរទៅមក។

៤. ខុស ប្រទេសកម្ពុជាត្រូវបានគេនិយាយថាជាសង្គមក្មេងខ្ចីដោយហេតុថាមានប្រជាជនប្រមាណ ៥០% ជាយុវជនដែលមានអាយុក្រោម ២៥ ឆ្នាំ។ ម្យ៉ាងវិញទៀត យុវជនដែលមានអាយុចាប់ពី ១៥ ដល់ ២៥ ឆ្នាំ មានប្រមាណ ៣២% នៃចំនួនយុវជនសរុបនៅក្នុងប្រទេសទាំងមូល។ ជារៀងរាល់ឆ្នាំមានចំនួនយុវជនយ៉ាងច្រើនប្រមាណ ៣០០.០០០ នាក់ ចូលប្រឡូកក្នុងទីផ្សារការងារ។ ភាគច្រើននៃអ្នកស្វែងរកការងារធ្វើទាំងនោះ គឺជាយុវជនដែលមកពីទីជនបទដែលប្រមាណជា ៨០% ធ្លាប់ជាអ្នកប្រកបរបរអាជីវកម្មដោយខ្លួនឯង និងជាអ្នកបម្រើការឱ្យក្រុមគ្រួសាររបស់ខ្លួនដោយពុំមានប្រាក់ឈ្នួល។

៥. ត្រូវ នៅក្នុងចំណោមកំលាំងពលកម្មដែលមានចំនួនសរុបជាង ៦ លាននាក់ មានប្រមាណ ៨០% មកពីវិស័យកសិកម្មដែលតំណាងឱ្យចំនួនប្រជាជនសរុបប្រមាណលើសពី ៤០%។ ភាគច្រើននៃកំលាំងពលកម្មដែលមាននៅក្នុងវិស័យកសិកម្ម គឺស្ថិតនៅតាមទីជនបទក្នុងប្រភេទការងារមិនជាក់លាក់ដូចជា : មានភាពស្ទាក់ស្ទើរក្នុងការស្វែងរកការងារធ្វើនៅកន្លែងផ្សេងៗ ការធ្វើចំណាកស្រុក ការធ្វើការក្នុងវិស័យសំណង់ វិស័យឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ជាដើម។

៦. ខុស បើយោងទៅតាមការសិក្សាស្រាវជ្រាវរបស់អង្គការ ILO ដែលធ្វើឡើងនៅចុងឆ្នាំ២០០៩ បានបង្ហាញឱ្យឃើញថា អ្នកស្វែងរកការងារធ្វើភាគច្រើនស្វែងរកការងារជាថ្មីឡើងវិញដោយវិលត្រលប់ទៅធ្វើការក្នុងឧស្សាហកម្មកាត់ដេរ។ ដោយសារកម្មករទាំងនោះបានបង្កើតនូវបណ្តាញទំនាក់ទំនងរវាងគ្នា និងគ្នានៅក្នុងរោងចក្រ។ ដោយក្នុងនោះកម្មករដែលបានចំណាកស្រុកជាស្ត្រី មានចំនួនជាងពាក់កណ្តាលនៃកំលាំងពលកម្មនៅតាមតំបន់ទីប្រជុំជន (ទីក្រុង) បានទៅបម្រើការងារនៅក្នុងផ្នែកលក់ដូចជាការលក់ដំណាំកសិផល និងនេសាទជាដើម។

៧. ត្រូវ លើសពីនេះទៅទៀត ការពឹងពាក់មិត្តភ័ក្ត្រដែលមានការងារធ្វើ (ជាមធ្យោបាយមួយដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការទំនាក់ទំនងការងារជាមួយនិយោជក) ក្នុងករណីនេះ ក៏ជាការលើកទឹកចិត្តដល់អ្នកស្វែងរកការងារធ្វើក្នុងការចូលរួម ឬបង្កើតក្រុមជំនួយ និងបណ្តាញស្វែងរកការងារធ្វើជាមួយអ្នកដែលមានស្ថានភាពដូចគ្នា។ កម្មករដែលត្រូវបានគេបញ្ឈប់ពីការងារជាច្រើនមិនចាប់អារម្មណ៍ទៅនឹងឱកាសការងារជាច្រើនដែលមានសម្រាប់ខ្លួននោះទេ រួមមានការបានទទួលព័ត៌មាន និងជំនួយផ្សេងៗដែលផ្តល់តាមរយៈការប្រឹក្សាយោបល់ និងការអន្តរាគមន៍ផ្នែកការងារជាដើម។

៨. ត្រូវ បញ្ហាដែលទាក់ទងទៅនឹងការមានការងារធ្វើលើសពីមួយ មានច្រើនជាងគេនៅក្នុងវិស័យអប់រំ និងកសិកម្ម ដូចជាតាមការធ្វើការងារតាមវេនៅក្នុងវិស័យកសិកម្ម និងគ្រូបង្រៀនសិស្សតាមថ្នាក់ ឬការបង្រៀនក្រៅម៉ោង។ ទន្ទឹមនឹងនេះ ភាពមានការងារធ្វើលើសពីមួយក៏មានច្រើន នៅក្នុងវិស័យសុខាភិបាល ការងារសង្គម រដ្ឋបាលសាធារណៈ និងការពារជាតិ ។

៩. ខុស ការរៀបចំប្រវត្តិរូបសង្ខេបឱ្យបានត្រឹមត្រូវ និងល្អប្រសើរគ្រាន់តែជាផ្នែកដ៏តូចនៅក្នុងដំណើរការស្វែងរកការងារធ្វើប៉ុណ្ណោះ។ នៅក្នុងករណីខ្លះ ប្រវត្តិរូបសង្ខេបប្រៀបបានទៅនឹង "**លិខិតចូល**" ទៅក្នុងអង្គភាពមួយ ក៏ប៉ុន្តែនៅខណៈពេលដែលមានអ្នកដាក់ពាក្យសុំចូលបម្រើការងារមានចំនួនពី ២០០ ទៅ ៣០០ នាក់ សម្រាប់មុខតំណែងតែមួយនោះ ប្រវត្តិរូបសង្ខេបដែលបានរៀបចំត្រឹមត្រូវ និងល្អប្រសើរមានពេលខ្លះក៏មិនបានទទួលការចាប់អារម្មណ៍ដែរ។ ហេតុដូច្នេះហើយ បានជាតម្រូវឱ្យមានការប្រើប្រាស់នូវវិធីសាស្ត្រជាច្រើនក្នុងការស្វែងរកការងារធ្វើ ដោយមិនគ្រាន់តែដាក់នូវប្រវត្តិរូបសង្ខេបតែប៉ុណ្ណោះទេ។

១០. ខុស បើយោងតាមក្រុមការងារវាយតម្លៃដែលបានធ្វើការសាកសួរជាមួយយុវជនដែលស្ថិតក្នុងក្រុមផ្សេងៗគ្នាដែលនៅតែមានបំណងបន្តការសិក្សានៅវិទ្យាល័យ អ្នកទាំងនោះមិនខ្វាយខ្វល់ទៅនឹងប្រភេទការងារដែលខ្លួនចង់ធ្វើបន្ទាប់ពីបានបញ្ចប់ការសិក្សា ដោយមិនមែនមកពីបញ្ហាការសិក្សា ឬសេដ្ឋកិច្ចនោះឡើយ។

# ឧបសម្ព័ន្ធទី ៣.២
# ប្រធានបទសម្រាប់ក្រុមពិភាក្សាតូចៗមាននៅក្នុងលំហាត់ទី ៣.១ ពាក់ព័ន្ធនៅនឹងការអភិវឌ្ឍលទ្ធភាពទទួលបានការងារធ្វើ

បញ្ហាសំខាន់ៗនៅក្នុងទីផ្សារការងារនៅប្រទេសកម្ពុជា រួមមានៈ

១. មានយុវជនភាគច្រើនដែលទទួលបានឱកាសការងារថ្មីនៅតាមរោងចក្រកាត់ដេរ ក៏ប៉ុន្តែសុវត្ថិភាពការងាររបស់អ្នកទាំងនោះគឺអាស្រ័យទៅលើកិច្ចព្រមព្រៀងអន្តរជាតិ និងស្ថានភាពទីផ្សារសាកលលោកទាំងស្រុង។

២. ចំនួនកម្មកររោងចក្រនាពេលបច្ចុប្បន្នបានតំណាងឱ្យមួយភាគតូចនៃចំនួនកំលាំងពលកម្មនៅក្នុងប្រទេសកម្ពុជាទាំងមូល។ រីឯការរំពឹងទុកខ្ពស់ចំពោះការផ្ញើប្រាក់យ៉ាងទៀងទាត់ទៅកាន់ស្រុកកំណើតបានចូលរួមចំណែកនៅក្នុងជីវភាពរស់នៅតាមទីជនបទ។

៣. ភាពមិនស៊ីគ្នារវាងការសិក្សាអប់រំ និងជំនាញរបស់យុវជនទៅនឹងតម្រូវការរបស់និយោជក គឺជាបញ្ហាចោទនៅក្នុងប្រទេសកម្ពុជា។

៤. ការផ្លាស់ប្តូរទីកន្លែងនៅក្នុងប្រទេស និងធ្វើការចំណាកស្រុកទៅក្រៅប្រទេស គឺជាបញ្ហាមួយដ៏សំខាន់នៅក្នុងទីផ្សារការងារ។ ការធ្វើចំណាកស្រុកនៅក្នុងប្រទេសមានការកើនឡើងក្នុងអំឡុងពេលថ្មីៗនេះដែលភាគច្រើនផ្លាស់ប្តូរពីតំបន់មួយទៅតំបន់មួយទៀត។

៥. អត្រាអ្នកគ្មានការងារធ្វើក្នុងប្រទេសកម្ពុជានៅមានកម្រិតទាប ពីព្រោះមនុស្សភាគច្រើនដែលមានអាយុគ្រប់ធ្វើការមិនអាចស្វែងរកការងារដែល "**សក្តិសម**" សម្រាប់ខ្លួន។ ដោយសារមូលហេតុពុំមានប្រាក់ឧបត្ថម្ភសម្រាប់អ្នកគ្មានការងារធ្វើ ឬប្រាក់សន្សំសម្រាប់ចំណាយនៅក្នុងគ្រួសារនោះ អ្នកគ្មានការងារធ្វើភាគច្រើនបានស្ថិតនៅក្រោមសម្ពាធក្នុងការទទួលយកការងារធ្វើណាមួយ ដើម្បីមានលទ្ធភាពទ្រទ្រង់ជីវភាពរបស់ខ្លួន។

# មេរៀនទី ៤

# ដំណើរការដោះស្រាយបញ្ហាក្នុងការប្រឹក្សាយោបល់ការងារ



**គោលបំណងនៃការសិក្សា :** នៅពេលបញ្ចប់មេរៀនទី ៤ នេះ សិក្ខាកាមទាំងអស់នឹង:

- យល់ដឹងអំពីតម្រូវការសម្រាប់ការផ្តល់ប្រឹក្សាយោបល់ការងារទោះបីជាការងារផ្លូវការមានការខ្វះខាតក៏ដោយ
- យល់ដឹង និងអាចពន្យល់អំពីដំណាក់កាលទាំង ៨ នៅក្នុងដំណើរការនៃការដោះស្រាយបញ្ហានៅការប្រឹក្សាយោបល់ការងារ
- យល់ដឹងអំពីដំណាក់កាលនីមួយៗ និងការអភិវឌ្ឍសមត្ថភាពសម្រាប់អ្នកផ្តល់ប្រឹក្សាយោបល់ដទៃទៀត
- មានសមត្ថភាពផ្តល់ប្រឹក្សាយោបល់ដល់អតិថិជននៅគ្រប់ដំណាក់កាលប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាព
- ធ្វើការតាមដាន (Follow-up) អំពីការវាយតម្លៃទៅលើការប្រឹក្សាយោបល់

**រយៈពេល** ៤ ម៉ោង

**សេចក្តីសង្ខេប** នៅក្នុងមេរៀននេះ:

- បទបង្ហាញទី ៤.១: ដំណាក់កាលទី១ - ការកំណត់ពីការលំបាកក្នុងការងារ
- លំហាត់ទី ៤.១: ការកំណត់ពីការលំបាកក្នុងការងារ
- បទបង្ហាញទី ៤.២: ដំណាក់កាលទី២ - ការបញ្ជាក់ពីការលំបាកក្នុងការងារ
- លំហាត់ទី ៤.២: ជំហានក្នុងការកំណត់ដំណាក់កាលទី១ និងទី២ នៃដំណើរការដោះស្រាយបញ្ហា
- បទបង្ហាញទី ៤.៣: ដំណាក់កាលទី៣ - ការបង្កើត និងការចងក្រងផែនការសកម្មភាព
- លំហាត់ទី ៤.៣: ការបង្កើតផែនការសកម្មភាព
- បទបង្ហាញទី ៤.៤: ដំណាក់កាលទី៤: ការអនុវត្ត និងការតាមដាន
- បទបង្ហាញទី៤.៥: ការពិនិត្យអំពីលទ្ធផលដែលសម្រេចបាននៃគោលដៅប្រឹក្សាយោបល់
- បទបង្ហាញទី ៤.៦: ការកំណត់អំពីភាពគ្រប់គ្រាន់របស់អតិថិជនក្នុងការទទួលបានការងារធ្វើ
- លំហាត់ទី ៤.៥: តើអតិថិជនបានសម្រេចគោលដៅនៃការប្រឹក្សាយោបល់ដែរឬទេ? លំហាត់សិក្សាគំរូដែលមានគូសបញ្ជាក់អំពីនីតិវិធីពាក់ព័ន្ធ



# គោលគំនិតមូលដ្ឋាន
# ដំណើរការដោះស្រាយបញ្ហាក្នុងការប្រឹក្សាយោបល់ការងារ



**ដំណើរការដោះស្រាយបញ្ហា**

- ត្រូវបានប្រើប្រាស់នៅពេលដំណើរការផ្តល់ការប្រឹក្សាយោបល់ដល់អតិថិជនចាប់ផ្តើម
- ផ្តល់ការគាំទ្រដល់ការចូលរួមរបស់អតិថិជននៅក្នុងសកម្មភាពផ្សេងៗដែលនាំអ្នកទាំងនោះទៅកាន់ទីផ្សារការងារបានយ៉ាងឆាប់រហ័ស
- ដំណើរការអន្តរកម្មដែលរួមមាន ៤ ដំណាក់កាល និងវិធានការទាំង ៨។ អ្នកផ្តល់ប្រឹក្សាយោបល់ និងអតិថិជនបានពិភាក្សាអំពីវិធានការ ដើម្បីទទួលបាននូវដំណោះស្រាយ និងការអនុវត្តនូវបទអន្តរាគមន៍ដែលជួយដល់អតិថិជនបង្កើនសកម្មភាពក្នុងការចូលរួមនៅក្នុងទីផ្សារការងារ។
- ដំណើរការនេះ គឺជាការចូលរួមរវាងអ្នកផ្តល់ប្រឹក្សាយោបល់ និងអតិថិជន។ នៅក្នុងដំណើរការនេះក៏បានបង្កើតនូវបែបបទក្នុងការពិភាក្សា ដើម្បីធ្វើការស្វែងយល់អំពីបញ្ហាគន្លឹះមុននឹងអតិថិជនធ្វើការសម្រេចចិត្តចំពោះដំណោះស្រាយណាមួយ។

**ដំណាក់កាលទាំង ៤ និងវិធានការទាំង ៨ មានដូចខាងក្រោម៖**

**ក. ការកំណត់ពីការលំបាកក្នុងការងារ**

១. ការបង្កើតទំនាក់ទំនង
២. ការកំណត់ទៅលើបរិបទអតិថិជន

**ខ. ការបញ្ជាក់ពីការលំបាកក្នុងការងារ**

៣. ការស្វែងយល់អំពីការងាររំពឹងទុកនាពេលបច្ចុប្បន្ន
៤. ការកំណត់អំពីជំនាញ និងកម្រិតគុណវុឌ្ឍន៍
៥. វាយតម្លៃចំពោះការត្រៀមទុកជាមុនក្នុងការស្វែងរកការងារធ្វើ និងការថែរក្សាការងារឱ្យបានឋិតថេរ

**គ. ការបង្កើត និងការចងក្រងផែនការសកម្មភាព**

៦. ការធ្វើសំយោគព័ត៌មាន និងការបង្កើតនូវជម្រើសផ្សេងៗ
៧. ការបង្កើតផែនការសកម្មភាពការងារ

**ឃ. ការអនុវត្ត និងការតាមដាន(Follow-up)**

៨.ការអនុវត្ត និងការតាមដាន(Follow-up)

## គុណសម្បត្តិនៃដំណើរការដោះស្រាយបញ្ហា រួមមាន៖

- ជួយកំណត់អំពីកិច្ចអន្តរាគមន៍មួយណាដែលសក្តិសមសម្រាប់អតិថិជន
- ជាដំណើរការដែលផ្តោតទៅលើគោលដៅជាចំបង។ អតិថិជនបានបង្កើតនូវផែនការសកម្មភាព វិធានការ ពេលវេលាដែលសង្កេតឃើញមានការវិវឌ្ឍន៍ទៅមុខចាប់តាំងពីកិច្ចអន្តរាគមន៍ទាំងឡាយត្រូវបានអនុវត្ត ហើយក៏ជាវិធានការដែលអាចសម្រេចទៅបាន
- អ្នកផ្តល់ប្រឹក្សាយោបល់អាចធ្វើការត្រួតពិនិត្យ និងវាយតម្លៃបានដោយងាយស្រួលទៅលើភាពរីកចម្រើន លទ្ធផលដែលសម្រេចបាន និងការតាំងចិត្តរបស់អតិថិជនចាប់តាំងពីវិធានការទាំងនោះត្រូវបានដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពជាមួយលទ្ធផលរំពឹងទុក
- សេវារបស់អ្នកផ្តល់សេវាដទៃទៀតមានសារៈសំខាន់ និងមានភាពងាយស្រួលក្នុងការត្រួតពិនិត្យ ពីព្រោះអ្នកទាំងនោះទទួលខុសត្រូវទៅលើគុណភាពនៃសេវាដែលខ្លួនបានផ្តល់

## បែបផែននៃការផ្តល់ប្រឹក្សាយោបល់

- ត្រូវបញ្ចប់ក្នុងមួយវគ្គ
- រយៈពេលជាមធ្យមពី ៣០ ទៅ ៤៥ នាទី
- មាននៅក្នុងលទ្ធភាពនៃការទទួលបានការងារធ្វើទាំង ៥ យ៉ាង ដោយក្នុងនោះរួមបញ្ចូលនូវកត្តាផ្ទាល់ខ្លួន និងការរកឃើញបញ្ហាគន្លឹះបានឆាប់រហ័ស
    ១. កត្តាបុគ្គល និងបរិស្ថានជុំវិញខ្លួនដែលជះឥទ្ធិពលដល់លទ្ធភាពទទួលបានការងារធ្វើ
    ២. មានគោលដៅការងារច្បាស់លាស់/សមត្ថភាពក្នុងការសម្រេចចិត្តអំពីអាជីព
    ៣. មានជំនាញ និងតម្រូវការដែលទាមទារសម្រាប់ការបំពេញការងារ
    ៤. មានជំនាញស្វែងរកការងារធ្វើ
    ៥. មានជំនាញថែរក្សាការងារឱ្យបានឋិតថេរ
- ធ្វើការពិនិត្យទៅលើជម្រើសនៃការបណ្តុះបណ្តាលវិជ្ជាជីវៈដោយឆ្លុះបញ្ចាំងទៅនឹងស្ថានភាពទីផ្សារការងារនាពេលបច្ចុប្បន្ន
- ធ្វើការពិភាក្សាអំពីលទ្ធភាពនៃការទទួលបានការងារធ្វើដោយឆ្លុះបញ្ចាំងទៅនឹងជម្រើសនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការកំណត់ទៅលើវិធានការផ្សេងៗគ្នាដែលនឹងត្រូវអនុវត្ត ដើម្បីសម្រេចបាននូវគោលដៅនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើការកំណត់ពេលវេលាវិធានការបន្ទាន់ ហើយចំណុចទាំងនេះត្រូវបានបញ្ចូលនៅក្នុងផែនការសកម្មភាព
- រួមបញ្ចូលទាំងសមាសភាពនៃការតាមដាន (Follow-up)



# បទបង្ហាញទី ៤.១: ដំណាក់កាលទី១-ការកំណត់ពីការលំបាកក្នុងការងារ



ទំព័របង្ហាញទី ៤.១

ដំណើរការដោះស្រាយបញ្ហានៅក្នុងការប្រឹក្សាយោបល់ការងារ

- ដំណាក់កាលទី១: ការកំណត់ពីការលំបាកក្នុងការងារ
  - ការបង្កើតទំនាក់ទំនង
  - ការកំណត់ទៅលើ(បរិបទ)អតិថិជន
- ដំណាក់កាលទី២: ការបញ្ជាក់ពីការលំបាកក្នុងការងារ
  - ការស្វែងយល់អំពីការរំពឹងទុកក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈនាពេលបច្ចុប្បន្ន
  - ការកំណត់ និងការវាយតម្លៃការងារដែលតម្រូវជំនាញជាក់លាក់ណាមួយ
  - វាយតម្លៃទៅលើការត្រៀមទុកជាមុនក្នុងការស្វែងរក និងការថែរក្សាការងារឱ្យបានឋិតថេរ

ទំព័របង្ហាញទី ៤.២

ដំណើរការដោះស្រាយបញ្ហានៅក្នុងការប្រឹក្សាយោបល់ការងារ (ត)

- ដំណាក់កាលទី៣: ការបង្កើត និងការចងក្រងផែនការសកម្មភាព
  - ការសំយោគព័ត៌មាន និងការបង្កើតនូវជម្រើសផ្សេងៗ
  - ការបង្កើតផែនការសកម្មភាព

**ដំណើរការដោះស្រាយបញ្ហានៅក្នុងការប្រឹក្សាយោបល់ការងារ (ត)**

- **ដំណាក់កាលទី៤: ការអនុវត្ត និងការតាមដាន** (Follow-up)
  - **ការអនុវត្ត**
    - ការធ្វើបទអន្តរាគមន៍
    - ធនធាននៅក្នុងសហគមន៍
  - **ការតាមដាន** (Follow-up)
    - ការពិនិត្យទៅលើការសម្រេចបាននៃគោលដៅប្រឹក្សាយោបល់

កំណត់ថា តើអតិថិជនមានសមត្ថភាពគ្រប់គ្រាន់ដែរឬទេ ?

**ទំព័របង្ហាញទី ៤.៣**

**ដំណាក់កាលទី១: ការកំណត់ពីការលំបាកក្នុងការងារ**

- ការបង្កើតទំនាក់ទំនង
  - ការបង្កើតទំនាក់ទំនង
  - ការចាប់ផ្តើមពិភាក្សាដំបូងទៅលើតួនាទី និងការរំពឹងទុក
  - ការស្វែងយល់អំពីគោលគំនិតរបស់អតិថិជនទៅលើបញ្ហា
- ការកំណត់ទៅលើបរិបទអតិថិជន
  - ធ្វើការស្វែងយល់អំពីតម្រូវការចាំបាច់ដែលត្រូវដោះស្រាយមុននឹងធ្វើការវាយតម្លៃទៅលើជម្រើសការងារ

<u>ការសហការ</u> :

ដំណាក់កាលដំបូងនៃដំណើរការវាយតម្លៃទៅលើការពិភាក្សារួមមាន អំពីស្ថានភាពរបស់អតិថិជននាពេលបច្ចុប្បន្នទៅនឹងការស្វែងរកការងារធ្វើរបស់អ្នកទាំងនោះ ព្រមជាមួយនឹងកិច្ចការដែលអ្នកផ្តល់ប្រឹក្សាយោបល់ខិតខំអាចជួយទៅបាន។ នៅក្នុងអំឡុងពេលពិភាក្សានេះ អ្នកផ្តល់ប្រឹក្សាយោបល់ត្រូវបង្កើតនូវទំនាក់ទំនងដែលអាចជឿទុកចិត្តបានដល់អតិថិជនដែលស្តែងឡើងតាមរយៈការរំពឹងទុកទៅវិញទៅមក តួនាទី គោលបំណងនៃការជួបពិភាក្សា និង

ការព្រមព្រៀងអំពីបែបបទដែលត្រូវអនុវត្តបន្ត។ ទំនាក់ទំនងដែលបានបង្កើតឡើង បានជួយលើកទឹកចិត្តអតិថិជនក្នុងការចូលរួម និងធ្វើការជាក្រុមជាមួយអ្នកផ្តល់ប្រឹក្សាយោបល់។ អតិថិជនមិនគ្រាន់តែជាបុគ្គលដែលត្រូវការជំនួយប៉ុណ្ណោះទេ ក៏ប៉ុន្តែជាបុគ្គលដែលគួរទទួលបាននូវសេវាដែលប្រកបដោយការយកចិត្តទុកដាក់ និងមានប្រសិទ្ធភាពខ្ពស់ពីសំណាក់អ្នកផ្តល់ប្រឹក្សាយោបល់។

នៅក្នុងចំណុចនេះ ត្រូវបានបែងចែកជា ៣ ដំណាក់កាលតូចៗ រួមមាន៖

- ការបង្កើតនូវទំនាក់ទំនងស្និតរមួត
- ការពិភាក្សាអំពីការយល់ឃើញរបស់អតិថិជនក្នុងពេលបច្ចុប្បន្នទៅលើស្ថានភាពការងាររបស់ខ្លួន និងការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការរំពឹងទុក តួនាទី គោលបំណង និងលទ្ធផលនៃការជួបពិភាក្សា

**<u>អតិថិជន:</u>** នៅក្នុងការពិភាក្សា អ្នកផ្តល់ប្រឹក្សាយោបល់ខិតខំធ្វើការស្វែងយល់អំពីចំណាប់អារម្មណ៍ តម្រូវការចាំបាច់ និងការត្រៀមខ្លួនរួចជាស្រេចក្នុងការស្វែងរកការងារធ្វើរបស់អតិថិជន។ អ្នកផ្តល់ប្រឹក្សាយោបល់ត្រូវលើកឡើងនូវបញ្ហាមួយចំនួនដែលអាចជះឥទ្ធិពលដល់អតិថិជន និងតម្រូវការចាំបាច់មួយចំនួនដែលអាចជាឧបសគ្គដល់អតិថិជនក្នុងការចូលរួមឡើងវិញនៅក្នុងទីផ្សារការងារឱ្យទទួលបានជោគជ័យ។

នាពេលបញ្ចប់ដំណាក់កាលនេះ ការលំបាកក្នុងការងារត្រូវបានកំណត់ (រកឃើញ) និងត្រូវបានកត់ត្រានៅក្នុងទម្រង់ "**កំណត់ត្រាការលំបាក**"។ ដំណាក់កាលទី ១ ត្រូវបានបញ្ចប់រវាងអតិថិជន និងអ្នកផ្តល់ប្រឹក្សាយោបល់ដោយបានឯកភាពគ្នាទៅលើគោលបំណងនៃការជជែកពិភាក្សា និងកិច្ចការដែលនឹងត្រូវអនុវត្តជាមួយគ្នា។



# លំហាត់ទី ៤.១ – ការកំណត់ពីការលំបាកក្នុងការងារ



**រយៈពេល:** ៤០នាទី

**គោលបំណង:**

សិក្ខាកាមអនុវត្តសាកល្បងនូវដំណាក់កាលដំបូងទាំង ២ ដែលមាននៅក្នុង "**ដំណើរការដោះស្រាយបញ្ហា**" និងធ្វើការកំណត់អំពីប្រការដែលគួរនិយាយ និងសាកសួរអតិថិជននៅក្នុងការជជែកពិភាក្សានេះ

**សេចក្តីណែនាំ:**

- **<u>ផ្នែកទី១</u>:** ក្រុមពិភាក្សានីមួយៗ ត្រូវផ្តល់ជាគំនិតនូវប្រការដែលគួរនិយាយ ឬគួរធ្វើ ដើម្បីបង្កើតទំនាក់ទំនងប្រសើរជាមួយអតិថិជន។ ការគិតទៅលើដំណាក់កាលតូចៗទាំង ៣ រួមមាន៖ ក. ការបង្កើតនូវទំនាក់ទំនងស្និតរមួត ខ. ការយល់ឃើញរបស់អតិថិជនក្នុងពេលបច្ចុប្បន្នទៅលើស្ថានភាពការងាររបស់ខ្លួន និងការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការរំពឹងទុក តួនាទី គោលបំណង និងលទ្ធផលនៃការជួបពិភាក្សា
  - **<u>ចម្លើយ:</u>** ស្វាគមន៍អតិថិជនប្រកបដោយភាពកក់ក្តៅ ការណែនាំខ្លួន ការចាប់ដៃ ហៅចំឈ្មោះ និងការនិយាយស្តីប្រកបដោយភាពជឿជាក់
  - ក្រុមពិភាក្សានីមួយៗ ធ្វើការពន្យល់អំពីវិធីសាស្រ្តក្នុងការសង្កេតអំពីអារម្មណ៍អតិថិជនចំពោះស្ថានភាពអត់ការងារធ្វើរបស់អ្នកទាំងនោះ និងអំពីវិធីសាស្រ្តក្នុងការលើកឡើងអំពីបញ្ហា ឬនិងតម្រូវការចាំបាច់មួយចំនួនដែលរាំងស្ទះដល់ការចូលរួមឡើងវិញរបស់អតិថិជននៅក្នុងទីផ្សារការងារឱ្យទទួលបានជោគជ័យ
  - **<u>ចម្លើយ:</u>** យល់ដឹងអំពីចំណុចដែលអតិថិជនដឹង និងស្គាល់អំពីកត្តានានាដែលរាំងខ្លួនក្នុងការសម្រេចបានគោលដៅការងារ ត្រូវបញ្ជាក់ពីអារម្មណ៍អតិថិជនចំពោះស្ថានភាពទាំងនោះ
  - កត់ត្រានូវគំនិតរបស់លោកអ្នកនៅលើក្រដាសដែលបានចែកជូន (រយៈពេល ២០ នាទី)
- **<u>ផ្នែកទី២</u>:** បែងចែកជាក្រុមពិភាក្សាដែលមានសមាជិក ០៣នាក់
  - លោកអ្នកនឹងអនុវត្តសាកល្បងនូវដំណាក់កាល ២ ដំបូង " **ការបង្កើតទំនាក់ទំនង** " និង " **កំណត់ចំពោះបរិបទអតិថិជន** " (រយៈពេល ២០ នាទី)
  - លោកអ្នកនឹងផ្លាស់ប្តូរវេនគ្នាក្នុងការសម្តែងជាអតិថិជន អ្នកផ្តល់ប្រឹក្សាយោបល់ និងអ្នកសង្កេតការណ៍ក្នុងលំហាត់នេះ និងលំហាត់បន្ទាប់។ ចំពោះអ្នកសង្កេតការណ៍សម្រាប់លំហាត់នេះត្រូវប្រើប្រាស់នូវតារាងសង្កេតការណ៍ (ឯកសារទី៤.១) ដើម្បីកត់ត្រាយោបល់បន្ថែម



## បទបង្ហាញទី ៤.២: ដំណាក់កាលទី២-ការបញ្ជាក់ពីការលំបាកក្នុងការងារ



ទំព័របង្ហាញទី ៤.៤

**ដំណាក់កាលទី២: ការបញ្ជាក់ពីការលំបាកក្នុងការងារ**

- ការស្វែងយល់អំពីការងាររំពឹងទុកនាពេលបច្ចុប្បន្ន
  - តើអតិថិជនមានគោលដៅការងារដែរឬទេ?
  - តើអតិថិជនមានជំនាញដែលអាចផ្លាស់ប្តូរបាន ដើម្បីបង្កើនឱកាសទទួលបានការងារធ្វើដែរឬទេ?
- ការកំណត់ និងវាយតម្លៃជំនាញការងារច្បាស់លាស់
  - ការពិនិត្យទៅការសិក្សា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រវត្តិការងារ ការស្ម័គ្រចិត្ត ប្រវត្តិការងារ និងចំណាប់អារម្មណ៍ជាដើម

**<u>សេចក្តីរំពឹងទុក:</u>** អ្នកផ្តល់ប្រឹក្សាយោបល់ និងអតិថិជន ទទួលបានការយល់ដឹងអំពីគោលដៅការងារ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់អតិថិជនជាមួយគ្នា ប្រសិនបើអតិថិជនមាន។
ក្នុងករណីដែលអតិថិជនមានគោលដៅការងារ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈនោះ អ្នកផ្តល់ប្រឹក្សាយោបល់ត្រូវធ្វើការស្វែងយល់អំពីមូលហេតុ និងវិធីសាស្ត្រក្នុងការជ្រើសរើស ។

**<u>ជំនាញ:</u>** ការពិភាក្សាអំពីព័ត៌មានលម្អិតដែលពាក់ព័ន្ធទៅនឹងជំនាញការងារច្បាស់លាស់របស់អតិថិជន និងកម្រិតគុណវុឌ្ឍន៍។ អ្នកប្រឹក្សាយោបល់ជួយដល់អតិថិជនកំណត់ និងវាយតម្លៃជំនាញការងារច្បាស់លាស់ (ជំនាញរឹង) និងជំនាញទន់ ព្រមទាំងកម្រិតវប្បធម៌។

**<u>ស្វែងរកជំនាញដែលសក្តិសម:</u>** ជំនាញការងារច្បាស់លាស់ ជំនាញដែលអាចផ្លាស់ប្តូរបាន/ជំនាញតាមប្រភេទ ជំនាញគ្រប់គ្រងខ្លួនឯង បទពិសោធន៍ការងារ ការអប់រំ បទពិសោធន៍ក្នុងការងារស្ម័គ្រចិត្ត ការបណ្តុះបណ្តាល អាជ្ញាបណ្ណ ឧបករណ៍ សម្ភារ និងចំណាប់អារម្មណ៍ជាដើម ។
គោលបំណងនៅក្នុងដំណាក់កាលនេះ គឺដើម្បីពិនិត្យទៅលើចំណុចខ្លាំង ចំណុចខ្សោយ កត្តាដែលបង្កជាបញ្ហានៅក្នុងការងារ និងការកំណត់ប្រភពបញ្ហា។
គោលដៅនៅក្នុងដំណាក់កាលនេះ គឺស្វែងឱ្យឃើញនូវស្ថានភាពការងាររបស់អតិថិជន និងបញ្ហានានាដែលអ្នកទាំងនោះបានជួបប្រទះ ហេតុដូចនេះត្រូវកំណត់អំពីជម្រើសក្នុងការដំណោះស្រាយបញ្ហា និងការបង្កើតនូវផែនការសកម្មភាព។

**ទំព័របង្ហាញទី ៤.៥**

**ដំណាក់កាលទី២: ការបញ្ជាក់ពីការលំបាកក្នុងការងារ (ត)**

- ការវាយតម្លៃទៅលើការត្រៀមក្នុងការស្វែងរកការងារធ្វើ និងការថែរក្សាការងារឱ្យបានឋិតថេរ
  - ការពិភាក្សាទៅលើសក្តានុពលរបស់អតិថិជនក្នុងការស្វែងរក និងការរក្សាការងារ
  - ការពិនិត្យអំពីតម្រូវការគាំទ្រក្នុងការស្វែងរក និងថែរក្សាការងារឱ្យបានឋិតថេរ

នៅក្នុងដំណាក់កាលនេះ អ្នកផ្តល់ប្រឹក្សាយោបល់អាចធ្វើការស្វែងយល់បន្ថែមអំពីបញ្ហាផ្សេងៗ។ ទន្ទឹមនឹងនេះ ក៏ជាការពិភាក្សាអំពីជំនាញក្នុងការស្វែងរកការងារធ្វើ និងជំនាញគ្រប់គ្រងខ្លួនឯង។

ការត្រៀមខ្លួនជាស្រេចទាក់ទងទៅនឹងលទ្ធភាពទទួលបានការងារធ្វើទី១ នោះ គឺកត្តាផ្ទាល់ខ្លួន និងបរិស្ថានជុំវិញខ្លួន ដែលជះឥទ្ធិពលទៅលើលទ្ធភាពទទួលបានការងារធ្វើ។
នៅក្នុងចំណុចនេះ ត្រូវធ្វើការត្រួតពិនិត្យ ដើម្បីប្រាកដថា ពុំមានភ្លេចចំណុចណាមួយនៅពេលមុនចាប់ផ្តើមធ្វើការពិភាក្សា សំនួរដែលប្រើប្រាស់បានដូចជា " ប្រសិនបើលោកអ្នកត្រូវបាននិយោជកផ្តល់ការងារនៅថ្ងៃស្អែក តើលោកអ្នកមានហេតុផលណាមួយដែលថា ហេតុអ្វីបានជាលោកអ្នកមិនអាចទទួលការងារនោះបាន?" ចំពោះចម្លើយដែលអាចឆ្លើយបាននោះ គឺមកពីការថែទាំក្មេង ការដឹកជញ្ជូន ជួយរៀបចំហិរញ្ញវត្ថុរបស់អ្នកទាំងនោះជាដើម ។ល។

នៅក្នុងដំណាក់កាលទី២ គឺការពិនិត្យឡើងវិញទៅលើ "កំណត់ត្រាការលំបាក" ដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការពិនិត្យឱ្យកាន់តែស៊ីជម្រៅទៅលើស្ថានភាពការងាររបស់អតិថិជន ដែលក្នុងនោះសកម្មភាពសមស្រប និងត្រឹមត្រូវនឹងត្រូវកំណត់នៅក្នុងដំណាក់កាលទី៣ ។ គោលដៅនៃការប្រឹក្សាយោបល់ គឺត្រូវបានបង្កើតឡើងដោយផ្អែកទៅលើ "កំណត់ត្រាការលំបាក" ។

# លំហាត់ទី ៤.២ – ជំហានក្នុងការកំណត់ដំណាក់កាល ទី១ និងទី២ នៃដំណើរការដោះស្រាយបញ្ហា

រយៈពេល: ៦០នាទី

គោលបំណង:

- ជួយអតិថិជនក្នុងការស្វែងយល់អំពីបញ្ហាប្រឈមដែលនឹងត្រូវជួបប្រទះនៅក្នុងដំណាក់កាលទី១ និងទី២ នៃដំណើរការដោះស្រាយបញ្ហា

សេចក្ដីណែនាំ:

- ខ្ញុំនឹងធ្វើការបង្ហាញជូនអំពីដំណាក់កាលទី១ និងទី២ នៃដំណើរការដោះស្រាយបញ្ហា ដោយប្រើប្រាស់នូវកម្រងរឿង-អតិថិជន(Client-scenario) (**ឯកសារទី ៤.២**) ជាមួយអ្នកស្ម័គ្រចិត្តក្នុងក្រុមដែលសម្ដែងជាអតិថិជន
- បែងចែកជា ៣ ក្រុមពិភាក្សា
- ក្រុមនីមួយៗ ត្រូវធ្វើការសង្កេតឱ្យបានជិតដល់នូវដំណាក់កាលទី១ និងទី២ ហើយធ្វើការកត់ត្រាចំណុចដែលបានអនុវត្ត និងជម្រើសផ្សេងៗសម្រាប់អតិថិជន ។ (ប្រើប្រាស់តារាងសង្កេតការទី១ និងទី២ គឺ **ឯកសារ ទី៤.១ និង ទី៤.៣**)
    - **ក្រុមទី១**: បង្កើតទំនាក់ទំនង និងស្វែងយល់អំពីការរំពឹងទុកចំពោះការបណ្ដុះបណ្ដាលវិជ្ជាជីវៈក្នុងពេលបច្ចុប្បន្ន។
    - **ក្រុមទី២**: ការកំណត់ចំពោះអតិថិជន ការស្វែងយល់ និងការវាយតម្លៃទៅលើកម្រិតជំនាញ/កម្រិតគុណវុឌ្ឍិ។
    - **ក្រុមទី៣**: ការវាយតម្លៃទៅលើការត្រៀមទុកជាមុនក្នុងការស្វែងរកការងារធ្វើ និងថែរក្សាការងារឱ្យបានឋិតថេរ (រយៈពេល ៣០ នាទី)
- ក្រុមនីមួយៗនឹងត្រូវបរិយាយអំពីចំណុចដែលខ្លួនបានធ្វើការសង្កេតថាពេញចិត្ត និងមិនពេញចិត្តអំពីការបង្ហាញជូននេះ (រយៈពេល ៣០ នាទី)



# បទបង្ហាញទី ៤.៣: ដំណាក់កាលទី ៣ ការបង្កើត និងការចងក្រងផែនការសកម្មភាព



ទំព័របង្ហាញទី ៤.៦

ដំណាក់កាលទី៣: ការបង្កើត និងការចងក្រងផែនការសកម្មភាព

- ការធ្វើសំយោគព័ត៌មាន និងការបង្កើតនូវជម្រើសផ្សេងៗ
  - ការធ្វើសង្ខេបព័ត៌មានដែលបានប្រមូល
  - ការកំណត់នូវលក្ខខណ្ឌ ឬកិច្ចការដែលចាំបាច់
  - ការកំណត់គោលដៅ
- ការបង្កើតផែនការសកម្មភាព
  - ផែនការដែលមានសរសេររៀបរាប់អំពីដំណាក់កាលដែលត្រូវអនុវត្តដើម្បីឈានទៅសម្រេចបានគោលដៅដែលបានគ្រោងទុក

នៅក្នុងដំណាក់កាលទី៣ នៃដំណើរការដោះស្រាយបញ្ហានេះ គឺជាដំណាក់កាលនៃការជួយតម្រង់ទិសដល់អតិថិជនដោយតម្រូវឱ្យមានការរៀបចំផែនការឱ្យបានត្រឹមត្រូវ ព្រមជាមួយសកម្មភាពជាក់ស្តែងសម្រាប់អតិថិជនយកទៅអនុវត្ត។ កិច្ចការដែលបានសម្រេចនៅក្នុងដំណាក់កាលទី១ និងទី២ គឺបានបញ្ជាក់យ៉ាងច្បាស់អំពីការលំបាកក្នុងការងារហៅថា "**ការពិនិត្យកំណត់ត្រាការលំបាកឡើងវិញ**" ។ ការពិនិត្យឡើងវិញនេះបានបង្កើតនូវគោលដៅនៃការប្រឹក្សាយោបល់ តាមរយៈការកំណត់អំពីចំណុចដែលតម្រូវឱ្យធ្វើការផ្លាស់ប្តូរ ឬកែសម្រួល ដើម្បីធ្វើជាគន្លឹះក្នុងការដោះស្រាយបញ្ហា។ មធ្យោបាយក្នុងការសម្រេចគោលដៅនោះ គឺការជជែកពិភាក្សា និងដំណោះស្រាយដែលជ្រើសរើសដោយអតិថិជន បានបង្កើតជាសកម្មភាពនានាដែលអាចនាំឱ្យអ្នកប្រឹក្សាយោបល់បង្កើតផែនការសកម្មភាពសម្រាប់អនុវត្ត។

<u>**សំយោគ:**</u> ការធ្វើសង្ខេបព័ត៌មានដែលប្រមូលបាន ដោយឆ្លុះបញ្ចាំងពីស្ថានភាពការងារ និងលទ្ធភាពដែលអាចធ្វើបានរបស់អតិថិជន។ ដោយមានការឯកភាពទៅលើចំណុចខាងលើ អតិថិជន និងអ្នកផ្តល់ប្រឹក្សាយោបល់ធ្វើការពិភាក្សាទៅលើចំណុចដែលចាំបាច់សម្រាប់អតិថិជនក្នុងការទទួលបានការងារធ្វើ។ ទន្ទឹមនឹងនោះ អ្នកទាំងពីរនឹងបង្កើតនូវគោលដៅជាក់លាក់ និងការពិនិត្យទៅលើជម្រើសដែលអាចរកបាននៅក្នុងសហគមន៍ ក្នុងគោលបំណង

ជួយដល់អតិថិជនឱ្យទទួលបានការងារធ្វើ។ អ្នកផ្តល់ប្រឹក្សាយោបល់ត្រូវបញ្ជាក់ឡើងវិញនូវចំណុចទាំងឡាយដែលអតិថិជនត្រូវការក្នុងទម្រង់ការបញ្ជាក់អំពីគោលដៅ។ "ឥឡូវនេះដើម្បីទទួលបានការងារជាជំនួយការផ្នែករដ្ឋបាលឱ្យបានឆាប់រហ័ស លោកអ្នកត្រូវបង្កើត ឬរៀបចំនូវបញ្ជីឈ្មោះនិយោជក និងត្រៀមនូវសំនួរចាំបាច់សម្រាប់ធ្វើការសាកសួរនិយោជក ក្នុងអំឡុងពេលធ្វើបទសម្ភាសន៍ការងារ"។

__ផែនការសកម្មភាព:__ ការបង្កើតផែនការសកម្មភាពដែលមានលក្ខណៈប្រាកដប្រជាជាដំណាក់កាលៗ ឬជាដំណាក់កាលចាប់ផ្តើមដែលអតិថិជនអាចស្វែងយល់ពីគោលដៅការងាររបស់ខ្លួន ហើយមានការព្រមព្រៀងគ្នារវាងអ្នកផ្តល់ប្រឹក្សាយោបល់ និងអតិថិជន។

គោលដៅចំបងនៃផែនការសកម្មភាព គឺដើម្បីឈានទៅសម្រេចបាននូវគោលដៅនៃការផ្តល់ប្រឹក្សាយោបល់ដែលផ្តល់លទ្ធភាពឱ្យអតិថិជនបង្កើននូវស្ថានភាពការងាររបស់ខ្លួន និងមានសមត្ថភាពគ្រប់គ្រាន់នៅក្នុងទីផ្សារការងារ។

នៅពេលអតិថិជនជ្រើសរើសយកជម្រើសណាមួយ នោះគឺជាការបោះជំហានទៅមុខក្នុងការបង្កើតផែនការសកម្មភាព។ ផែនការសកម្មភាព តម្រូវឱ្យមានលក្ខណៈជាក់លាក់ អាចវាស់វែងបាន អាចសម្រេចទៅបាន មានភាពជាក់ស្តែង និងទាន់ពេលវេលា (ប្រើអក្សរកាត់ថា SMART)។

ការចាប់ផ្តើមនៅក្នុងដំណាក់កាលទី៣ អ្នកផ្តល់ប្រឹក្សាយោបល់ត្រូវប្រាប់អតិថិជនឱ្យបានដឹងពីដំណាក់កាលនានាចំពោះការបង្កើតផែនការសកម្មភាព។ "ឥឡូវនេះ យើង(អ្នកផ្តល់ប្រឹក្សាយោបល់) បានជ្រាបអំពីស្ថានភាព និងការលំបាកក្នុងការងាររបស់លោកអ្នក តើលោកអ្នកគិតថាដល់វេលាដែលត្រូវបង្កើតផែនការសកម្មភាពជាក់លាក់ដែរឬទេ? យើងនឹងចាប់ផ្តើមពីការស្វែងរកដំណោះស្រាយចំពោះការលំបាកក្នុងការងារ ហើយបន្ទាប់មកយើងនឹងពិនិត្យកិច្ចអន្តរាគមន៍ណាមួយដែលអាចជួយលោកអ្នកមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រឈមនឹងការលំបាកទាំងនោះ" ។

ផែនការសកម្មភាព ត្រូវបានបង្កើតនៅក្នុងបែបផែនដែលភ្នាក់ងារផ្តល់សេវាដទៃទៀត អាចប្រើប្រាស់ទៅបាន។ នៅពេលដែលផែនការសកម្មភាពត្រូវបានបញ្ចប់ តួនាទីរបស់អ្នកផ្តល់ប្រឹក្សាយោបល់ គឺត្រូវប្រាកដថាអតិថិជននៅតែទទួលបានការលើកទឹកចិត្ត និងទំនាក់ទំនងជាប់ជានិច្ច។

# លំហាត់ទី ៤.៣ – ការបង្កើតផែនការសកម្មភាព

**រយៈពេល: ៧៥ នាទី**

គោលបំណង:

- ធ្វើឱ្យអតិថិជនមានការយល់ដឹង(ភាពស៊ាំ)អំពីដំណើរការរៀបចំផែនការសកម្មភាព

សេចក្តីណែនាំ:

- ធ្វើការបែងចែកជាក្រុមពិភាក្សាដែលមានសមាជិក ០៣ នាក់
- ការបំពេញនូវទម្រង់របស់អតិថិជនដែលមានគូសបញ្ជាក់នៅក្នុង **ឯកសារទី ៤.២**។ ការកំណត់អំពីគោលដៅនៃការផ្តល់ប្រឹក្សាយោបល់ និងកិច្ចអន្តរាគមន៍ដែលត្រូវរួមបញ្ចូលនៅក្នុងផែនការសកម្មភាព (រយៈពេល ៤៥ នាទី)
- ការបំពេញនូវតារាងផែនការសកម្មភាព (**ឯកសារទី ៤.៤**) (រយៈពេល ១៥ នាទី)
- ការពិភាក្សាអំពីជម្រើសនៃកិច្ចអន្តរាគមន៍ (រយៈពេល ១៥ នាទី)



# បទបង្ហាញទី ៤.៤: ដំណាក់កាលទី ៤
# ការអនុវត្ត និងការតាមដាន (Follow-up)



**ទំព័របង្ហាញទី ៤.៧**

**ដំណាក់កាលទី ៤: ការអនុវត្ត និងការតាមដាន** (Follow-up)

- ការអនុវត្ត-បទអន្តរាគមន៍
  - ការកំណត់នូវបទអន្តរាគមន៍ទាំងឡាយដែលចាំបាច់ក្នុងការឈានទៅសម្រេចបាននូវគោលដៅការងារ
  - រាល់បទអន្តរាគមន៍ទាំងអស់នឹងត្រូវបញ្ចូលនៅក្នុងផែនការសកម្មភាពជាមួយនឹងលទ្ធផលរំពឹងទុក និងកាលបរិច្ឆេទច្បាស់លាស់

**<u>កិច្ចអន្តរាគមន៍:</u> អាចមានទំនាក់ទំនងមួយ ឬច្រើនទៅនឹងទំហំលទ្ធភាពទទួលបានការងារធ្វើ:**

កត្តាបុគ្គលខ្លួនឯង/បរិស្ថានជុំវិញខ្លួន ការសម្រេចចិត្តចាប់យកអាជីព ការបង្កើនជំនាញ ការស្វែងរកការងារធ្វើ ឬការថែរក្សាការងារឱ្យនៅឋិតថេរ។ គោលបំណងនៅក្នុងចំណុចនេះ គឺការជួយជ្រោមជ្រែងដល់អតិថិជនដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដោះស្រាយនូវរាល់ការលំបាកដែលបានកត់ត្រាទុក។

បទអន្តរាគមន៍ដែលមាននៅក្នុងផែនការសកម្មភាព អាចរួមបញ្ចូលនូវ: ការធ្វើតេស្តសាកល្បងឥរិយាបថ និងចំណង់ចំណូលចិត្ត ការប្រឹក្សាយោបល់ការងារ ការបណ្តុះបណ្តាលការអាន និងសរសេរ ការបណ្តុះបណ្តាលវិជ្ជាជីវៈវគ្គខ្លី ឬវែង ការបណ្តុះបណ្តាលជំនាញស្វែងរកការងារធ្វើ (សិក្ខាសាលា ឬក្លឹបស្វែងរកការងារធ្វើ)។ សកម្មភាពទាំងនេះ អាចស្ថិតក្នុងទម្រង់មួយទល់មួយ ឬជាក្រុម។ ការផ្តល់ប្រឹក្សាយោបល់ អាចនឹងត្រូវធ្វើឡើងនៅពេលជួបគ្នាលើកក្រោយ។



# បទបង្ហាញទី ៤.៤.១: ការអាស្រ័យទៅលើធនធាននៅក្នុងសហគមន៍



ទំព័របង្ហាញទី ៤.៨

- ការអនុវត្ត - ធនធាននៅក្នុងសហគមន៍
  - ✓ តើធនធាននៅក្នុងសហគមន៍មួយណាដែលអាចជួយដល់អតិថិជនក្នុងការឈានទៅសម្រេចបាននូវគោលដៅប្រឹក្សាយោបល់?
  - ✓ ប្រភេទសេវាចំនួន ៣ សំខាន់ៗដែលផ្តល់ដោយអង្គការ (អង្គភាព)ក្នុងតំបន់:
    - ការគាំទ្រដល់ការប្រឹក្សាយោបល់អាជីព
    - ការទទួលបានជំនាញ
    - ការជួយគាំទ្រដល់ការថែរក្សាការងារឱ្យបានឋិតថេរ

<u>**ធនធាននៅក្នុងសហគមន៍:**</u> ធនធានដែលមាននៅក្នុងសហគមន៍អាចផ្តល់ជាសេវាដល់អតិថិជន ដើម្បីឱ្យអ្នកទាំងនោះឈានទៅដល់គោលដៅនៃការប្រឹក្សាយោបល់របស់ខ្លួន។ កិច្ចអន្តរាគមន៍ដែលបានបង្ហាញជូនខាងលើជាធម្មតាត្រូវបានផ្តល់នៅតាមទីតាំងផ្សេងគ្នានៅក្នុងសហគមន៍ ក៏ប៉ុន្តែមិនមែនគ្រប់សហគមន៍ទាំងអស់ផ្តល់ជូននូវសេវាដូចគ្នានោះទេ។ នៅក្នុងសហគមន៍មានកន្លែងជាច្រើនដែលផ្តល់សេវាជួយដល់អតិថិជនក្នុងការចូលទៅកាន់ទីផ្សារការងារឡើងវិញដូចជា៖ អាគារសិក្សាអប់រំ/បណ្តុះបណ្តាល អង្គការមិនមែនរដ្ឋាភិបាល មជ្ឈមណ្ឌលការងារ។



# លំហាត់ទី ៤.៤.១
# ធនធានសហគមន៍នៅប្រទេសកម្ពុជា



រយៈពេល: ៥០ នាទី

គោលបំណង:

- ការស្វែងយល់អំពីសក្តានុពលនៃធនធានសហគមន៍នៅក្នុងតំបន់របស់លោកអ្នក

សេចក្តីណែនាំ:

- ធ្វើការបែងចែកជាក្រុមពិភាក្សាដែលមានសមាជិក ០៥ នាក់
- ចែកជូនឯកសារទី ៤.១.១ និងធ្វើការពិភាក្សាអំពីធនធានសហគមន៍ដែលអាចផ្តល់សេវាដូចជា៖ ១.ការគ្រប់គ្រងខ្លួនឯង ២. ការគាំទ្រក្នុងការផ្តល់ប្រឹក្សាយោបល់អាជីព ៣. ការទទួលបានជំនាញ ៤.ការស្វែងរកការងារធ្វើ និង ៥. ការថែរក្សាការងារឱ្យបានឋិតថេរ (រយៈពេល ៣០ នាទី)
- ក្រុមពិភាក្សានីមួយៗត្រូវធ្វើការរៀបរាប់បន្ថែមអំពីអង្គការ (អង្គភាព) នៅក្នុងសហគមន៍របស់ខ្លួន ដោយរួមបញ្ចូលទាំងសេវាដែលអង្គការ (អង្គភាព) ទាំងនោះអាចផ្តល់ជូនដល់អតិថិជន ហើយអ្នកផ្តល់ការបណ្តុះបណ្តាល និងសរសេរនៅលើក្រដាសដែលបានចែកជូន (រយៈពេល ២០ នាទី)
- តារាងនឹងត្រូវបង្កើតឡើង និងធ្វើការចែកជូនលោកអ្នក (សិក្ខាកាម) និងអតិថិជនរបស់ខ្លួនក្នុងអំឡុងពេលបង្កើតផែនការសកម្មភាពរបស់អ្នកទាំងនោះ



# បទបង្ហាញទី ៤.៥: ការពិនិត្យអំពីលទ្ធផលដែល សម្រេចបាននៃគោលដៅប្រឹក្សាយោបល់



**ទំព័របង្ហាញទី ៤.៩**

- ការតាមដាន (Follow-up)
  - តើមានអ្វីនឹងកើតឡើងបន្ទាប់ពីការជួបពិភាក្សាលើកដំបូង?
  - កំណត់ពីរបៀបផែនក្នុងការតាមដានដែលនឹងត្រូវអនុវត្ត
- ការតាមដាន – ការពិនិត្យមើលលទ្ធផលដែលសម្រេចបាននៃគោលដៅប្រឹក្សាយោបល់
  - តើអតិថិជនបានបំពេញបទអន្តរាគមន៍កម្មវិធីមួយ ឬកម្មវិធីទាំងអស់ដែរឬទេ?
  - តើគោលដៅនៃការប្រឹក្សាយោបល់បានទទួលជោគជ័យដែរឬទេ?

__ការតាមដាន:__ លទ្ធផលដែលសម្រេចបាននៅក្នុងដំណាក់កាលមុនមិនទាន់គ្រប់គ្រាន់នោះទេ ប្រសិនបើមិនទាន់ធ្វើការពិនិត្យ ប្រសិនបើផែនការសកម្មភាពកំពុងអនុវត្ត និងគោលដៅនៃការប្រឹក្សាយោបល់ត្រូវបានសម្រេច។ ការតាមដាន គឺជាកូនសោរគន្លឹះក្នុងការអនុវត្តផែនការសកម្មភាព ដោយពាក់ព័ន្ធទៅនឹងការពិនិត្យថា តើសកម្មភាពទាំងឡាយដែលបានរៀបចំឡើងត្រឹមត្រូវដែរឬទេ? ហើយថាតើសកម្មភាពទាំងនេះត្រូវបានអនុវត្ត ឬបញ្ចប់?។ ឧទាហរណ៍អំពីរបៀបតាមដានដែលត្រូវអនុវត្ត : អតិថិជនបានឯកភាពចូលរួមនៅក្នុងបទអន្តរាគមន៍ ហើយជូនដំណឹងទៅកាន់អ្នកផ្តល់ប្រឹក្សាយោបល់ដើម្បីធ្វើការពិភាក្សាអំពីលទ្ធផល និងបទអន្តរាគមន៍នាពេលបន្ទាប់។ អ្នកផ្តល់ប្រឹក្សាយោបល់អាចធ្វើការតាមដានតាមរយៈទូរស័ព្ទជារៀងរាល់ខែ (ឬច្រើនដង) ក្នុងករណីដែលអតិថិជនកំពុងជួបបញ្ហាដោយមិនអាចបំពេញបទអន្តរាគមន៍បាន។

__**លទ្ធផលដែលសម្រេចបាន:**__ នៅក្នុងការអនុវត្តនូវសកម្មភាពដែលបានឯកភាពគ្នានៅក្នុងផែនការសកម្មភាព យើងសង្កេតឃើញមានអតិថិជនមួយចំនួនបានយល់ថាសកម្មភាពទាំងនោះមិនអាចអនុវត្តទៅបាន ឬធ្វើការផ្លាស់ប្តូរគំនិតរបស់ខ្លួនដែលពាក់ព័ន្ធទៅនឹងគោលដៅនៃការប្រឹក្សាយោបល់។ ទោះជាយ៉ាងនេះក្តី តួនាទីរបស់អ្នកប្រឹក្សាយោបល់ គឺលើកទឹកចិត្ត និងផ្តល់ការគាំទ្រដល់អតិថិជន។

ការពិនិត្យទៅលើលទ្ធផលដែលសម្រេចបាននូវគោលដៅនៃការប្រឹក្សាយោបល់ បាននាំទៅដល់ការបង្ហាញមួយ ឬពីរ រួមមាន៖ ១. គោលដៅនៃការប្រឹក្សាយោបល់ត្រូវសម្រេចជាស្ថាពរ ឬ ២. សម្រេចមិនបាន

១. ភាគីទាំងសងខាងត្រូវកំណត់ឱ្យបានច្បាស់លាស់ ប្រសិនបើអតិថិជនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានការងារធ្វើដែលស្របទៅនឹងគោលដៅនៃការប្រឹក្សាយោបល់បានកំណត់

២. នៅពេលគោលដៅនៃការប្រឹក្សាយោបល់សម្រេចមិនបាន អតិថិជន និងអ្នកផ្តល់ប្រឹក្សាយោបល់ត្រូវចំណាយពេលដើម្បីពិនិត្យអំពីស្ថានភាពឡើងវិញ តើគោលដៅនៃការប្រឹក្សាយោបល់សក្តិសមដែរឬទេ? តើផែនការសកម្មភាពមានលក្ខណៈប្រាកដប្រជាដែរឬទេ? ការយល់ដឹងអំពីមូលហេតុដែលមិនអាចសម្រេចទៅបាន បានក្លាយទៅជាកិច្ចការដែលត្រូវអនុវត្តរួមគ្នារវាងអតិថិជន និងអ្នកផ្តល់ប្រឹក្សាយោបល់ ដោយក្នុងនោះត្រូវគិតទុកជាមុនចំពោះបែបផែននៃការសហការរវាងភាគីទាំងពីរ។



## បទបង្ហាញទី ៤.៦: ការកំណត់អំពីភាពគ្រប់គ្រាន់របស់អតិថិជនក្នុងការទទួលបានការងារធ្វើ



ទំព័របង្ហាញទី ៤.១០

- ការតាមដាន (Follow-up)–ការកំណត់អំពីសមត្ថភាពគ្រប់គ្រាន់របស់អតិថិជន
  - ✓ អតិថិជន និងអ្នកផ្តល់ប្រឹក្សាយោបល់ធ្វើការវាយតម្លៃប្រសិនបើគោលដៅនៃការប្រឹក្សាយោបល់អាចសម្រេចទៅបាន និងអំពីសមត្ថភាពគ្រប់គ្រាន់របស់អតិថិជនក្នុងការទទួលបានការងារធ្វើ
  - ✓ **មានសមត្ថភាពគ្រប់គ្រាន់** បានន័យថាអតិថិជនអាចសម្រេចគោលដៅដោយខ្លួនឯង មួយណាក៏បាននៅក្នុងទំហំលទ្ធភាពការងារទាំង០៥

មានសមត្ថភាពគ្រប់គ្រាន់ត្រូវបានកត់ត្រាទុក នៅពេលដែលអតិថិជនលែងត្រូវការសេវាពីសំណាក់អ្នកផ្តល់ប្រឹក្សាយោបល់ ព្រោះអ្នកទាំងនោះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការសម្រេចគោលដៅដោយខ្លួនឯងណាមួយក៏បាន នៅក្នុងទំហំលទ្ធភាពការងារទាំង០៥ ។ អ្នកផ្តល់ប្រឹក្សាយោបល់ ត្រូវធ្វើការបញ្ជាក់ពីគោលគំនិតរបស់អតិថិជនដែលយល់ថាមានសមត្ថភាពគ្រប់គ្រាន់ តាមរយៈការពិនិត្យឡើងវិញអំពីសកម្មភាពដែលបានបំពេញ គោលដៅដែលសម្រេចបាន និងកាលៈទេសៈផ្សេងៗដែលពាក់ព័ន្ធទៅនឹងទំហំលទ្ធភាពការងារណាមួយ។

មានសមត្ថភាពគ្រប់គ្រាន់ត្រូវបានបញ្ជាក់នៅពេលដែលអតិថិជនៈ

- បានធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសការងារ ឬអាជីព
- បានបង្ហាញពីជំនាញ និងចំណេះដឹងសម្រាប់បំពេញការងារ
- បានចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការស្វែងរកការងារធ្វើ និង
- នៅក្នុងអំឡុងពេលគ្មានការងារធ្វើបានចូលរួមយ៉ាងសកម្មក្នុងការចូលរួមអភិវឌ្ឍជំនាញថែរក្សាការងារ និងថែរក្សាការងារដោយខ្លួនឯង

ការផ្តល់ប្រឹក្សាយោបល់ត្រូវបានបញ្ចប់នៅពេលអតិថិជនមានការងារធ្វើ មានសមត្ថភាពគ្រប់គ្រាន់ ឬនៅពេលអ្នកទាំងនោះបដិសេធមិនព្រមបន្តដំណើរការនៃការប្រឹក្សាយោបល់។

# លំហាត់ទី ៤.៥ –តើអតិថិជនបានសម្រេចគោលដៅនៃការប្រឹក្សាយោបល់ដែរឬទេ?

**រយៈពេល: ៧៥នាទី**

**គោលបំណង:**

- ជួយដល់សិក្ខាកាមកំណត់នៅពេលគោលដៅនៃការប្រឹក្សាយោបល់បានសម្រេច
- ការពិនិត្យទៅលើជម្រើសសម្រាប់អតិថិជន ក្នុងករណីដែលអ្នកទាំងនោះមិនអាចបំពេញបាននូវបទអន្តរាគមន៍ ឬសម្រេចបាននូវគោលដៅនៃការប្រឹក្សាយោបល់

**សេចក្តីណែនាំ:**

- ធ្វើការបែងចែកជាក្រុមពិភាក្សាដែលមានសមាជិក ៣ នាក់
- បំពេញទម្រង់សម្រាប់អតិថិជន (ឯកសារទី ៤.៥) ដោយធ្វើការកំណត់នូវលទ្ធភាពដែលអាចធ្វើបានចំនួន ២ (រយៈពេល ៣០ នាទី) និងប្រើប្រាស់នូវទម្រង់តាមដាន (Follow-up) នៃបទអន្តរាគមន៍ (ឯកសារទី ៤.៦)
- សិក្ខាកាមគ្រប់រូប នឹងត្រូវធ្វើបទបង្ហាញមួយក្នុងចំណោមទម្រង់ផ្សេងៗដែលបានបញ្ចប់ ទៅកាន់ក្រុមពិភាក្សា។ ចំពោះក្រុមពិភាក្សាដទៃទៀតនឹងប្រើប្រាស់តារាងសង្កេតការណ៍ (ឯកសារទី ៤.៧) ដើម្បីផ្តល់ព័ត៌មានត្រលប់ទៅកាន់អ្នកធ្វើបទបង្ហាញ (រយៈពេល ៤៥ នាទី)

# ឯកសារទី ៤.១
# តារាងសង្ខេបការទី ១

<u>ការបង្កើតទំនាក់ទំនង</u>

តើអ្នកផ្តល់ប្រឹក្សាយោបល់បាន...

- ☐ ស្វាគមន៍អតិថិជនប្រកបដោយភាពកក់ក្តៅ
- ☐ បង្កភាពងាយស្រួលដល់អតិថិជន
- ☐ បង្ហាញពីភាពជឿទុកចិត្ត

សូមបញ្ជាក់ពី ☐ សេចក្តីរំពឹងទុក

- ☐ តួនាទី
- ☐ គោលបំណង និងលទ្ធផលនៃការធ្វើបទសម្ភាសន៍

- ☐ យល់ដឹងអំពីការគិតរបស់អតិថិជនទៅលើបញ្ហា និងស្ថានភាពការងារនាពេលបច្ចុប្បន្ន
- ☐ បញ្ហាផ្សេងៗ________________________________________________

<u>ការកំណត់អំពីអតិថិជន</u>

តើអ្នកផ្តល់ប្រឹក្សាយោបល់បាន...

- ☐ ស្តាប់នូវចំណុចទាំងឡាយដែលអតិថិជនយល់ថាគួរការពារខ្លួនបែបបណាដើម្បីសម្រេចបានគោលដៅការងារ
- ☐ យល់ដឹងពីអារម្មណ៍របស់អតិថិជនចំពោះស្ថានភាពនេះ
- ☐ កំណត់អំពីបញ្ហាដែលរាំងស្ទះដល់អតិថិជន
- ☐ កំណត់អំពីបញ្ហាបន្ទាន់ណាមួយដែលទប់ស្កាត់អតិថិជនពីការចាប់ផ្តើមប្រតិបត្តិ
- ☐ បញ្ហាផ្សេងៗ________________________________________________

# ឯកសារទី ៤.២
# កម្រងរឿងរបស់អតិថិជន

**អ្នកផ្តល់ប្រឹក្សាយោបល់:** សួស្តី អ្នកស្រីហ៊ីង! ខ្ញុំឈ្មោះកាន គន្ធី ជាមន្ត្រីមជ្ឈមណ្ឌលការងារ។ សូមអញ្ជើញអង្គុយ។

**អតិថិជន:** សូមអរគុណ!

**អ្នកផ្តល់ប្រឹក្សាយោបល់:** ចំពោះការធ្វើដំណើរមកមជ្ឈមណ្ឌលការងារ តើអ្នកស្រីមានការលំបាកក្នុងការស្វែងរកដែរឬទេ?

**អតិថិជន:** មិនមានទេ! លោកបានណែនាំផ្លូវមកកាន់មជ្ឈមណ្ឌលការងារបានច្បាស់លាស់ណាស់

**អ្នកផ្តល់ប្រឹក្សាយោបល់:** តើអ្នកស្រីមានបញ្ហាអ្វីដែរ?

**អតិថិជន:** ខ្ញុំអត់មានការងារធ្វើរយៈពេល ៦ ខែកន្លងមកហើយ ខ្ញុំសង្ឃឹមថាលោកនឹងអាចជួយខ្ញុំក្នុងការស្វែងរកការងារធ្វើ។ (***ការលំបាកទី១ ត្រូវបានកំណត់–ត្រូវការជំនួយក្នុងការស្វែងរកការងារធ្វើ***)

**អ្នកផ្តល់ប្រឹក្សាយោបល់:** ខ្ញុំសប្បាយរីករាយនឹងជួយដល់អ្នកស្រី។ ខ្ញុំមានជំនឿថាការសហការ យើងពិតជារកឃើញនូវមធ្យោបាយដែលជួយដល់អ្នកស្រីឱ្យវិលត្រលប់ទៅកាន់ទីផ្សារការងារវិញ។ ***(ការលើកទឹកចិត្ត)*** នាពេលកន្លងមក តើអ្នកស្រីបានព្យាយាមសាកល្បងធ្វើអ្វីខ្លះ?

**អតិថិជន:** ចាប់តាំងពីខ្ញុំបាត់បង់ការងារជាអ្នកដំឡើងគ្រឿងអេឡិចត្រូនិចនៅពេលដែលរោងចក្របិទទ្វារមក ខ្ញុំមិនទាន់ស្វែងរកការងារធ្វើបានសោះ។ ក្រៅពីមានជំនាញជាអ្នកដំឡើងគ្រឿងអេឡិចត្រូនិច ខ្ញុំមិនចេះធ្វើការងារអ្វីផ្សេងទៀតទេ ម្យ៉ាងវិញទៀតនៅក្នុងតំបន់នេះមិនសូវមាននិយោជកបែបនេះច្រើនទេ។ (***ការលំបាកទី២ ត្រូវបានកំណត់-ពុំមានជំនាញដែលអាចផ្លាស់ប្តូរការងារបាន***) លោកដឹងទេ ខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបំពេញការងារ ខ្ញុំមានបទពិសោធន៍ជាង ២០ ឆ្នាំ ក៏ប៉ុន្តែខ្ញុំមិនដឹងថាគួរទៅរកកន្លែងណា។ (***ការលំបាកទី៣ ត្រូវបានកំណត់ -នាងមិនដឹងពីវិធីសាស្ត្រស្វែងរកនិយោជកដែលចង់បាន***)

**អ្នកផ្តល់ប្រឹក្សាយោបល់:** ខ្ញុំដឹងថា វាមានការលំបាកការបាត់បង់ការងារដែលធ្លាប់បម្រើការជាង២០ឆ្នាំ នៅក្នុងក្រុមហ៊ុនតែមួយ និងជំនាញដដែលនោះ។ ទីផ្សារការងារមានការប្រែប្រួល ហើយការងាររបស់អ្នកស្រីប្រហែលជាមិនមានតម្រូវការនៅក្នុងទីក្រុងភ្នំពេញនោះទេ។ ***(ការសង្ខេប និងការវែកញែក)***

**អតិថិជន:** ត្រឹមត្រូវណាស់! ខ្ញុំមានអារម្មណ៍អស់សង្ឃឹមចំពោះស្ថានភាពកំពុងជួបប្រទះ និងមានភាពអន្ទះសារចំពោះការវិលត្រលប់ទៅកាន់ការងារនាពេលខាងមុខ។ ***(អារម្មណ៍របស់អតិថិជន)***

**អ្នកផ្តល់ប្រឹក្សាយោបល់:** ខ្ញុំដឹងថា អ្នកស្រីកំពុងមានអារម្មណ៍អស់សង្ឃឹម និងមិនសប្បាយចិត្តចំពោះស្ថានភាពដែលអ្នកកំពុងជួបប្រទះ។ ***(ឆ្លុះបញ្ចាំងពីអារម្មណ៍)*** រយៈពេល ៦ ខែ គឺជារយៈពេលមួយដែលយូរ។ តើអ្នកស្រីធ្លាប់បានស្វែងរកការងារក្នុងប្រភេទជាអ្នកដំឡើងគ្រឿងអេឡិចត្រូនិចដែរឬទេ?

**អតិថិជន:** តាមពិតទៅ ខ្ញុំមិនដឹងពីរបៀបនៃការស្វែងរកការងារធ្វើនោះទេ។ ខ្ញុំបានពិភាក្សាជាមួយមិត្តភក្តិ និងក្រុមគ្រួសារអំពីស្ថានភាពរបស់ខ្ញុំ។ នេះជាកិច្ចការដែលខ្ញុំបានធ្វើកន្លងមក។ ខ្ញុំត្រូវចង់ទៅបម្រើការអ្នកដំឡើងគ្រឿងអេឡិចត្រូនិចដែលជាការងារតែមួយគត់ដែលខ្ញុំធ្លាប់ធ្វើ។ ***(ស្វែងយល់ពីការរំពឹងទុកនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ ជាផ្នែកនៅក្នុងដំណាក់កាលទី២)***

**អ្នកផ្តល់ប្រឹក្សាយោបល់:** តើអ្នកស្រីត្រូវការឱ្យខ្ញុំធ្វើការពិនិត្យ (ពិភាក្សា) ទៅលើស្ថានភាពនាពេលបច្ចុប្បន្នរបស់អ្នកស្រីជាមួយគ្នា និងធ្វើការកំណត់អំពីវិធីសាស្ត្រក្នុងការស្វែងរកការងារធ្វើរបស់អ្នកស្រីឱ្យកាន់តែប្រសើរឡើងបានដែរឬទេ?

**អតិថិជន:** ចាស! នេះគឺជាមូលហេតុដែលខ្ញុំមកកាន់ទីនេះ។

-------------------- ចប់ដំណាក់កាលទី១ --------------------

**អ្នកផ្តល់ប្រឹក្សាយោបល់:** នៅពេលដែលអ្នកស្រីនិយាយថា អ្នកស្រីនៅតែចូលចិត្តធ្វើការជាអ្នកដំឡើងគ្រឿងអេឡិចត្រូនិច ព្រោះតែជាការងារតែមួយគត់ដែលអ្នកស្រីធ្លាប់ធ្វើ តើមានន័យថាអ្នកស្រីអាចចាប់អារម្មណ៍ទៅលើកិច្ចការផ្សេងទៀត ក៏ប៉ុន្តែអ្នកស្រីមិនចង់ស្វែងយល់ពីជម្រើសទាំងនោះ ពីព្រោះអ្នកស្រីមិនមានជំនាញផ្សេងពីនេះ។

**អតិថិជន:** មិនមែនទេ ខ្ញុំពិតជាពេញចិត្តធ្វើការជាអ្នកដំឡើងគ្រឿងអេឡិចត្រូនិច ហើយចង់ត្រឡប់ទៅកាន់ការងារក្នុងជំនាញនោះវិញណាស់។ ***(ស្វែងយល់ពីការរំពឹងទុកនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ-បន្ត)***

**អ្នកផ្តល់ប្រឹក្សាយោបល់:** ជាការប្រសើរណាស់ ដែលអ្នកស្រីពេញចិត្តជាមួយប្រភេទការងារនោះ។ តើអ្នកស្រីអាចប្រាប់ខ្ញុំបានទេ ថាតើអ្នកស្រីមានលក្ខណៈសម្បត្តិអ្វីខ្លះក្នុងការធ្វើជាអ្នកដំឡើងគ្រឿងអេឡិចត្រូនិចនោះ?

**អតិថិជន:** ខ្ញុំមានបទពិសោធន៍ជាង ២០ឆ្នាំ ក្នុងជំនាញនេះ ហើយខ្ញុំបានទទួលសញ្ញាបត្រផ្នែកដំឡើងគ្រឿងអេឡិចត្រូនិចនៅមហាវិទ្យាល័យក្នុងស្រុកឆ្នាំ១៩៨៨។ ថ្លៃសិក្សារបស់ខ្ញុំនិយោជកជាអ្នកចំណាយ។ ខ្ញុំក៏បានផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកថ្មីកាលពី ៤ ឆ្នាំមុន ហើយខ្ញុំជាប្រធានក្រុមនៅក្នុងផ្នែកនេះ។ (***អតិថិជនមានគោលដៅការងារច្បាស់លាស់ និងមានការអប់រំ និងជំនាញចាំបាច់ដើម្បីធ្វើការនេះ***) ខ្ញុំក៏ជាអ្នកស្ម័គ្រចិត្តដោយបានចំណាយពេលវេលា ២ ដងក្នុងមួយសប្តាហ៍នៅសហគមន៍។ ខ្ញុំបានបង្រៀនដល់ក្មេងគ្រប់វ័យពីរបៀបលេងបាល់ឱប។ ខ្ញុំរីករាយធ្វើការជាមួយមនុស្សគ្រប់វ័យ។

**អ្នកផ្តល់ប្រឹក្សាយោបល់:** អ្នកស្រីពិតជាមានជំនាញទំនាក់ទំនងល្អក្នុងការបណ្តុះបណ្តាលមនុស្ស និងធ្វើការជាមួយកុមារ។ អ្នកស្រីមានជំនាញគ្រប់បែបយ៉ាងក្នុងនាមជាអ្នកដំឡើងគ្រឿងអេឡិចត្រូនិច ឬជាអ្នកត្រួតពិនិត្យ។ ឥឡូវនេះតើអ្នកស្រីកំពុងស្វែងរកការងារធ្វើក្នុងតំបន់មែនឬ?

**អតិថិជន:** ចាស! ប្រសិនបើមាន

**អ្នកផ្តល់ប្រឹក្សាយោបល់:** តើអ្នកស្រីយល់ដឹងពីការស្វែងរកការងារធ្វើអ្វីខ្លះ?

**អតិថិជន:** មិនច្រើនប៉ុន្មានទេ! ខ្ញុំគ្រាន់តែដឹងថាខ្ញុំត្រូវជួបនិយោជក ហើយប្រគល់ប្រវត្តិរូបសង្ខេបឱ្យអ្នកទាំងនោះ។ ជាធម្មតា មនុស្សដែលអាចជួយឱ្យស្វែងរកនិយោជកបាន គឺជាក្រុមគ្រួសារ និងមិត្តភ័ក្រ្ត។

**អ្នកផ្តល់ប្រឹក្សាយោបល់:** តើអ្នកស្រីបានត្រៀមខ្លួនជួបជាមួយនិយោជកហើយឬនៅ?

**អតិថិជន:** ខ្ញុំបានជួបនិយោជកម្នាក់ ក៏ប៉ុន្តែគាត់មិនត្រូវការបុគ្គលិកនោះទេ។

**អ្នកផ្តល់ប្រឹក្សាយោបល់:** តើអ្នកស្រីបានធ្វើអ្វីខ្លះ?

**អតិថិជន:** ខ្ញុំបានអរគុណគាត់ចំពោះការណាត់ជួប ហើយខ្ញុំបានចាកចេញ។

**អ្នកផ្តល់ប្រឹក្សាយោបល់:** តើអ្នកស្រីបានធ្វើអ្វីបន្ថែមទៀតទេ ចាប់តាំងពីអ្នកស្រីបាត់បង់ការងារ?

**អតិថិជន:** មិនមានទេ ពីព្រោះខ្ញុំមិនមានរថយន្ត និងមិនយល់ពីរបៀបធ្វើដំណើរ(រថយន្តក្រុង ឬរទេះភ្លើងជាដើម)។

***(អតិថិជនត្រូវការជំនួយអំពីបញ្ហាដឹកជញ្ជូន)***

**អ្នកផ្តល់ប្រឹក្សាយោបល់:** បើតាមខ្ញុំយល់អ្នកស្រីមានការលំបាកក្នុងការស្វែងរកការងារធ្វើ ពីព្រោះមិនដឹងពីនិយោជកនៅក្នុងតំបន់ និងមិនដឹងពីចំណុចដែលនឹងត្រូវនិយាយទៅកាន់និយោជកក្នុងការលើកទឹកចិត្តអ្នកទាំងនោះជ្រើសរើសអ្នកស្រីឱ្យបម្រើការងារ។ ទន្ទឹមនឹងនេះ អ្នកស្រីមានការលំបាកក្នុងការចុះជួបនិយោជកពីព្រោះបញ្ហាធ្វើដំណើរ។

**អតិថិជន:** ត្រឹមត្រូវណាស់! ក៏ប៉ុន្តែនាពេលនេះ ខ្ញុំត្រៀមធ្វើអ្វីគ្រប់យ៉ាងដើម្បីទទួលបានការងារធ្វើ។

**អ្នកផ្តល់ប្រឹក្សាយោបល់:** ប្រសិនបើអ្នកស្រីត្រូវបាននិយោជកផ្តល់ការងារឱ្យនៅថ្ងៃស្អែក តើអ្នកស្រីគិតអំពីមូលហេតុដែលអ្នកមិនអាចទទួលការងារនោះបានឬទេ?

**អតិថិជន:** ពុំមានទេ!

-------------------- **ចប់ដំណាក់កាលទី២** --------------------

# ឯកសារទី ៤.៣

# តារាងសង្ខេបទី ២

<u>ស្វែងយល់ពីការរំពឹងទុកនៃការបណ្តុះបណ្តាលវិជ្ជាជីវនាពេលបច្ចុប្បន្ន</u>

តើអ្នកផ្តល់ប្រឹក្សាយោបល់:

- ☐ សាកសួរអតិថិជនអំពីគោលដៅនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ☐ ព្យាយាមកំណត់អំពីវិធីសាស្ត្រដែលអតិថិជនជ្រើសរើសគោលដៅអាជីព
- ☐ ព្យាយាមជួយដល់អតិថិជនក្នុងការកំណត់អំពីគោលដៅអាជីព (ប្រសិនបើមិនមានកំណត់ពីមុន)
- ☐ ពិនិត្យទៅលើជំនាញដែលអាចផ្លាស់ប្តូរបាន ដើម្បីជួយដល់អតិថិជនកំណត់អំពីគោលដៅនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ☐ បញ្ហាផ្សេងៗ____________________________________________

<u>ការកំណត់ និងការវាយតម្លៃទៅលើជំនាញការងារជាក់លាក់</u>

តើអ្នកផ្តល់ប្រឹក្សាយោបល់:

- ☐ ស្វែងយល់ដោយលម្អិតអំពីការងារដែលពាក់ព័ន្ធទៅនឹងជំនាញ
- ☐ ការពិនិត្យទៅលើជំនាញទុន (ការទំនាក់ទំនង...) និងជំនាញរឹង (បច្ចេកទេស...)
- ☐ សាកសួរពីជំនាញដែលទទួលបានពីសកម្មភាពផ្សេងៗ (ការងារស្ម័គ្រចិត្តជាដើម)
- ☐ សាកសួរសំនួរដែលទាក់ទងទៅនឹងការសិក្សាអប់រំ និងការបណ្តុះបណ្តាលដទៃទៀត
- ☐ បញ្ហាផ្សេងៗ ____________________________________________

<u>ការវាយតម្លៃទៅលើការត្រៀមខ្លួនរួចជាស្រេចក្នុងការស្វែងរកការងារធ្វើ និងការថែរក្សាការងារឱ្យបានឋិតថេរ</u>

តើអ្នកផ្តល់ប្រឹក្សាយោបល់:

- ☐ សាកសួរសំនួរដែលទាក់ទងនឹងដំណាក់កាលដែលបានអនុវត្តនៅក្នុងការស្វែងរកការងារធ្វើ
- ☐ ការពិនិត្យទៅលើបញ្ហាដទៃទៀតដែលជះឥទ្ធិពលដល់លទ្ធភាពក្នុងការស្វែងរក ឬថែរក្សាការងារឱ្យបានឋិតថេរ
- ☐ ការពិនិត្យទៅលើការលើកទឹកចិត្តអតិថិជនក្នុងការស្វែងរកការងារធ្វើ
- ☐ ការត្រួតពិនិត្យទៅលើតម្រូវការគាំទ្រក្នុងការស្វែងរកការងារធ្វើ និងថែរក្សាការងារឱ្យបានឋិតថេរ
- ☐ បញ្ហាផ្សេងៗ ____________________________________________

# ឯកសារទី ៤.៤
# ផែនការសកម្មភាពការងារ

នាមត្រកូល:______________________ នាមខ្លួន______________________
អាសយដ្ឋាន: ______________________________________________
ក្រុង: ______________________ លេខទូរស័ព្ទ: ______________________

ភ្នាក់ងារចូលរួម:

បញ្ហាបុគ្គលខ្លួនឯង/បរិស្ថានជុំវិញខ្លួន (ឧ: ការថែទាំកុមារ សុខភាព មេផ្ទះ):

តម្រូវការ: ______________________________________________

គោលដៅការងារ (រយៈពេលខ្លី/វែង បើសិនអាចអនុវត្តបាន): : ______________________

តម្រូវការ: ______________________________________________

ការសិក្សាអប់រំ និងការបណ្ដុះបណ្ដាល (រួមមាន អាថ្លាប័ណ្ណ វិញ្ញាបនបត្រ និងសញ្ញាបត្រ):

______________________________________________

ប្រវត្តិការងារ (រួមមានបទពិសោធន៍ទាក់ទងនឹងការងារស្ម័គ្រចិត្ត):

| ឈ្មោះក្រុមហ៊ុន | មុខតំណែង | រយៈពេលបំរើការងារ |
|---|---|---|
| (១) | | |
| (២) | | |
| (៣) | | |

មុខជំនាញ/ចំណុចខ្លាំង:______________________________________________

______________________________________________

មុខជំនាញដែលត្រូវការដើម្បីត្រឡប់ទៅកាន់ការងារវិញ: ______________________

______________________________________________

**ចំណុចខ្លាំងក្នុងការស្វែងរកការងារធ្វើ** • ប្រវត្តិរូបសង្ខេប • លិខិតអម • ជំនាញធ្វើបទសម្ភាសន៍ • អ៊ិនធើណិត • តាមបណ្ដាញក្នុងសង្គម • ទំនោរទីផ្សារការងារ • បញ្ហាផ្សេងៗ:

ជំនាញក្នុងការស្វែងរកការងារធ្វើ/តម្រូវការឧបករណ៍ ដើម្បីវិលត្រឡប់ទៅកាន់ការងារវិញ: ______________

______________________________________________

បញ្ហាក្នុងការថែរក្សាការងារឱ្យបានឋិតថេរ (ប្រសិនបើមាន): ______________________

______________________________________________

តម្រូវការ: ______________________________________________

# សេចក្ដីសង្ខេបនៃការវាយតម្លៃ

កំណត់សម្គាល់: ____________________

____________________

____________________

____________________

បញ្ហាដែលបានពិភាក្សា:

- បញ្ហាបុគ្គលផ្ទាល់ខ្លួន/បរិស្ថានជុំវិញខ្លួន
- ការសម្រេចចិត្តជ្រើសរើសអាជីព
- ការបង្កើនជំនាញ
- ជំនួយក្នុងការស្វែងរកការងារធ្វើ
- ការថែរក្សាការងារឱ្យបានឋិតថេរ

ការកត់ត្រាបញ្ហាដែលបានពិភាក្សា: ____________________

____________________

____________________

ជម្រើសដែលបានពិភាក្សា: ____________________

____________________

____________________

____________________

____________________

____________________

ជម្រើសដែលបានជ្រើសរើស/វាចារណកម្ម: ____________________

____________________

____________________

____________________

____________________

____________________

ការធ្វើបច្ចុប្បន្នកម្ម

| កាលបរិច្ឆេទ | បច្ចុប្បន្នកម្មនៃព័ត៌មាន |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

# ផែនការសកម្មភាពការងារ/កំណត់ហេតុតាមដាន

នាមត្រកូល: ____________________________ នាមខ្លួន: __________________________________ គោលដៅការងារ: _____________________________

| កាលបរិច្ឆេទ | ភ្នាក់ងារ | សកម្មភាព/សេវា | Appt. | ការចាប់ផ្តើម | លទ្ធផល | កាលបរិច្ឆេទ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

យើងឯកភាពថាព័ត៌មានខាងលើពិតជាត្រឹមត្រូវ និងគ្រប់គ្រាន់តាមកាលបរិច្ឆេទដែលបានចុះហត្ថលេខា និងដោយមានការចូលរួមរបស់ទីភ្នាក់ងារដែលមានឈ្មោះខាងលើ។

ហត្ថលេខាអតិថិជន: _________________________________ កាលបរិច្ឆេទ: ________________________ អ្នកផ្តល់ប្រឹក្សាយោបល់:______________________

# ឯកសារទី ៤.៥

## កម្រងរឿងរបស់អតិថិជន

**អ្នកផ្តល់ប្រឹក្សាយោបល់:** សួរស្តី! លោក វីរៈតារា សុខសប្បាយជាទេថ្ងៃនេះ?

**អតិថិជន:** មិនសូវជាសុខសប្បាយប៉ុន្មានទេ អ្នកស្រី អារូ៉ា

**អ្នកផ្តល់ប្រឹក្សាយោបល់:** ហេតុអ្វីបានជាលោកនិយាយយ៉ាងដូច្នេះ?

**អតិថិជន:** ខ្ញុំមិនបានបញ្ចប់វគ្គបណ្តុះបណ្តាលផ្នែកបើកបររថយន្តធំកាលពីខែមុនឡើយ

**អ្នកផ្តល់ប្រឹក្សាយោបល់:** តើលោកនឹងត្រូវបញ្ចប់នៅក្នុងខែនេះមែនដែរឬទេ?

**អតិថិជន:** មិនមែនទេ! ខ្ញុំយល់ថា រូបខ្ញុំមិនអាចធ្វើការជាអ្នកបើកបររថយន្តធំបានទេ ពីព្រោះខ្ញុំឈឺឆ្អឹងខ្នង

**អ្នកផ្តល់ប្រឹក្សាយោបល់:** តើលោកគិតថាជំហានបន្ទាប់របស់យើងគួរធ្វើអ្វីបន្តទៀត?

## ឯកសារទី ៤.៦

| ឈ្មោះអ្នកផ្តល់ការប្រឹក្សាយោបល់ |
|---|
| |

### ការតាមដាន ( Follow-up ) ទៅលើបទអន្តរាគមន៍

| លេខសម្គាល់ | ឈ្មោះអតិថិជន | លេខកូដតំបន់ | លេខទូរស័ព្ទ |
|---|---|---|---|

តើគាត់បានចូលរួមក្នុងបទអន្តរាគមន៍ដែរឬទេ? ☐ មាន ☐ មិនមាន

តើចាំបាច់ឱ្យធ្វើបទអន្តរាគមន៍បន្ថែមទៀតដែរឬទេ? ☐ មាន ☐ មិនមាន

ប្រសិនបើចម្លើយខាងលើគឺ **"មាន"** តើបទអន្តរាគមន៍មួយណា? (សូមសរសេរពីប្រភេទនៃបទអន្តរាគមន៍)

______________________________________________

ប្រសិនបើគាត់នឹងត្រូវចូលរួមនៅក្នុងបទអន្តរាគមន៍បន្ថែម តើពេលណាដែលលោកអ្នកនឹងតាមដានបន្តជាមួយអតិថិជនរូបនេះ?

______________________________________________

ប្រសិនបើពុំមានបទអន្តរាគមន៍បន្ថែម តើពីព្រោះតែនាពេលបច្ចុប្បន្ននេះគាត់មានការងារធ្វើឬ? ☐ មាន ☐ មិនមាន

ប្រសិននាពេលបច្ចុប្បន្ននេះគាត់មានការងារធ្វើ តើជាប្រភេទការងារអ្វី? ______________________

តើគាត់កំពុងធ្វើការនៅកន្លែងណា? តើក្រុមហ៊ុន ឬអង្គការឈ្មោះអ្វី?

______________________________________________

តើគាត់បានចាប់ផ្តើមការងារនេះនៅពេលណា? ______________________

តើអតិថិជនមានការបណ្តុះបណ្តាលទាក់ទងនឹងការងារដែលគាត់កំពុងធ្វើពេលនេះឬទេ? ☐ មាន ☐ មិនមាន

| ការអនុវត្ត | កាលបរិច្ឆេទនៃការតាមដាន | លទ្ធផលនៃការតាមដាន |
|---|---|---|
| ១ | | |
| ២ | | |
| ៣ | | |

កំណត់ត្រាផ្សេងៗ ______________________________________________

# ឯកសារទី ៤.៧

# តារាងសង្ខេបការទី ៣

<u>ពិនិត្យលើលទ្ធផលសម្រេចបាននៃគោលដៅប្រឹក្សាយោបល់</u>

តើអ្នកផ្តល់ប្រឹក្សាយោបល់:

- ☐ ការពិនិត្យទៅលើបទអន្តរាគមន៍ដែលនៅអាចអនុវត្តបាន
- ☐ ការពិនិត្យទៅលើការបញ្ចប់នៃបទអន្តរាគមន៍
- ☐ ការពិនិត្យទៅលើគោលដៅការងារដែលលទ្ធផលសម្រេចបាន
- ☐ ការលើកទឹកចិត្ត និងការគាំទ្រអតិថិជន
- ☐ ការបង្កើតនូវគោលដៅនៃការប្រឹក្សាយោបល់ថ្មី ព្រមជាមួយនឹងសកម្មភាព និងបទអន្តរាគមន៍ថ្មី (ផែនការសកម្មភាពថ្មី)
- ☐ ការកំណត់អំពីពេលវេលាសក្តិសមក្នុងការបិទសំណុំឯកសារ និងបញ្ចប់ការផ្តល់ប្រឹក្សាយោបល់

<u>ការកំណត់ពីសមត្ថភាពគ្រប់គ្រាន់របស់អតិថិជន</u>

អ្នកផ្តល់ប្រឹក្សាយោបល់ត្រូវធ្វើការពិនិត្យ ថាតើ:

- ☐ ការសម្រេចចិត្តចាប់យកអាជីពដទៃទៀតត្រូវបានធ្វើ
- ☐ អតិថិជនមានជំនាញ និងចំណេះដឹងដែលត្រូវការក្នុងការបំពេញការងារ
- ☐ អតិថិជនអាចចូលរួមនៅក្នុងការបង្កើតផែនការស្វែងរកការងារធ្វើ
- ☐ អតិថិជននៅតែទទួលបានការលើកទឹកចិត្តក្នុងការបន្តដំណើរការ

## ឯកសារទី ៤.៨
## ការបង្កើតភាពជាដៃគូរយុទ្ធសាស្ត្រជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល

**ឧទាហរណ៍ពីអង្គការមិនមែនរដ្ឋាភិបាល និងភ្នាក់ងារដទៃទៀតដែលអាចជួយដល់យុវជនដែលគ្មានការងារធ្វើ**

- **អង្គការមិត្តសំឡាញ់** (ធ្វើការជាមួយក្មេងដែលរស់នៅតាមចិញ្ចើមថ្នល់) ផ្តល់លទ្ធភាពក្នុងការចូលរួមក្នុងសង្គមឡើងវិញដោយធ្វើការជាមួយក្រុមគ្រួសាររបស់កុមារ ក្នុងគោលបំណងបង្កើនប្រាក់ចំណូលដើម្បីទប់ស្កាត់កុមារពីការធ្វើការតាមដងផ្លូវតទៅទៀត។ (ឧ: គម្រោងនៅក្នុងខេត្តកំពង់ចាម)

  គម្រោងរួមមាន:
  - ផ្តល់ផ្ទះស្នាក់នៅបណ្តោះអាសន្ន និងផ្ទះជួលដែលមានបន្ទប់ និងអាហារ
  - មជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាល
  - ការទៅដល់មូលដ្ឋាន
- **សហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា** Small and Medium Enterprise Cambodia (SMEC)

  គម្រោងរួមមាន:
  - បង្កើតសមាគមន៍ឧស្សាហកម្ម តាមរយៈវេទិកាដែលបានរៀបចំឡើង
  - បណ្តុះបណ្តាលសហគ្រាសខ្នាតតូច តាមរយៈកិច្ចប្រជុំក្រុមតូចៗ
- **បណ្តាញការងារយុវជន** (YEN) ជាដៃគូរជាមួយអង្គការសហប្រជាជាតិ (UN) អង្គការពលកម្មអន្តរជាតិ (ILO) និងធនាគារពិភពលោក(WB)
- **សហព័ន្ធនិយោជក និងសមគមពាណិជ្ជកម្មកម្ពុជា** (CAMFEBA) គម្រោងការងារយុវជន និងកិច្ចសន្ទនាសង្គម (YEP)

  គម្រោងរួមមាន:
  - សេវាជួយស្វែងរកការងារឱ្យធ្វើ
  - បណ្តុះបណ្តាលជំនាញទន់ដើម្បីពង្រឹងនូវលទ្ធភាពការងារ
  - អ៊ិនធើរណិតការហ្វេសម្រាប់ការស្វែងរកព័ត៌មានស្វែងរកការងារធ្វើ
  - តាមរយៈបណ្តាញយុវជនដែលមានការងារធ្វើ (វិជ្ជាជីវៈ)
  - ការប្រឹក្សាយោបល់ការងារ និងការជួយស្វែងរកការងារឱ្យធ្វើ
  - ការជួយបំពេញពាក្យសុំការងារធ្វើ
- សមាគមន៍យុវជនខ្មែរ
- CAMPRONET
- Kampuchean Action for Primary Education (KAPE)
- USAID and Youth Opportunity Networks (YOC’s)
- NZAID (New Zealand’International Aid & Development Agency) (2005-2010)

  គម្រោងរួមមាន: ការបង្កើតនូវកាលានុវត្តភាពការងារនៅក្នុងឧស្សាហកម្មទេសចរណ៍

# មេរៀនទី៥

## ការរៀបចំ និងការធ្វើផែនការចុះជួបនិយោជក



**គោលបំណងនៃមេរៀន:**

នៅពេលបញ្ចប់មេរៀនទី៥ នេះ សិក្ខាកាមទាំងអស់នឹងអាចៈ

- ពន្យល់ពីទស្សនទាននៃពាក្យ Marketing
- ពិនិត្យនូវរាល់សកម្មភាពរបស់មន្ត្រីមជ្ឈមណ្ឌលការងារនៅក្នុងមុខងារម៉ាឃីតទីង Marketing function
- កំណត់នូវនិយោជកសំខាន់ៗនៅក្នុងតំបន់
- យល់ដឹងអំពីដំណាក់កាលដែលទាក់ទងទៅនឹងការរៀបចំចុះជួបនិយោជក
- កាចុះជួបនិយោជក
- ប្រើប្រាស់នូវជំនាញក្នុងការធ្វើបទបង្ហាញប្រកបដោយប្រសិទ្ធភាពខ្ពស់នៅពេលចុះជួបនិយោជក
- ការអភិវឌ្ឍជំនាញឱ្យបានស្ទាត់ជំនាញ

**រយៈពេល:** ៦ ម៉ោង

**សេចក្តីសង្ខេប**

នៅក្នុងមេរៀននេះ

- បទបង្ហាញទី ៥.១ : និយមន័យ Marketing
- លំហាត់ទី ៥.១: លក្ខខណ្ឌនៃការជ្រើសរើសនិយោជកអាទិភាព
- បទបង្ហាញទី ៥.២ : ការរៀបចំទំនាក់ទំនងនិយោជក
- លំហាត់ទី ៥.២ : ការយល់ដឹងពីនិយោជកអាទិភាពនៅក្នុងតំបន់របស់លោកអ្នក
- បទបង្ហាញទី ៥.៣ : គំនិតផ្តួចផ្តើម Marketing
- លំហាត់ទី ៥.៣ : ការយល់ដឹងអំពីនិយោជក និងការបង្កើតនូវគោលដៅនៃការទំនាក់ទំនង
- បទបង្ហាញទី ៥.៤ : ការជ្រើសរើសមធ្យោបាយក្នុងការផ្សព្វផ្សាយ
- បទបង្ហាញទី៥.៥ : ការរៀបចំធ្វើបទបង្ហាញទៅកាន់និយោជក
- លំហាត់ទី ៥.៤ : ការធ្វើបទបង្ហាញទៅកាន់និយោជកតែម្នាក់
- លំហាត់ទី ៥.៥ : ការធ្វើបទបង្ហាញទៅកាន់ក្រុមនិយោជក
- បទបង្ហាញទី ៥.៦ : ការរំលឹកឡើងវិញនូវដំណាក់កាលទាំង ៩ នៅក្នុងការរៀបចំផែនការសកម្មភាពសម្រាប់ទំនាក់ទំនងនិយោជក
- ឧបសម្ព័ន្ធទី ៥.១ : តារាងផែនការ Marketing
- ឧបសម្ព័ន្ធទី ៥.២ : គុណសម្បត្តិ និងគុណវិបត្តិនៃការទំនាក់ទំនងនិយោជកតាមទូរស័ព្ទ និងការចុះជួបនិយោជក

# គំនិតជាមូលដ្ឋាន

Marketing គឺជាមធ្យោបាយដែលឆ្លើយតបទៅនឹងតម្រូវការរបស់និយោជក ឬអតិថិជន។ នោះមានន័យថាជាមធ្យោបាយក្នុងការខិតទៅជិតនិយោជកនៅក្នុងបែបផែនមួយ ដែលបង្ហាញឱ្យពួកគាត់ឃើញអំពីគុណតម្លៃ និងសារៈប្រយោជន៍ក្នុងការសហការជាមួយមជ្ឈមណ្ឌលការងារ។

គោលការណ៍គ្រឹះសំខាន់ៗចំនួន ៣ យ៉ាង ដែលធ្វើឱ្យវិធីសាស្ត្រ Marketing មានប្រសិទ្ធិភាពខ្ពស់ រួមមាន ៖

- ការផ្តោតជាចំបងទៅលើតម្រូវការរបស់និយោជក
- វិធីសាស្ត្របញ្ចូលគ្នាដែលរៀបចំឡើងដោយមជ្ឈមណ្ឌលការងារ
- គោលដៅចំបង គឺការពេញចិត្តរបស់អតិថិជន

## ការផ្តោតទៅលើតម្រូវការរបស់អតិថិជន

នៅក្នុងការខិតខំប្រឹងប្រែង Marketing ការផ្តោតទៅលើតម្រូវការរបស់អតិថិជនដែលមានការប្រែប្រួល គឺជាការណែនាំនូវសេវាក្នុងមធ្យោបាយធ្វើយ៉ាងណាឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន។

## វិធីសាស្ត្របញ្ចូលគ្នានៃការធ្វើ Marketing ( Integrate Marketing )

Marketing គឺសំដៅទៅលើសកម្មភាពនៅក្នុងក្រុមដែលតម្រូវឱ្យមានការខិតខំប្រឹងប្រែង និងការចូលរួមពីសមាជិកទាំងអស់ដែលយល់ដឹងតួនាទីរៀងៗខ្លួន នៅក្នុងការបង្កើតផែនការ Marketing។ Marketing ដែលទទួលបានជោគជ័យ ត្រូវបានវាស់វែងដោយអាស្រ័យទៅលើកម្រិតនៃការពេញចិត្តរបស់អតិថិជន។ Marketing មិនគ្រាន់តែសំដៅទៅលើសកម្មភាពផ្សព្វផ្សាយ និងការចុះជួបនិយោជកប៉ុណ្ណោះទេ ក៏ប៉ុន្តែរួមបញ្ចូលនូវសកម្មភាពផ្សេងៗព្រមជាមួយនឹងនីតិវិធីផ្តល់សេវាដែលត្រូវបានបញ្ចូលនៅក្នុងផែនការសកម្មភាពបានយ៉ាងល្អប្រសើរ ។

## ការពេញចិត្តរបស់អតិថិជន

ការពេញចិត្តរបស់អតិថិជនបានស្តែងឡើងតាមរយៈ ចំណុច ២ សំខាន់ៗ រួមមានៈ

- ការជួយដោះស្រាយបញ្ហារបស់និយោជក ដែលទាក់ទងទៅនឹងការងាររបស់អ្នកទាំងនោះ
- ផ្តល់សេវាប្រកបដោយគុណភាព ដែលបង្កើតជាសញ្ញាខ័ណ្ឌវិជ្ជមានសម្រាប់មជ្ឈមណ្ឌលការងារ

## ការរៀបចំផែនការ Marketing

ការរៀបចំផែនការ Marketing មិនគ្រាន់តែជាកិច្ចការសាមញ្ញក្នុងការប្រមូល និងធ្វើចំណាត់ថ្នាក់ទិន្នន័យប៉ុណ្ណោះទេ។ ទោះបីជាស្ថិតក្នុងគុណតម្លៃបែបណាក៏ដោយ មន្ត្រីមជ្ឈមណ្ឌលការងារទាំងអស់ត្រូវមានឆន្ទៈ និង

ការពេញចិត្តក្នុងការអនុវត្តឱ្យបានល្អប្រពៃ។ សូមធ្វើការចាប់អារម្មណ៍ទៅនឹងចំណុចដែលបានគូសបញ្ជាក់ខាងក្រោម ដើម្បីធានាថាផែនការត្រូវបានរៀបចំឡើងដោយៈ

- មានលក្ខណៈសាមញ្ញ ច្បាស់លាស់ និងសង្កត់ធ្ងន់ទៅលើចំណុចសំខាន់ៗ តាមរយៈការសរសេរពីរ ឬបីបន្ទាត់ប៉ុណ្ណោះ
- ធ្វើការកំណត់ឱ្យបានច្បាស់លាស់អំពីកិច្ចការដែលនឹងត្រូវប្រតិបត្តិ

### ការផ្តោតទៅលើនិយោជក

ជំហានដំបូងនៅក្នុងផែនការ គឺត្រូវធ្វើការបែងចែកនិយោជកជាផ្នែកៗ។ ចំណុចខាងក្រោមនេះ គឺជាលក្ខណៈវិនិច្ឆ័យ ដែលអាចប្រើប្រាស់សម្រាប់ជាជំនួយដល់មជ្ឈមណ្ឌលការងារក្នុងការកំណត់និយោជកគោលដៅក្នុងអំឡុងពេលរៀបចំផែនការ Marketing។

១. វិស័យដែលកំពុងរីកចម្រើន
២. វិស័យកំពុងធ្លាក់ចុះ
៣. តម្រូវការមុខរបរ
៤. និយោជកថ្មីៗ
៥. សហគ្រាសថ្មីៗ
៦. និយោជកដែលកំពុងរកបុគ្គលិកមកជំនួសកន្លែងបុគ្គលិកដែលបានចាកចេញ (Turnover)
៧. និយោជកដែលមានអត្រាបញ្ឈប់ ១៥% ឬច្រើនជាង
៨. អាទិភាពដទៃទៀត

### តារាងផែនការ Marketing

បន្ទាប់ពីបានកំណត់និយោជកគោលដៅដោយមជ្ឈមណ្ឌលការងាររួចមក មន្ត្រីមជ្ឈមណ្ឌលការងារត្រូវប្រើប្រាស់នូវតារាងផែនការ Marketing ដើម្បីរៀបចំនូវផែនការ Marketing របស់ខ្លួន (ឧបសម្ព័ន្ធទី ៥.១)។

### គំនិតផ្តួចផ្តើម Marketing

ចំណុចសំខាន់នៅក្នុងដំណើរការរៀបចំផែនការ គឺការកំណត់នូវកិច្ចការដែលត្រូវធ្វើសម្រាប់និយោជកគោលដៅ។ ការបង្ហាញជូនខាងក្រោមនេះ គឺជាចំណុចប្រសិទ្ធភាពដែលបានឆ្លើយតបទៅនឹងតម្រូវការរបស់និយោជកគោលដៅ រួមមានៈ

១. ការប្រមូលព័ត៌មានជ្រើសរើសបុគ្គលិកថ្មីៗ
២. ការកំណត់ពីតម្រូវការ
៣. អ្នកស្វែងរកការងារធ្វើដែលត្រៀមខ្លួនជាស្រេចសម្រាប់ចូលទៅក្នុងទីផ្សារការងារ
៤. ដោះស្រាយបញ្ហាសេវាតាមលំដាប់ការងារ
៥. ទំនាក់ទំនងនិយោជកថ្មី
៦. បញ្ហាផ្សេងៗ

### ផែនការ Marketing សម្រាប់និយោជកដែលបានជ្រើសរើស

ដំណាក់កាលទី១ បន្ទាប់ពីបានកំណត់និយោជកគោលដៅដោយប្រើប្រាស់នូវតារាងផែនការ Marketing មន្រ្តីមជ្ឈមណ្ឌលការងារធ្វើការជ្រើសរើសនិយោជកក្នុងចំនួនជាក់ស្តែងសម្រាប់ចុះជួបក្នុងរយៈពេល១ឆ្នាំ។ ដំណាក់កាលទី២ មន្រ្តីមជ្ឈមណ្ឌលការងារធ្វើបញ្ជីនិយោជកដែលបានជ្រើសរើសដាក់ក្នុងតារាងផែនការ Marketing និងចាប់ផ្តើមចុះជួបនិយោជកម្តងម្នាក់ៗ។

### អត្ថប្រយោជន៍នៃ Marketing

គោលគំនិតនៃការអនុវត្ត Marketing ជាប្រយោជន៍ជួយកាត់បន្ថយបញ្ហា ហើយឆ្លើយតបទៅនឹងគោលបំណងរបស់មជ្ឈមណ្ឌលការងារ និងការបង្ហាញនូវកាលានុវត្តភាពនៅក្នុងទីផ្សារការងារ។ ការផ្តោតជាចំបងទៅលើសេវារបស់មជ្ឈមណ្ឌលការងារ គឺ Marketing បានផ្តល់ជាប្រយោជន៍ដល់និយោជក និងកម្មករ ការលើកកម្ពស់កិត្តិស័ព្ទមជ្ឈមណ្ឌលការងារ ការឈានទៅសម្រេចបាននូវគោលដៅរបស់អង្គភាព និងជាពិសេសការនាំមកឱ្យមន្រ្តីបម្រើការងារមានភាពសប្បាយរីករាយ។

### ដំណាក់កាលទាំង ៩ នៅក្នុងការរៀបចំផែនការសកម្មភាពសម្រាប់ទំនាក់ទំនងនិយោជក រួមមានៈ

១. ការយល់ដឹងពីអាទិភាពនៅក្នុងតំបន់របស់លោកអ្នក
២. ការយល់ដឹងអំពីសេវារបស់មជ្ឈមណ្ឌលការងារ
៣. ការបង្កើតនូវគោលដៅសម្រាប់ការចុះជួប (ទំនាក់ទំនង)
៤. ការពិនិត្យទិន្នន័យដែលមានស្រាប់ឡើងវិញ
៥. ការស្វែងយល់ពីសំណួរដើម្បីកំណត់ពីតម្រូវការរបស់និយោជក
៦. ការជ្រើសរើសមធ្យោបាយក្នុងការផ្សព្វផ្សាយ
៧. រៀបចំកម្មវិធី (ពេលវេលា) ក្នុងការទំនាក់ទំនង
៨. កត់ត្រាព័ត៌មានទំនាក់ទំនង
៩. ការរៀបចំធ្វើបទបង្ហាញ

### ដំណាក់កាលទី១: ការយល់ដឹងពីអាទិភាពនៅក្នុងតំបន់របស់លោកអ្នក

នៅពេលរៀបចំពីចំណុចអាទិភាពសម្រាប់ទំនាក់ទំនងជាមួយនិយោជក មន្រ្តីមជ្ឈមណ្ឌលការងារត្រូវធ្វើការពិចារណាទៅលើកត្តាខាងក្រៅ ដូចជាៈ

១. តើអាទិភាពដែលពាក់ព័ន្ធទៅនឹងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានអ្វីខ្លះ?
២. តើអាទិភាពរបស់មជ្ឈមណ្ឌលការងារមានអ្វីខ្លះ?
៣. តើមានកត្តាសំខាន់អ្វីខ្លះដែលគួរធ្វើការពិចារណា?
៤. តើយើងគួរបញ្ចុះបញ្ចូលនិយោជកបែបណាដើម្បីធ្វើការផ្លាស់ប្តូរវិធីសាស្រ្តជ្រើសរើស ឬជ្រើសរើសសម្រិតសម្រាំងបុគ្គលិក?

## ដំណាក់កាលទី២: ការយល់ដឹងអំពីសេវារបស់មជ្ឈមណ្ឌលការងារ

សេវាសម្រាប់និយោជកដែលផ្តល់ដោយមជ្ឈមណ្ឌលការងារ អាចផ្តល់ជាដំណោះស្រាយមួយចំនួនដល់និយោជកដែលបានជួបប្រទះ ពាក់ព័ន្ធទៅនឹងបញ្ហាការងារ។ នេះជាតួនាទីរបស់មន្ត្រីមជ្ឈមណ្ឌលការងារ ដែលដើរតួជាអ្នក Marketing ដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ ដូចជាការរាយការណ៍ទៅកាន់ថ្នាក់ដឹកនាំអំពីតម្រូវការនាពេលបច្ចុប្បន្ន ដែលមជ្ឈមណ្ឌលការងារមិនទាន់សម្រេចបាន ដូច្នេះតម្រូវឱ្យធ្វើការកែសម្រួល ដើម្បីអាចអនុវត្តទៅបាន។

## ដំណាក់កាលទី៣: ការបង្កើតនូវគោលដៅសម្រាប់ការចុះជួប (ទំនាក់ទំនង)

តើលោកអ្នកកំណត់គោលដៅក្នុងការទំនាក់ទំនងនិយោជកយ៉ាងដូចម្តេច ?

លោកអ្នកត្រូវចាប់ផ្តើមពីការពិនិត្យឡើងវិញនូវហេតុផលក្នុងការកំណត់និយោជកគោលដៅ និងការសម្រេចចិត្តចំពោះគំនិតផ្តួចផ្តើមដែលនឹងត្រូវអនុវត្ត។ ប្រសិនបើលោកអ្នកធ្លាប់ស្គាល់និយោជកពីមុន លោកអ្នកអាចបង្កើតផែនការ និងគោលដៅផ្ទាល់ខ្លួនបាន ហើយរាល់ការចុះជួបនិយោជកដោយធ្វើការដំណោះស្រាយបញ្ហារបស់និយោជកបន្ទាប់ពីបានកំណត់អំពីតម្រូវការរបស់អ្នកទាំងនោះឱ្យទៅជាគោលដៅរបស់លោកអ្នក។ វិធីសាស្ត្រនេះសក្តិសមទៅនឹងការកំណត់គោលដៅ ដែលអាចគ្របដណ្តប់នៅក្នុងវិស័យឧស្សាហកម្ម ឬមុខរបរជាក់លាក់ក៏ដូចជាការលើកកម្ពស់សមភាពយេនឌ័រ។ តាមរយៈការចងក្រងនូវតម្រូវការរបស់និយោជក លោកអ្នកអាចកំណត់នូវគោលដៅរបស់ខ្លួន និងអនុវត្តតាមលំដាប់លំដោយ។

## ដំណាក់កាលទី៤: ការពិនិត្យទិន្នន័យដែលមានស្រាប់ឡើងវិញ

គោលការណ៍សំខាន់បំផុតក្នុងការទំនាក់ទំនងនិយោជកនោះ គឺភាពខុសប្លែកគ្នារវាងការព្រួយបារម្ភ និងភាពជឿជាក់ដែលត្រូវបានរៀបចំ។

មន្ត្រីមជ្ឈមណ្ឌលការងារ មិនត្រូវប្រឌិតនូវព័ត៌មានទំនាក់ទំនងនិយោជកទេ ក៏ប៉ុន្តែត្រូវរៀបចំផែនការដោយផ្ចិតផ្ចង់ និងត្រួតពិនិត្យឡើងវិញចំពោះព័ត៌មានដែលអាចរកបាន ធ្វើការស្រាវជ្រាវអំពីស្ថានភាពដែលកំណត់ថាមានសារៈសំខាន់ និងធ្វើការពិភាក្សានូវស្ថានភាពទាំងនេះជាមួយសហការី ឬអ្នកទំនាក់ទំនងដទៃទៀត។

## ដំណាក់កាលទី៥: ការស្វែងយល់ពីសំណួរដើម្បីកំណត់ពីតម្រូវការរបស់និយោជក

វិធីសាស្ត្រមួយក្នុងការកំណត់អំពីតម្រូវការរបស់និយោជក គឺការសួរសំណួរដោយបើកចំហរ (Open-ended questions) ដែលនឹងប្រមូលព័ត៌មានបានច្រើន។ ធ្វើការត្រៀមនូវបញ្ជីសំណួរដោយផ្តោតជាចំបងទៅលើការចុះជួបរបស់លោកអ្នក ដែលក្នុងនោះក៏ជាការបង្ហាញអំពីសេវារបស់មជ្ឈមណ្ឌលការងារក្នុងការផ្តល់ជូន និងដោយស្របទៅនឹងតម្រូវការរបស់និយោជក ក៏ដូចជាអត្ថប្រយោជន៍ដែលនិយោជកមិនបានគិតទុកជាមុន។

**ដំណាក់កាលទី៦: ការជ្រើសរើសមធ្យោបាយក្នុងការផ្សព្វផ្សាយ**

វិធីសាស្ត្រ Marketing ដែលជួយបង្កើនទំនាក់ទំនងក្នុងការងារមាន២ ចំណុចសំខាន់ៗរួមមានៈ ការទំនាក់ទំនងតាមទូរស័ព្ទ និងការចុះជួបដោយផ្ទាល់។

លោកអ្នកត្រូវស្នើសុំពេលវេលានៃការណាត់ជួបនិយោជកទុកជាមុន ដោយត្រូវរៀបរាប់ពីគោលបំណងឱ្យបានច្បាស់លាស់ ក្នុងករណីជ្រើសរើសការចុះជួបដោយផ្ទាល់ លោកអ្នកត្រូវធ្វើបទបង្ហាញអំពីសេវាដែលផ្តល់ជូនដោយមជ្ឈមណ្ឌលការងារ។ លោកអ្នកត្រូវកំណត់ថា តើគួរធ្វើបទបង្ហាញបែបផ្លូវការ ឬក្រៅផ្លូវការ។ លោកអ្នកអាចលើកទឹកចិត្តនិយោជកឱ្យធ្វើការកោះហៅនិយោជិតដែលដែលបានពាក់ព័ន្ធនឹងការងារឱ្យចូលរួម។

វិធីសាស្ត្រក្នុងការទូរស័ព្ទដែលមានប្រសិទ្ធភាពខ្ពស់ រួមមានៈ

- ការរៀបចំបរិស្ថានឱ្យបានសមស្រប ( ទីតាំង/ ការរំខាន/ ផាសុខភាព )
- ការរៀបចំសម្ភារជំនួយសម្រាប់ទូរស័ព្ទទំនាក់ទំនង (សៀវភៅកំណត់ត្រាផ្ទាល់ខ្លួន/ សំណុំឯកសារអតិថិជន/ ពេលវេលាទំនេរ/ ក្រដាស/ ប៊ិច )
- ការសរសេរអំពីគោលដៅនៃការទូរស័ព្ទ (ជួយឱ្យលោកអ្នកផ្តោតអារម្មណ៍ទៅលើគោលដៅជាចំបង )
- ការរៀបចំ និងការប្រើប្រាស់នូវប្រយោគចាប់ផ្តើមសន្ទនាឱ្យបានសមរម្យ (ដើម្បីទាញនូវចំណាប់អារម្មណ៍ទៅលើចំណុចរំពឹងទុករបស់លោកអ្នក )
- ការត្រៀមសំណួរទុកជាមុន
- សរសេរជាលាយលក្ខអក្សរនូវមូលហេតុនៃការជំទាស់ដោយប្រើពាក្យសមរម្យ និងចម្លើយដែលមានលក្ខណៈអូសទាញ ឬបញ្ចុះបញ្ចូល
- ហាត់សមឱ្យបានច្រើនដង មុននឹងធ្វើការទូរស័ព្ទទៅកាន់និយោជក (ជួយបង្កើនការនិយាយឱ្យបានល្អប្រសើរ ស្វែងយល់ពីកង្វះខាត និងបង្កើតនូវភាពជឿជាក់ )
- រក្សានូវឥរិយាបថវិជ្ជមាន
- ការកត់ត្រា (ការផ្តោតទៅលើគោលដៅជាចំបង ជួយបង្កើនការគិតពិចារណា និងការឆ្លើយតប/បង្កើនកម្លាំងចិត្ត/ផ្តល់ការកត់ត្រានូវការទូរស័ព្ទទំនាក់ទំនង )
- ប្រមូលផ្តុំនិយោជកជាក្រុម រួចធ្វើការទំនាក់ទំនងក្នុងពេលតែមួយ (សន្សំពេលវេលា និងរក្សានូវការបញ្ជូនព័ត៌មានឱ្យជាប់លាប់ )
- ប្រើប្រាស់ជម្រើសពេលវេលាក្នុងការណាត់ជួប
- ធ្វើការសង្ខេបនូវចំណុចគន្លឹះរាល់ពេលបញ្ចប់នៃការទូរស័ព្ទ

**ដំណាក់កាលទី៧: រៀបចំកម្មវិធី (ពេលវេលា) ក្នុងការទំនាក់ទំនង**

មន្ត្រីមជ្ឈមណ្ឌលការងារត្រូវរៀបចំកម្មវិធីប្រចាំខែ បន្ទាប់ពីបានធ្វើការពិភាក្សាជាមួយប្រធានមជ្ឈមណ្ឌលការងារ កម្មវិធីនេះរួមមានបញ្ជីឈ្មោះនិយោជកគោលដៅដែលមាននៅក្នុងផែនការ Marketing ដំណាក់កាលទី២ ។ កម្មវិធី Marketing ត្រូវបញ្ចូលនូវៈ

- ចំនួននិយោជកដែលត្រូវទំនាក់ទំនង
- ចំនួនពេលវេលាដែលនឹងត្រូវចំណាយទៅលើនិយោជកក្នុងសប្តាហ៍នីមួយៗ
- ឈ្មោះនិយោជកដែលនឹងត្រូវទំនាក់ទំនង

កម្មវិធីនេះ ត្រូវធ្វើការពិនិត្យឡើងវិញជារៀងរាល់ខែ ដើម្បីធានាបាននូវគោលដៅដែលបានកំណត់ ត្រូវសម្រេចបាន។

**ដំណាក់កាលទី៨: កត់ត្រាពីព័ត៌មានទំនាក់ទំនង**

កំណត់ត្រាព័ត៌មាននិយោជក មានសារៈប្រយោជន៍ដល់លោកអ្នកក្នុងការអនុវត្តក្នុងផែនការ Marketing ។ ព័ត៌មានទាំងនោះត្រូវកត់ត្រានៅក្នុងសំណុំឯកសាររបស់និយោជក។ ការប្រមូលឯកសារនៃការចុះជួបនិយោជក គឺជាដំណាក់កាលដ៏សំខាន់ ពីព្រោះព័ត៌មានដែលបានចុះនឹងត្រូវប្រើប្រាស់ក្នុងការរក្សាទំនាក់ទំនងការងារជាមួយនិយោជក និងការធានានូវគុណភាពនៃសេវា។



## បទបង្ហាញទី ៥.១:
## និយមន័យ Marketing



ទំព័របង្ហាញទី ៥.១

និយមន័យ Marketing

- ការវិភាគ ការរៀបចំផែនការ ការអនុវត្ត និងការត្រួតពិនិត្យ
- កម្មវិធី ឬសេវា
- ការផ្លាស់ប្តូរដោយស្ម័គ្រចិត្ត
- គោលដៅនៅក្នុងទីផ្សារការងារ
- គោលបំណងរបស់អង្គភាព
- ការផ្តោតទៅលើតម្រូវការនៅក្នុងទីផ្សារការងារ និងចំណង់ចំណូលចិត្ត
- ការកំណត់តម្លៃ
- ការទំនាក់ទំនង និងការចែកផ្សាយ
- ការជូនដំណឹង ការលើកទឹកចិត្ត និងសេវា

ទំព័របង្ហាញទី ៥.២

នៅក្នុងវិធីសាស្ត្រ Marketing មានគោលការណ៍សំខាន់ៗចំនួន ៣ រួមមាន:

- ការផ្តោតទៅលើតម្រូវការរបស់អតិថិជនជាចំបង
- វិធីសាស្ត្របញ្ចូលគ្នាធ្វើ Marketing ( Integrate Marketing )
- ការពេញចិត្តរបស់អតិថិជន



# លំហាត់ទី ៥.១:
# លក្ខខណ្ឌនៃការជ្រើសរើសនិយោជកអាទិភាព



រយៈពេល: ៣៥នាទី

គោលបំណង

- ផ្តល់ឱកាសដល់សិក្ខាកាមក្នុងការចែករំលែកនូវការយល់ឃើញរបស់ខ្លួនអំពីលក្ខខណ្ឌនៃការជ្រើសរើសនិយោជកអាទិភាព។

## សេចក្តីណែនាំ:

- បែងចែកជាក្រុមពិភាក្សាដែលមានសមាជិកចំនួន ០៥ នាក់
- ធ្វើការពិភាក្សាអំពីលក្ខខណ្ឌដែលអាចធ្វើទៅបានសម្រាប់កំណត់និយោជកគោលដៅដែលមាននៅក្នុងផែនការ Marketing និងកត់ត្រានូវចំលើយរបស់លោកអ្នកនៅលើក្រដាសដែលបានចែកជូន (រយៈពេល ១៥ នាទី)
- ធ្វើការសម្រេចទៅលើលក្ខខណ្ឌដែលលោកអ្នកបានផ្តោតជាចំបង (រយៈពេល ០៥ នាទី)
- ជ្រើសរើសអ្នកតំណាង និងធ្វើបទបង្ហាញអំពីមូលហេតុនៃលក្ខខណ្ឌទាំងនេះនៅក្នុងក្រុមពិភាក្សាធំ (រយៈពេល ១៥ នាទី)

កំណត់ចំណាំ:



## បទបង្ហាញទី ៥.២:
## ការរៀបចំទំនាក់ទំនងនិយោជក



**ទំព័របង្ហាញទី ៥.៣**

**ដំណាក់កាលនៅក្នុងការរៀបចំទំនាក់ទំនងនិយោជក**

១. ការយល់ដឹងពីអាទិភាពនៅក្នុងតំបន់របស់លោកអ្នក
២. ការយល់ដឹងអំពីសេវារបស់មជ្ឈមណ្ឌលការងារ
៣. ការបង្កើតនូវគោលដៅសម្រាប់ការចុះជួប (ទំនាក់ទំនង)
៤. ការពិនិត្យទិន្នន័យដែលមានស្រាប់ឡើងវិញ
៥. ការស្វែងយល់ពីសំណួរដើម្បីកំណត់ពីតម្រូវការរបស់និយោជក
៦. ការជ្រើសរើសមធ្យោបាយផ្សព្វផ្សាយ
៧. រៀបចំកម្មវិធី (ពេលវេលា) ក្នុងការទំនាក់ទំនង
៨. កត់ត្រាព័ត៌មានទំនាក់ទំនង
៩. ការរៀបចំធ្វើបទបង្ហាញ

**ទំព័របង្ហាញទី៥.៤**

**លក្ខខណ្ឌក្នុងការជ្រើសរើសនិយោជក**

១. វិស័យដែលកំពុងរីកចម្រើន
២. វិស័យដែលកំពុងធ្លាក់ចុះ
៣. តម្រូវការមុខរបរ
៤. និយោជកថ្មីៗ
៥. សហគ្រាសថ្មីៗ
៦. និយោជកដែលកំពុងរកបុគ្គលិកមកជំនួសកន្លែងបុគ្គលិកដែលបានចាកចេញ (Turnover)
៧. អាទិភាពដទៃទៀត

# លំហាត់ទី ៥.២ : ការយល់ដឹងពីនិយោជកអាទិភាពនៅក្នុងតំបន់របស់លោកអ្នក

រយៈពេល: ៤០នាទី

គោលបំណង:

- សិក្ខាកាមធ្វើការលើកឡើងពីអាទិភាពមួយចំនួននៅក្នុងតំបន់

សេចក្តីណែនាំ:

- ធ្វើការបែងចែកជាក្រុមពិភាក្សាដែលមានសមាជិក ០៣ នាក់
- ការលើកឡើងអំពីនិយោជកអាទិភាពនៅក្នុងតំបន់ដែលមជ្ឈមណ្ឌលការងារស្ថិតនៅ និងសរសេរនៅលើក្រដាសដែលបានចែកជូន (រយៈពេល ២០ នាទី)
- ជ្រើសរើសអ្នកតំណាង និងធ្វើបទបង្ហាញនៅក្នុងក្រុមពិភាក្សាធំ (រយៈពេល ២០ នាទី)

កំណត់ចំណាំ:



## បទបង្ហាញទី ៥.៣:
## គំនិតផ្តួចផ្តើម Marketing



ទំព័របង្ហាញទី៥.៤

**គំនិតផ្តួចផ្តើម Marketing**

- ការប្រមូលព័ត៌មានជ្រើសរើសបុគ្គលិកថ្មីៗ
- ការកំណត់ពីតម្រូវការ
- អ្នកស្វែងរកការងារធ្វើដែលត្រៀមខ្លួនជាស្រេច សម្រាប់ចូលទៅក្នុងទីផ្សារការងារ
- ដោះស្រាយបញ្ហាសេវាតាមលំដាប់ការងារ
- ទំនាក់ទំនងនិយោជកថ្មី
- បញ្ហាផ្សេងៗ



# លំហាត់ទី ៥.៣:
# ការយល់ដឹងពីនិយោជក និងការបង្កើត នូវគោលដៅនៃការទំនាក់ទំនង



រយៈពេល: ៤០នាទី

គោលបំណង:

- ផ្តល់ជូនដល់សិក្ខាកាម (ភាពសុាំ) មានការយល់ដឹងទៅនឹងការរំពឹងទុករបស់និយោជក ដើម្បីមានភាពងាយស្រួលក្នុងការបង្កើតគោលដៅក្នុងការចុះជួបនិយោជក

សេចក្តីណែនាំ:

- ធ្វើការបែងចែកជាក្រុមពិភាក្សាដែលមានសមាជិកចំនួន ០៥ នាក់ និងធ្វើការពិភាក្សាទៅលើ:
    - ការរំពឹងទុករបស់និយោជកពាក់ព័ន្ធទៅនឹងមជ្ឈមណ្ឌលការងារ
    - ប្រតិកម្មរបស់និយោជកចំពោះការចុះជួបរបស់មន្ត្រីមជ្ឈមណ្ឌលការងារ រួមមានប្រតិកម្មដែលមានលក្ខណៈវិជ្ជមាន និងអវិជ្ជមាន
- សរសេរចម្លើយរបស់លោកអ្នកនៅលើក្រដាសដែលបានចែកជូន (រយៈពេល ២០ នាទី)
- ជ្រើសរើសអ្នកតំណាង និងធ្វើការរាយការណ៍នៅក្នុងក្រុមពិភាក្សាធំ (រយៈពេល ២០ នាទី)

កំណត់ចំណាំ:



# បទបង្ហាញទី ៥.៤
# ការជ្រើសរើសមធ្យោបាយក្នុងការផ្សព្វផ្សាយ



**ទំព័របង្ហាញទី ៥.៦**

ការជ្រើសរើសមធ្យោបាយក្នុងការផ្សព្វផ្សាយ

មាន ២ ចំណុចសំខាន់ៗ រួមមាន:

- ការចុះជួបដោយផ្ទាល់
- តាមរយៈទូរស័ព្ទ

**ទំព័របង្ហាញទី ៥.៧**

គុណសម្បត្តិ និងគុណវិបត្តិនៃការចុះជួបនិយោជកដោយផ្ទាល់

**គុណសម្បត្តិ**

- អាចឃើញទីតាំងរបស់និយោជក សម្ភារ និង បុគ្គលិក
- អាចលើកឡើងអំពីបញ្ហា ឬតម្រូវការដាក់លាក់របស់និយោជក
- បានស្គាល់មុខ និងឈ្មោះរបស់និយោជក
- និយោជកបានស្គាល់មុខ និងឈ្មោះមន្ត្រីមជ្ឈមណ្ឌលការងារ
- អាចប្រើប្រាស់នូវវិធីសាស្ត្រក្នុងការលក់ដូរទំនិញ

**គុណវិបត្តិ**

- ចំណាយពេលវេលា
- ចំណាយថវិកាក្នុងការធ្វើដំណើរ
- មិនបានជួបបុគ្គលដែលបានទំនាក់ទំនង
- ការពិភាក្សានឹងចំណាយពេលយូរ ប្រសិនបើនិយោជកមិនបានកំណត់បញ្ហា/តម្រូវការបានទុកជាមុន

**ទំព័របង្ហាញទី ៥.៧**

### គុណសម្បត្តិ និងគុណវិបត្តិនៃការចុះជួបនិយោជកដោយផ្ទាល់ (ត)

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • និយោជកមិនសូវធ្វើការរិះគន់ក្នុងការចុះជួបដោយផ្ទាល់ ជាជាងការមិនស្គាល់មុខ និងឈ្មោះ<br>• អាចធ្វើការផ្ទៀងផ្ទាត់ព័ត៌មានឱ្យបានច្បាស់លាស់ និងកែសម្រួលនូវចំណុចកាន់ប្រឡំ<br>• ប្រសិនបើរក្សាបាននូវការចុះជួបនិយោជកឱ្យបានជាប់លាប់ លក្ខខណ្ឌអវិជ្ជមានជាច្រើននឹងត្រូវបានកាត់បន្ថយ | • និយោជកអាចត្រូវរំខានដោយសម្ពាធការងារផ្សេងទៀត<br>• មិនទាន់បានរៀបចំឯកសារទុកជាមុន<br>• អាចត្រូវរង់ចាំយូរដើម្បីបានជួបនិយោជក |

**ទំព័របង្ហាញទី ៥.៨**

### គុណសម្បត្តិ និងគុណវិបត្តិនៃការទំនាក់ទំនងតាមទូរស័ព្ទ

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • គ្របដណ្តប់បានទូលំទូលាយ<br>• អាចគ្រប់គ្រងពេលវេលា<br>• អាចប្រើប្រាស់មន្ត្រីបានច្រើន<br>• ចំពោះមន្ត្រីដែលរងសម្ពាធក្នុងការណាត់ជួប១ ទល់នឹង១ ការទូរស័ព្ទគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាព<br>• មានភាពងាយស្រួលក្នុងការប្រើប្រាស់ឯកសារយោងនានា<br>• អាចជួយដោះស្រាយបញ្ហាបុគ្គល ១ ទល់នឹង ១<br>• អាចធ្វើការផ្ទៀងផ្ទាត់ព័ត៌មានឱ្យបានច្បាស់លាស់ និងកែសម្រួលនូវចំណុចកាន់ប្រឡំ<br>• អាចធ្វើការទំនាក់ទំនងនិយោជកទោះបីជានៅឆ្ងាយពីគ្នា<br>• កាត់បន្ថយនូវការចំណាយពេលវេលារបស់និយោជក | • មិនបានឃើញទីតាំងរបស់និយោជក សម្ភារ និងបុគ្គលិក នាគ្រាដំបូង<br>• និយោជកអាចបដិសេធក្នុងការសន្ទនាជាមួយមន្ត្រីមជ្ឈមណ្ឌលការងារ ឬបិទទូរស័ព្ទ<br>• មិនបានជួបបុគ្គលដែលបានទំនាក់ទំនង |

**ទំព័របង្ហាញទី ៥.៨**

**វិធីសាស្ត្រក្នុងការទូរស័ព្ទដែលមានប្រសិទ្ធភាពខ្ពស់រួមមានៈ**

- ការរៀបចំបរិស្ថានឱ្យបានសមស្រប (ទីតាំង/ ការរំខាន/ ផាសុខភាព)
- ការរៀបចំសម្ភារជំនួយសម្រាប់ទូរស័ព្ទទំនាក់ទំនង (សៀវភៅកំណត់ត្រាផ្ទាល់ខ្លួន/សំណុំឯកសារអតិថិជន/ពេលវេលាទំនេរ/ក្រដាស/ប៊ិច)
- ការសរសេរអំពីគោលដៅនៃការទូរស័ព្ទ (ជួយឱ្យលោកអ្នកផ្តោតអារម្មណ៍ទៅលើគោលដៅជាចំបង)

**ទំព័របង្ហាញទី ៥.៩**

**វិធីសាស្ត្រក្នុងការទូរស័ព្ទដែលមានប្រសិទ្ធភាពខ្ពស់ (ត)**

- ការរៀបចំ និងការប្រើប្រាស់នូវប្រយោគចាប់ផ្តើមសន្ទនាឱ្យបានសមរម្យ (ដើម្បីទាញនូវចំណាប់អារម្មណ៍ទៅលើចំណុចរំពឹងទុករបស់លោកអ្នក)
- ការត្រៀមសំណួរទុកជាមុន
- សរសេរជាលាយលក្ខអក្សរនូវមូលហេតុនៃការជំទាស់ដោយប្រើប្រាស់នូវប្រយោគសមរម្យ និងចម្លើយដែលមានលក្ខណៈអូសទាញឬបញ្ចុះបញ្ចូល

**ទំព័របង្ហាញទី ៥.១០**

**វិធីសាស្ត្រក្នុងការទូរស័ព្ទដែលមានប្រសិទ្ធភាពខ្ពស់ (ត)**

- ហាត់សមឱ្យបានច្រើនដងមុននឹងធ្វើការទូរស័ព្ទទៅកាន់និយោជក (ជួយបង្កើនការនិយាយឱ្យបានល្អប្រសើរ ស្វែងយល់ពីកង្វះខាត និងបង្កើតនូវភាពជឿជាក់)
- រក្សានូវឥរិយាបថវិជ្ជមាន

**ទំព័របង្ហាញទី ៥.១០**

**វិធីសាស្រ្តក្នុងការទូរស័ព្ទដែលមានប្រសិទ្ធភាពខ្ពស់ (ត)**

- ការកត់ត្រា (ការផ្តោតទៅលើគោលដៅជាចំបង/ជួយបង្កើនការគិតពិចារណា និងការឆ្លើយតប/បង្កើនកម្លាំងចិត្ត/ផ្តល់ការកត់ត្រានូវការទូស័ព្ទទំនាក់ទំនង)
- ប្រមូលផ្តុំនិយោជកជាក្រុម រួចធ្វើការទំនាក់ទំនងក្នុងពេលតែមួយ (សន្សំពេលវេលា និងរក្សានូវការបញ្ជូនព័ត៌មានឱ្យជាប់លាប់)
- ប្រើប្រាស់ជម្រើសពេលវេលាក្នុងការណាត់ជួប
- ធ្វើការសង្ខេបនូវចំណុចគន្លឹះរាល់ពេលបញ្ចប់នៃការទូរស័ព្ទ



# បទបង្ហាញទី ៥.៥ :
# ការរៀបចំធ្វើបទបង្ហាញទៅកាន់និយោជក



ទំព័របង្ហាញទី ៥.១១

**តើអ្វីទៅជាការធ្វើបទបង្ហាញ?**

- គឺជាការខិតខំព្យាយាមរបស់បុគ្គលណាមួយក្នុងការបង្ហាញពីគំនិត/ព័ត៌មាន/ការយល់ឃើញរបស់ខ្លួនទៅកាន់បុគ្គលម្នាក់ទៀត ឬក្រុមបុគ្គលផ្សេងទៀត
- ការធ្វើបទបង្ហាញអាចធ្វើឡើងក្នុងលក្ខណៈផ្លូវការ ឬក្រៅផ្លូវការ
- ការធ្វើបទបង្ហាញត្រូវបានបែងចែកជាប្រភេទ រួមមាន:
    - ក្រៅផ្លូវការ
    - បែបបញ្ចុះបញ្ចូល
    - ការលើកទឹកចិត្ត
    - បែបកំសាន្ត

ទំព័របង្ហាញទី ៥.១២

**ការធ្វើបទបង្ហាញមាន ៥ ចំណុចសំខាន់ៗ**

| ជាតុផ្សំ | ពិពណ៌នា |
|---|---|
| ១. ហេតុអ្វីបានជាតម្រូវឱ្យធ្វើបទបង្ហាញ (គោលបំណង)? | ការបញ្ជាក់អំពីអត្តសញ្ញាណអ្នកស្នើសុំតម្រូវការរបស់អ្នកស្នើសុំអត្ថប្រយោជន៍រំពឹងទុកពីការធ្វើបទបង្ហាញ និងប្រសិទ្ធភាពនៃការធ្វើបទបង្ហាញចំពោះអ្នកស្តាប់ |
| ២. តើអ្នកស្តាប់បទបង្ហាញជាមនុស្សប្រភេទណា? | អត្តសញ្ញាណកម្មអ្នកស្តាប់ ការសុំរបស់ពួកគេលើមាតិកានៃបទបង្ហាញ និងប្រតិកម្មរបស់អ្នកស្តាប់ដែលរំពឹងទុកជាមុនលើការធ្វើបទបង្ហាញ |

ទំព័របង្ហាញទី ៥.១២

| ជាតុផ្សំ | ពិពណ៌នា |
|---|---|
| ៣. តើមាតិកានៃបទបង្ហាញមានអ្វីខ្លះ? | ប្រភេទមាតិកានៃបទបង្ហាញរួមមានធនធានដែលអាចរកបាន និងការស្មានទុកជាមុននូវការលំបាកក្នុងការរៀបចំមាតិកា |
| ៤. តើបញ្ហាពេលវេលាមានអ្វីខ្លះ? | កាលបរិច្ឆេទនៃការធ្វើបទបង្ហាញ រយៈពេល និងបញ្ហាពេលវេលានៃការធ្វើបទបង្ហាញ |
| ៥. តើការធ្វើបទបង្ហាញប្រព្រឹត្តទៅនៅទីណា? | ទីតាំង ចំនួនអ្នកស្តាប់ និងការវាយតម្លៃទៅលើបន្ទប់ធ្វើបទបង្ហាញ ឧបករណ៍ និងធនធានដទៃទៀតដែលត្រូវការ និងអាចរកបាន |

ទំព័របង្ហាញទី ៥.១៣

## គម្រោងនៃការធ្វើបទបង្ហាញ

ចំណុចសំខាន់ៗនៃការធ្វើបទបង្ហាញ រួមមានៈ

- សេចក្តីផ្តើម
- តួសេចក្តី
- សេចក្តីបញ្ចប់ ឬការសន្និដ្ឋាន
- វិធីសាស្ត្រ

ទំព័របង្ហាញទី១៤

## ការបង្កើតនូវផែនការនៃការធ្វើបទបង្ហាញ

- រៀបចំនូវសេចក្តីផ្តើម/ចំណុចចាប់ផ្តើម
- វិធីសាស្ត្រ
- ប្រការដែលគួរជៀសវាង
- ចំណុចសំខាន់នៅក្នុងចំណុចចាប់ផ្តើម

ទំព័របង្ហាញទី ៥.១៥

## ការបង្កើតនូវផែនការរៀបចំបទបង្ហាញ

សេចក្តីផ្តើម ➡ តួសេចក្តី ➡ ប្រភេទ

- គោលបំណង
- គោលដៅ
- ទិសដៅ

- ចំណុចសំខាន់
- ចំណុចគាំទ្រ
- ឧទាហរណ៍
- ការប្រៀបធៀប

- រៀបតាមលំដាប់
- ទូទៅទៅជាក់លាក់
- សាមញ្ញទៅស្មុគស្មាញ
- មូលហេតុ
- ស្គាល់ទៅជាមិនស្គាល់
- បញ្ហាទៅជាដំណោះស្រាយ
- ភាពសមហេតុផល

ទំព័របង្ហាញទី ៥.១៦

## ការគ្រប់គ្រងពេលវេលា

- ការគ្រប់គ្រងពេលវេលាក្នុងការធ្វើបទបង្ហាញ
- កត់ត្រានៅក្នុងសៀវភៅកំណត់ត្រាណែនាំរបស់លោកអ្នក
- គ្រោងនូវសំណួរដែលអាចចោទសួរ/ការពិភាក្សា/លំហាត់

ទំព័របង្ហាញទី ៥.១៧

## ទម្រង់គំរូនៃការធ្វើបទបង្ហាញ

| សមាសធាតុ | គោលបំណង |
| --- | --- |
| • សេចក្តីផ្តើម | ណែនាំនូវបទបង្ហាញ និងភ្ជាប់ទំនាក់ទំនងរវាងអ្នកស្តាប់ និងមាតិកា ដើម្បីជម្រុញ និងបញ្ចុះបញ្ចូលពួកគេឱ្យស្តាប់ |

ទំព័របង្ហាញទី ៥.១៧

**ទម្រង់គំរូនៃការធ្វើបទបង្ហាញ (ត)**

| សមាសធាតុ | គោលបំណង |
|---|---|
| • មាតិកា | បង្ហាញនូវផ្នែកដែលត្រូវធ្វើបទបង្ហាញក្នុងមាតិកាទៅកាន់អ្នកស្តាប់ក្នុងវិធីដែលអាចជួយអ្នកសម្រេចនូវគោលបំណងក្នុងការធ្វើបទបង្ហាញរបស់អ្នក |
| • សេចក្តីសង្ខេប | សង្ខេប និងបញ្ជាក់នូវមាតិកាដែលត្រូវធ្វើបទបង្ហាញ |

ទំព័របង្ហាញទី ៥.១៧

**ទម្រង់គំរូនៃការធ្វើបទបង្ហាញ (ត)**

| សមាសធាតុ | គោលបំណង |
|---|---|
| • ការភ្ជាប់សេចក្តី | ទាក់ទាញអ្នកស្តាប់ទៅផ្នែកផ្សេងទៀតនៃមាតិកាត្រូវភ្ជាប់ព័ត៌មានថ្មីដែលទាក់ទងទៅនឹងផ្នែកពីមុន |
| • សេចក្តីបញ្ចប់ | ជម្រុញអ្នកចូលរួមមានសកម្មភាព និងសង្កត់ធ្ងន់លើខ្លឹមសារសំខាន់ៗដែលចង់ឱ្យពួកគេទទួលបាន |

ទំព័របង្ហាញទី ៥.១៨

**ការគ្រប់គ្រងពេលវេលា (ត)**

- ការហាត់សម
  - បទបង្ហាញដែលសំខាន់ត្រូវធ្វើការហាត់សម
  - ការហាត់សមត្រូវនិយាយឱ្យលឺៗ និងកម្រិតពេលវេលាដោយខ្លួនឯង
    - កំណត់ចំណាំទី១: សំណួរដែលបន្លាយពេលវេលានៃការធ្វើបទបង្ហាញ
    - កំណត់ចំណាំទី២: និយាយលឿននៅពេលលោកអ្នកមានអារម្មណ៍ទទួលសម្ពាធ
  - ថតសម្លេង និងធ្វើការវាយតម្លៃ

ការហាត់សមនៅមុខកញ្ចក់ គឺជាវិធីសាស្ត្រដែលធ្វើឱ្យលោកអ្នកមានភាពជឿជាក់

ទំព័របង្ហាញទី ៥.១៩

**សេចក្តីណែនាំក្នុងការចែករំលែកព័ត៌មានត្រលប់**

| <u>សេចក្តីណែនាំ</u> | <u>ការពន្យល់</u> |
|---|---|
| ការផ្តល់ព័ត៌មានត្រលប់ | |
| • ត្រូវមានភាពច្បាស់លាស់ | រៀបរាប់ពីចំណុចដែលលោកអ្នកបានឃើញ និងផលប៉ះពាល់អ្នកស្តាប់ |
| • ការរិះគន់ស្ថាបនា | លើកឡើងនូវវិធីសាស្ត្រ និងគំនិតផ្សេងៗ ដើម្បីយកមកពិចារណា |
| • ខ្លី ឬសង្ខេប | ត្រូវមានភាពច្បាស់លាស់, ផ្តល់ |
| • ពិពណ៌នា/ មិនមែនវិនិច្ឆ័យ | ទិន្នន័យណាដែលមិនទាន់បានផ្តល់ដោយអ្នកដទៃ |

ទំព័របង្ហាញទី ៥.១៩

**សេចក្តីណែនាំក្នុងការចែករំលែកព័ត៌មានត្រលប់**

(ត)

ការទទួលព័ត៌មានត្រលប់

| | |
|---|---|
| • ការស្តាប់ដោយបើកចំហរ | មិនត្រូវមានអារម្មណ៍ទោមនស្ស រំខានដល់ការផ្តល់ព័ត៌មាន ឬមានអារម្មណ៍ដាច់ខាតត្រូវ "**ពន្យល់**" |
| • ការយល់ដឹង | សួរបញ្ជាក់ប្រសិនបើលោកអ្នកស្តាប់មិនច្បាស់ |
| • ការពិចារណា<br>• ការផ្លាស់ប្តូរ | ផ្តល់ពេលវេលាដល់ខ្លួនឯងក្នុងការគិតពិចារណាអំពីព័ត៌មានត្រលប់ និងធ្វើការសម្រេចចិត្តនាពេលក្រោយ គួរធ្វើការផ្លាស់ប្តូរ ឬអត់ |

# លំហាត់ទី ៥.៤:
# ការធ្វើបទបង្ហាញទៅកាន់និយោជកតែម្នាក់

រយៈពេល: ១០០នាទី

គោលបំណង :

- ដើម្បីធ្វើការរៀបចំ និងការធ្វើបទបង្ហាញដល់និយោជកតែម្នាក់

សេចក្តីណែនាំ :

**ផ្នែកទី១: ការរៀបចំធ្វើបទបង្ហាញ (រយៈពេល ៦០ នាទី)**

- ធ្វើការសហការជាមួយក្រុមការងារនៃមជ្ឈមណ្ឌលការងាររបស់លោកអ្នក ដើម្បីរៀបចំការធ្វើបទបង្ហាញដល់និយោជកតែម្នាក់។ រយៈពេលនៃការធ្វើបទបង្ហាញមិនត្រូវឱ្យលើសពី ១០ នាទី
- នៅក្នុងក្រុមការងាររបស់អ្នក:
    - ការលើកឡើងអំពីគោលបំណងនៃការធ្វើបទបង្ហាញ
    - ការគិតទុកជាមុនអំពីប្រតិកម្ម/បញ្ហាពីសំណាក់និយោជក
    - រៀបចំការធ្វើបទបង្ហាញរបស់លោកអ្នកឱ្យបានត្រឹមត្រូវ និងលម្អិត
    - កំណត់ឱ្យបានច្បាស់ពីនិយោជក/វិធីសាស្រ្តដែលលោកអ្នកនឹងត្រូវធ្វើបទបង្ហាញ (ឧទា. ប្រភេទនៃសម្ភារសម្រាប់ការធ្វើបទបង្ហាញ)

**ផ្នែកទី២: អនុវត្តនូវការធ្វើបទបង្ហាញដល់និយោជកតែម្នាក់ (នាទី ៤០រយៈពេល )**

- ការធ្វើបទបង្ហាញដល់ក្រុមនិយោជកផ្សេងទៀត
- ផ្តល់ព័ត៌មានត្រលប់ (Feedback) ទៅលើការធ្វើបទបង្ហាញទាំងនេះដល់ក្រុមពិភាក្សាដែលបានធ្វើបទបង្ហាញ (សូមប្រើប្រាស់នូវទម្រង់ដែលមាននៅក្នុងឧបសម្ព័ន្ធទី ៥.៣)

# លំហាត់ទី ៥.៥:
# ការធ្វើបទបង្ហាញទៅកាន់ក្រុមនិយោជក

រយៈពេល: ៨០នាទី

គោលបំណង:

- ដើម្បីរៀបចំ និងធ្វើបទបង្ហាញដោយមន្ត្រីមជ្ឈមណ្ឌលការងារដល់ក្រុមនិយោជក

សេចក្តីណែនាំ:

- ធ្វើការបែងចែកជាក្រុមពិភាក្សាដែលមានសមាជិក ០៦ នាក់ ដើម្បីធ្វើផែនការរៀបចំ និងធ្វើបទបង្ហាញទៅកាន់ក្រុមនិយោជក។ រយៈពេលនៃការធ្វើបទបង្ហាញមិនត្រូវឱ្យលើសពី ១៥ នាទី (រយៈពេល ៣០ នាទី)។
- នៅក្នុងក្រុមការងាររបស់អ្នក:
  - ធ្វើការពិភាក្សាអំពីភាពខុសគ្នារវាងការធ្វើបទបង្ហាញដល់និយោជកតែម្នាក់ ទៅនឹងក្រុមនិយោជក និងលើកឡើងអំពីផលប៉ះពាល់នៅការធ្វើបទបង្ហាញ។
  - ការលើកឡើងអំពីគោលបំណងនៃការធ្វើបទបង្ហាញ និងរៀបចំអំពីចំណុចដែលត្រូវធ្វើបទបង្ហាញ ការប្រើប្រាស់នូវសម្ភារសម្រាប់ការធ្វើបទបង្ហាញ បញ្ហាដែលអាចកើតមានឡើងជាដើម។ រយៈពេលនៃការធ្វើបទបង្ហាញមិនត្រូវឱ្យលើសពី ១០ នាទី។
  - ត្រូវកំណត់មន្ត្រីដែលត្រូវធ្វើបទបង្ហាញ។
- ការធ្វើបទបង្ហាញទៅកាន់ក្រុមពិភាក្សាដទៃទៀត (រយៈពេល៣០ នាទី)
- ផ្តល់ព័ត៌មានត្រលប់ (Feedback) ទៅលើការធ្វើបទបង្ហាញទាំងនេះដល់ក្រុមពិភាក្សាដែលបានធ្វើបទបង្ហាញ (រយៈពេល ២០ នាទី)។



# បទបង្ហាញទី ៥.៦:
# ការរំលឹកឡើងវិញនូវដំណាក់កាលទាំង ៩ នៅក្នុង ការរៀបចំផែនការសកម្មភាពសម្រាប់ទំនាក់ទំនងនិយោជក



ទំព័របង្ហាញទី ៥.២០

ដំណាក់កាលទាំង ៩ នៅក្នុងការរៀបចំផែនការសកម្មភាពសម្រាប់ទំនាក់ទំនងនិយោជក រួមមាន:

១. ការយល់ដឹងពីអាទិភាពនៅក្នុងតំបន់របស់លោកអ្នក
២. ការយល់ដឹងអំពីសេវារបស់មជ្ឈមណ្ឌលការងារ
៣. ការបង្កើតនូវគោលដៅសម្រាប់ការចុះជួប (ទំនាក់ទំនង)
៤. ការពិនិត្យទិន្នន័យដែលមានស្រាប់ឡើងវិញ

ទំព័របង្ហាញទី ៥.២០

ដំណាក់កាលទាំង ៩ នៅក្នុងការរៀបចំផែនការសកម្មភាពសម្រាប់ទំនាក់ទំនងនិយោជក (ត)

៥. ការស្វែងយល់ពីសំណួរដើម្បីកំណត់ពីតម្រូវការរបស់និយោជក
៦. ការជ្រើសរើសមធ្យោបាយក្នុងការផ្សព្វផ្សាយ
៧. រៀបចំកម្មវិធី(ពេលវេលា)ក្នុងការទំនាក់ទំនង
៨. កត់ត្រាព័ត៌មានទំនាក់ទំនង
៩. ការរៀបចំធ្វើបទបង្ហាញ

## ឧបសម្ព័ន្ធទី ៥.១ : តារាងផែនការ Marketing

ដំណាក់កាលទី១

| ឈ្មោះនិយោជក | មូលហេតុនៃការកំណត់និយោជកគោលដៅ | | | | | | | | គំនិតផ្តួចផ្តើម Marketing ( Marketing Initiative ) | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិស័យរីកចំរើន | វិស័យដែលជួប ឱនភាព | តម្រូវការមុខរបរ | និយោជកថ្មី | សហគ្រាសថ្មី | អត្រាផ្លាស់ប្តូរ មុខរបរ | អត្រាបញ្ឈប់ | និយោជកអាចទ ភាពផ្សេងទៀត | ព័ត៌មានជ្រើស រើសបុគ្គលិកថ្មី | ការកំណត់ពី តម្រូវការ | ការងារមានក្នុង ទីផ្សារស្រាប់ | ដោះស្រាយ បំបាក់ការងារ | ទាក់ទងជាមួយ និយោជកថ្មី | ផ្សេងទៀត | យោបល់ |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |

ដំណាក់កាលទី២ - និយោជកដែលបានជ្រើសរើសសម្រាប់ឆ្នាំ ២០១០ - ២០១៥

| ឈ្មោះនិយោជកដែលបានជ្រើសរើស | ត្រីមាសដែលត្រូវចុះជួបនិយោជក | | | | មូលហេតុនៃការកំណត់និយោជកគោលដៅ | | | | | | | | គំនិតផ្តួចផ្តើម Marketing ( Marketing Initiative ) | | | | | | | កាលបរិច្ឆេទដែលបានចុះជួបជាស្ថាពរ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទី១ | ទី២ | ទី៣ | ទី៤ | វិស័យរីកចំរើន | វិស័យដែលជួប ឱនភាព | តម្រូវការមុខរបរ | និយោជកថ្មី | សហគ្រាសថ្មី | អត្រាផ្លាស់ប្តូរ មុខរបរ | អត្រាបញ្ឈប់ | និយោជកអាចទី ការពង្រីកទៀត | ព័ត៌មានជ្រើស រើសបុគ្គលិកថ្មី | ការកំណត់ពី តម្រូវការ | ការងារមានក្នុង ទីផ្សារស្រាប់ | ដោះស្រាយ បំពេញការងារ | ទាក់ទងជាមួយ និយោជកថ្មី | ផ្សេងទៀត | យោបល់ | |
| | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | |

## ឧបសម្ព័ន្ធទី ៥.២:
## គុណសម្បត្តិ និងគុណវិបត្តិនៃការទំនាក់ទំនងនិយោជកតាមទូរស័ព្ទ និងការចុះជួបនិយោជក

ការទំនាក់ទំនងនិយោជកតាមទូរស័ព្ទ និងការចុះជួបនិយោជកដោយផ្ទាល់ គឺជាមធ្យោបាយនៃការផ្សព្វផ្សាយដោយក្នុងនោះមានគុណសម្បត្តិ និងគុណវិបត្តិដូចបង្ហាញជូនខាងក្រោម។

### ការទំនាក់ទំនងតាមទូរស័ព្ទ

| គុណសម្បត្តិ និងគុណវិបត្តិ: ការទំនាក់ទំនងតាមទូរស័ព្ទ | |
|---|---|
| **គុណសម្បត្តិ** | **គុណវិបត្តិ** |
| - គ្របដណ្តប់បានទូលំទូលាយ<br>- អាចគ្រប់គ្រងពេលវេលា<br>- អាចប្រើប្រាស់មន្ត្រីបានច្រើន<br>- ចំពោះមន្ត្រីដែលរងសម្ពាធក្នុងការណាត់ជួប ១ ទល់នឹង១ ការទូរស័ព្ទគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាព<br>- មានភាពងាយស្រួលក្នុងការប្រើប្រាស់ឯកសារយោងនានា<br>- អាចជួយដោះស្រាយបញ្ហាបុគ្គល ១ ទល់នឹង ១<br>- អាចធ្វើការផ្ទៀងផ្ទាត់ព័ត៌មានឱ្យបានច្បាស់លាស់ និងកែសម្រួលនូវចំណុចភាន់ច្រឡំ<br>- អាចធ្វើការទំនាក់ទំនងនិយោជក ទោះបីជានៅឆ្ងាយពីគ្នា<br>- កាត់បន្ថយនូវការចំណាយពេលវេលារបស់និយោជក | - មិនបានឃើញទីតាំងរបស់និយោជក សម្ភារ និងបុគ្គលិកនាគ្រាដំបូង<br>- និយោជកអាចបដិសេធ ក្នុងការសន្ទនាជាមួយមន្ត្រីមជ្ឈមណ្ឌលការងារ ឬបិទទូរស័ព្ទ<br>- មិនបានជួបបុគ្គលដែលបានទំនាក់ទំនង |

### ការចុះជួបនិយោជកដោយផ្ទាល់

| ការចុះជួបនិយោជកដោយផ្ទាល់ | |
|---|---|
| **គុណសម្បត្តិ** | **គុណវិបត្តិ** |
| - អាចឃើញទីតាំងរបស់និយោជក សម្ភារ និងកម្មករ<br>- អាចលើកឡើងអំពីបញ្ហា ឬតម្រូវការជាក់លាក់របស់និយោជក<br>- បានស្គាល់មុខ និងឈ្មោះរបស់និយោជក<br>- និយោជកបានស្គាល់មុខ និងឈ្មោះមន្ត្រីមជ្ឈមណ្ឌលការងារ | - ចំណាយពេលវេលា<br>- ចំណាយថវិកាក្នុងការធ្វើដំណើរ<br>- មិនបានជួបបុគ្គលដែលបានទំនាក់ទំនង<br>- ការពិភាក្សានឹងចំណាយពេលយូរ ប្រសិនបើនិយោជកមិនបានកំណត់បញ្ហា/តម្រូវការបានទុកជាមុន |

| ការចុះជួបនិយោជកដោយផ្ទាល់ | |
|---|---|
| - អាចប្រើប្រាស់នូវវិធីសាស្ត្រក្នុងការលក់ដូរទំនិញ<br>- និយោជកមិនសូវធ្វើការរិះគន់ ណោក្នុងការចុះជួបដោយផ្ទាល់ ដាដាងការមិនស្គាល់មុខ និងឈ្មោះ<br>- អាចធ្វើការផ្ទៀងផ្ទាត់ព័ត៌មានឱ្យបានច្បាស់លាស់ និងកែសម្រួលនូវចំណុចភាន់ច្រឡំ<br>- ប្រសិនបើរក្សាបាននូវការចុះជួបនិយោជកឱ្យបានជាប់លាប់ លក្ខខណ្ឌអវិជ្ជមានជាច្រើននឹងត្រូវបានកាត់បន្ថយ | - និយោជកអាចត្រូវរំខានដោយសម្ពាធការងារផ្សេងទៀត<br>- មិនទាន់បានរៀបចំឯកសារទុកជាមុន<br>- អាចត្រូវរង់ចាំយូរដើម្បីបានជួបនិយោជក |

### តើត្រូវដោះស្រាយនូវគុណវិបត្តិខាងលើយ៉ាងដូចម្ដេច?

តាមរយៈការពិចារណាទៅលើចំណុចគុណសម្បត្តិ និងគុណវិបត្តិនៅក្នុងចំណុចខាងក្រោមនេះនឹងធ្វើការបង្ហាញជូនអំពីវិធីសាស្ត្រក្នុងការដោះស្រាយចំណុចគុណវិបត្តិខាងលើព្រមជាមួយនឹងវិធីសាស្ត្រដែលធ្លាប់បានប្រើប្រាស់នៅក្នុងប្រទេសកាណាដានាពេលកន្លងមក។

### ការចុះជួបនិយោជកដោយផ្ទាល់

តាមរយៈការស្ទង់មតិពីសំណាក់មជ្ឈមណ្ឌលការងារជាច្រើនបានបង្ហាញឱ្យឃើញថា "ការទំនាក់ទំនងតាមទូរស័ព្ទ" (Cold call) ហាក់បីដូចជាមិនសូវមានប្រសិទ្ធភាព ក៏ប៉ុន្តែការទំនាក់ទំនងតាមទូរស័ព្ទលើកដំបូង លោកអ្នកអាច :

- កាត់បន្ថយនូវការចុះជួប និងដោះស្រាយបញ្ហាតាមទូរស័ព្ទ
- រៀបចំការណាត់ជួបទុកជាមុនជាមួយបុគ្គលដែលលោកអ្នកចង់ជួបនៅក្នុងអង្គភាព
- ស្មានទុកជាមុនអំពីប្រភេទនៃការទទួលស្វាគមន៍ដែលលោកអ្នកអាចនឹងទទួល
- ការត្រៀមទុកជាមុន និងការរៀបចំសម្ភារ ឬឯកសារពាក់ព័ន្ធដែលនឹងត្រូវប្រើប្រាស់

### ករណីលើកលែង:

- លោកអ្នកបានព្យាយាមទំនាក់ទំនងតាមទូរស័ព្ទ ក៏ប៉ុន្តែមិនបានសម្រេច
- និយោជកជាច្រើនបានប្រមូលផ្ដុំនៅកន្លែងតែមួយ (មជ្ឈមណ្ឌលលក់ទំនិញ ឬតំបន់រោងចក្រ) ដែលលោកអ្នកអាចជួបនិយោជកជាច្រើនដោយប្រើពេលតិចតួច។
- ចំពោះការណាត់ជួបនិយោជកដែលមានកម្រិតទាប (ប្រកបអាជីវកម្មតូចតាច) ដូចជាអ្នកលក់ឥវ៉ាន់ ឬផ្នែកសេវាម្ចាស់ហាង ឬអ្នកគ្រប់គ្រងនៅនឹងកន្លែងរបស់អ្នកទាំងនោះ និងដែលអាចជួបទំនាក់ទំនងបាន។ ចំណុចសំខាន់នោះគឺពេលវេលាដូចជាលោកអ្នកមិនត្រូវធ្វើការណាត់ជួបនៅពេលស្រស់ស្រូបអាហារជាដើម។

**ការចុះជួបនិយោជកដោយផ្ទាល់មានសារៈសំខាន់ណាស់នៅពេលដែលៈ**

- លោកអ្នកត្រូវណែនាំដល់បុគ្គលិកអំពីបរិស្ថានការងារ ឧទា. ជានិយោជកថ្មី ឬជាបុគ្គលិកថ្មី ដូចជាមានកិច្ចការបែបថ្មីនៅក្នុងបរិស្ថានការងារ ឬមានម៉ាស៊ីនថ្មីជាដើម (ឧទា. លោកអ្នកមិនចាំបាច់ធ្វើការចុះជួបនិយោជកនៅកន្លែងលក់ទំនិញ ១០ កន្លែង ដើម្បីពិនិត្យអំពីបែបផែនក្នុងការធ្វើការនោះទេ)
- លោកអ្នកកំពុងដោះស្រាយបញ្ហាដល់និយោជកដ៏សំខាន់ និងមិនដែលចុះជួបកាលពីមុនមក
- លោកអ្នកត្រូវដោះស្រាយបញ្ហាដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាដែលមានកម្រិតទាបដោយសារលោកអ្នកមានអត្រាអ្នកស្វែងរកការងារធ្វើខ្ពស់នៅក្នុងការបញ្ជូនទៅនិយោជក
- លោកអ្នកជួបប្រទះបញ្ហាតាមទូរស័ព្ទ។ និយោជករូបនោះមិនមានភាពទើសទាល់ ឬរើសអើងក្នុងការចុះជួបដោយផ្ទាល់ ។

**ការទំនាក់ទំនងតាមទូរស័ព្ទ**

នៅក្នុងអំឡុងពេលទូរស័ព្ទផ្សព្វផ្សាយអំពីសេវារបស់មជ្ឈមណ្ឌលការងារ លោកអ្នកប្រើប្រាស់ព័ត៌មានដែលធ្លាប់ប្រើ (Piggy back) ហើយយកទៅប្រើប្រាស់សម្រាប់ការទូស័ព្ទទៅកាន់និយោជកដទៃទៀត។ លោកអ្នកអាចតម្រូវការបុគ្គលិកបន្ថែមទៀត នៅពេលដែលៈ

- និយោជកបានទូរស័ព្ទមកកាន់មជ្ឈមណ្ឌលការងារ ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានជ្រើសរើសបុគ្គលិក
- ធ្វើការតាមដាន (Follow-up) ចំពោះការបញ្ជូនឈ្មោះអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជក
- ធ្វើការតាមដានចំពោះការប្រកបរបរអាជីវកម្ម (Placement follow-up)

**ការទំនាក់ទំនងតាមទូរស័ព្ទមានប្រសិទ្ធិភាពបំផុត នៅពេលដែលៈ**

- ផ្លូវធ្វើដំណើរមានចំងាយឆ្ងាយ
- និយោជក គឺជាអតិថិជនដែលប្រើប្រាស់នូវសេវាជាប្រចាំ និងចាំបាច់ថែរក្សាទំនាក់ទំនងតាមទូរស័ព្ទ (ទំនាក់ទំនងនិយោជកជាប្រចាំ)
- ការប្រមូលព័ត៌មានជ្រើសរើសបុគ្គលិកថ្មីៗ
- ធ្វើការតាមដានឈ្មោះអ្នកស្វែងរកការងារធ្វើដែលបានបញ្ជូនទៅ និងកន្លែងការងារថ្មីៗ
- ការផ្សព្វផ្សាយទៅកាន់និយោជកដោយឡែកៗពីគ្នា
- ការទទួលបានព័ត៌មានទីផ្សារការងារ
- ការធ្វើបច្ចុប្បន្នកម្មកំណត់ត្រានិយោជក
- ការបង្កើតនូវចំណាប់អារម្មណ៍ដំបូងនៅក្នុងកម្មវិធី (ដែលចាំបាច់ឱ្យធ្វើការចុះជួប)
- លោកអ្នកមានការលំបាកក្នុងការចុះជួបនិយោជកដោយផ្ទាល់

# មេរៀនទី៦

## ផែនការសកម្មភាព និងការវាយតម្លៃវគ្គបណ្តុះបណ្តាល



**គោលបំណងនៃការសិក្សា :** នៅពេលបញ្ចប់មេរៀនទី៦ នេះ សិក្ខាកាមទាំងអស់នឹងអាចៈ

- ចូលរួមក្នុងការរំលឹកឡើងវិញនូវចំណុចគន្លឹះនៃដំណើរការប្រឹក្សាយោបល់ការងារ យុទ្ធសាស្ត្រក្នុងការផ្តល់សេវាការងារ និងការរំលឹកវគ្គ បណ្តុះ បណ្តាលទាំងមូលឡើងវិញ
- បង្កើតនូវផែនការសកម្មភាពដែលប្រើប្រាស់ជំនាញ និងចំណេះដឹងទទួលបានពីវគ្គបណ្តុះបណ្តាលយកទៅអនុវត្តនៅតាមមជ្ឈមណ្ឌលការងាររៀងៗខ្លួន
- ចូលរួមធ្វើការវាយតម្លៃវគ្គបណ្តុះបណ្តាល

**រយៈពេល** ៣ ម៉ោង

**សេចក្តីសង្ខេប** នៅក្នុងមេរៀននេះៈ

- បទបង្ហាញទី ៦.១ : ទម្រង់តារាងសង្ខេបនៃការផ្តល់សេវាការងារ
- លំហាត់ទី ៦.១ : ការរំលឹកឡើងវិញ និងការពិភាក្សាទៅលើទម្រង់គំរូនៃការផ្តល់ប្រឹក្សាយោបល់ការងារ
- លំហាត់ទី ៦.២ : ផែនការសកម្មភាព
- លំហាត់ទី ៦.៣ : ការវាយតម្លៃវគ្គបណ្តុះបណ្តាល និងការបញ្ចប់

# ការបង្ហាញទី ៦.១: ការរំលឹកឡើងវិញអំពីទម្រង់គំរូនៃការផ្តល់សេវាការងារ ទម្រង់គំរូនៃសេវាប្រឹក្សាយោបល់ការងារ





# លំហាត់ទី ៦.១ : ការរំលឹកឡើងវិញ និងការពិភាក្សា លើទម្រង់គំរូនៃការផ្ដល់ប្រឹក្សា យោបល់ការងារ



រយៈពេល: ៣៥នាទី

គោលបំណង :

- ធ្វើការរំលឹកឡើងវិញអំពីទម្រង់គំរូវាយតម្លៃនៃការផ្ដល់ប្រឹក្សាយោបល់ការងារ ដែលបានលើកឡើងក្នុងអំឡុងវគ្គបណ្ដុះបណ្ដាល និងការពិភាក្សាទៅលើសំនួរ/បញ្ហារបស់សិក្ខាកាម។

សេចក្ដីណែនាំ :

- អ្នកផ្ដល់ការបណ្ដុះបណ្ដាលនឹងដឹកនាំក្រុមពិភាក្សា ដើម្បីធ្វើការសង្ខេបអំពីចំណុចសំខាន់ៗដែលមាននៅក្នុងទម្រង់គំរូនៃការផ្ដល់ប្រឹក្សាយោបល់ការងារ (ប្រហែល ២០ នាទី)។
- សិក្ខាកាមធ្វើការកត់ត្រានូវសំនួររៀងៗខ្លួនដែលមាននៅក្នុងវគ្គបណ្ដុះបណ្ដាល ឬអំពីការអនុវត្តការងាររបស់សិក្ខាកាមនៅតាមមជ្ឈមណ្ឌលការងារ។
- អ្នកផ្ដល់ការបណ្ដុះបណ្ដាលនឹងឆ្លើយរាល់សំណួររបស់សិក្ខាកាម (រយៈពេល ២០ ទៅ ៣០នាទី)។



# លំហាត់ទី ៦.២ : ផែនការសកម្មភាព



រយៈពេល: ៤៥នាទី

គោលបំណង:

- ដើម្បីឱ្យសិក្ខាកាមទាំងអស់មានសមត្ថភាពបង្កើតនូវផែនការសកម្មភាព នៅពេលត្រលប់ទៅបំពេញការងារនៅតាមមជ្ឈមណ្ឌលការងារ និងអនុវត្តនូវចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាល។

សេចក្តីណែនាំ:

- ធ្វើការបែកចែកជាក្រុមពិភាក្សាទៅតាមមជ្ឈមណ្ឌលការងារនីមួយៗ
- ការបង្កើតនូវផែនការសកម្មភាព ដែលរួមបញ្ចូលនូវ:
    - o ផែនការដែលពាក់ព័ន្ធទៅនឹងវិធីសាស្ត្រដែលលោកអ្នកនឹងធ្វើបទបង្ហាញនិងធ្វើការពិភាក្សាអំពីចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាលជូនដល់ប្រធានមជ្ឈមណ្ឌលការងារ (អ្នកគ្រប់គ្រង)។
    - o ផែនការដែលមានរយៈពេល៣ខែ ដែលត្រូវបានរៀបចំឡើងត្រូវធ្វើការពិភាក្សាជាមួយប្រធានមជ្ឈមណ្ឌលការងារអំពីវិធីសាស្ត្រក្នុងការចាប់ផ្តើមផ្តល់សេវាប្រឹក្សាយោបល់ការងារដល់និយោជក (ផែនការសកម្មភាពនេះត្រូវមានជម្រើសភ្ជាប់មកជាមួយ)។
    - o តារាងដែលបានកត់ត្រាទុកអំពីបញ្ហាប្រឈមដែលលោកអ្នកនឹងត្រូវពុះពារដើម្បីអនុញ្ញាតឱ្យលោកអ្នកអាចអនុវត្តបានយ៉ាងពេញលេញ នៅក្នុងការផ្តល់សេវាប្រឹក្សាយោបល់ការងារដល់និយោជកនៅមជ្ឈមណ្ឌលការងាររបស់ខ្លួន និងអំពីវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាទាំងនេះ។ សូមធ្វើការពិចារណាទៅលើបញ្ហាប្រឈមទាំងអស់រួមមាន:
        - បញ្ហាប្រឈមដែលលោកអ្នកជួបប្រទះនៅក្នុងអំឡុងពេលផ្តល់សេវាប្រឹក្សាយោបល់ការងារ( ឧទាបញ្ហាពេលវេលាជាដើម )
        - បញ្ហាប្រឈមដែលកើតឡើងដល់អ្នកស្វែងរកការងារធ្វើ ក្នុងការទទួលបាននូវសេវាប្រឹក្សាយោបល់ការងារប្រភេទនេះ
        - បញ្ហាប្រឈមដែលកើតឡើងក្នុងពេលសហការជាមួយភាគីពាក់ព័ន្ធ ដូចជាវិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាដើម។
- នៅក្នុងក្រុមពិភាក្សាធំ សូមធ្វើការបង្ហាញអំពីផែនការសកម្មភាពដោយសង្ខេប (រយៈពេល ៧០ នាទី)

# លំហាត់ទី ៦.៣ : ការវាយតម្លៃវគ្គបណ្តុះបណ្តាល និង ការបញ្ចប់

រយៈពេល: ៥០នាទី

គោលបំណង:

- ការបញ្ចប់នូវការវាយតម្លៃវគ្គបណ្តុះបណ្តាល

សេចក្តីណែនាំ:

- ការបញ្ចប់នូវការសរសេរវាយតម្លៃវគ្គបណ្តុះបណ្តាល (រយៈពេល ២០ នាទី)
- អ្នកផ្តល់ការបណ្តុះបណ្តាលនឹងដឹកនាំការពិភាក្សាដែលពាក់ព័ន្ធទៅនឹងយោបល់ និងការទទួលបានព័ត៌មានត្រលប់ (Feedback) ទៅលើវគ្គបណ្តុះបណ្តាលរបស់សិក្ខាកាម (រយៈពេល ២០ នាទី)។ ដោយយោងទៅលើគោលបំណងនៃការសិក្សារបស់សិក្ខាកាម និងកំណត់ត្រាបុគ្គល (រយៈពេល ២០ នាទី)។
- អ្នកផ្តល់ការបណ្តុះបណ្តាលនឹងធ្វើការសង្ខេបអំពីវគ្គបណ្តុះបណ្តាលនៅទីបញ្ចប់ (រយៈពេល ១០ នាទី)។